៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៨ ខែ មីនា

ព.ស. ២៥០៨ គ.ស. ១៩៦៦

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង


**ផ្នែកសាសនា** — ទំព័រ

១– បុណ្យជាការលំបាកធ្វើ ឬក៏ងាយ លោក ផល-ទិត ដកស្រង់និងរៀបរៀង . . ២៤៣

២– ចុះពិភពលោកយើងនេះ ការចាប់ផ្ដើមកកើតមានឡើងជាដំបូងនោះតើដោយ អាស្រ័យហេតុអ្វី ? លោក ប៊ូ-ប៉ូ រៀបរៀង . . . . . ២៤៨

**ផ្នែកអក្សរសាស្ត្រ**

៣– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ២៧៤

៤– ប្រវត្តិនៃខេត្តស្វាយរៀង ព្រះមុនីកោសល ស្វរ-ហាយ រៀបរៀង . . ២៧៧

៥– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. តាម ស្រាវជ្រាវ (ត) . . . . . ២៨៣

៦ អធិប្បាយភាសិត ពាក្យកាព្យ បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ (ត) . ២៩៩

៧– ឯកសារ សាស្ត្រាស្ទឹករីតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ៣១៥

៨– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) . . . ៣១៩

៩– ឯកសារ កម្ពុជសុរិយា លោក ឌ-តាម ប្រមូលរៀបរៀង (ត) . . . ៣២៣

**ផ្នែកកំណត់និងប្រវត្តិការណ៍**

១០– សេចក្ដីកត់ហេតុនៃការប្រជុំការងារនៅពុទ្ធសាសនបណ្ឌិត្យ ថ្ងៃទី ១១-៣-៦៦ . ៣៣៩


---


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវី ២៣០៛០០ ។

ព្រះរាជអាណាចក្រកម្ពុជា
លេខ ២៤៨ / SPU

# សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ
# សហជីវិន នាយកវិជ្ជាស្ថានពុទ្ធសាសន-
# បណ្ឌិត្យ ជាទីស្នេហា

ខ្ញុំសូមអនុមោទនាទទួលដោយសោមនស្សរីករាយ និងដោយកតញ្ញុតាធម៌ នូវសព្ទសាធុការពរជ័យ ដែលសហជីវិនប្រសិទ្ធិថ្វាយខ្ញុំ ក្នុងឱកាសចូលឆ្នាំថ្មីនេះ តាងព្រះនាមនៃព្រះសង្ឃជាសមាជិកនៃក្រុមជំនុំព្រះត្រៃបិដក ដែលមានសម្តេចព្រះពោធិវង្ស ហួត តាត ជាអធិបតី និងព្រះតេជគុណព្រះមុនីកោសល ស៊ូរ-ហាយ ជាអធិបតីរង ព្រមទាំងក្នុងនាមនៃបុគ្គលិកនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យទាំងអស់ ។

ម្យ៉ាងទៀត ក្នុងឱកាសដ៏ប្រសើរដែលនេះ សហជីវិនមានសទ្ធាជ្រះថ្លាផ្ញើមកថ្វាយខ្ញុំ នូវសៀវភៅគម្ពីរព្រះត្រៃបិដកចំនួន ៨៤ ក្បាល ដែលជាស្នាព្រះហស្ត-ស្នាដៃដ៏ឧត្តមរបស់ព្រះសង្ឃ និងគ្រហស្ថជាសមាជិកចំណាន ៗ នៃក្រុមជំនុំព្រះត្រៃបិដក ក្រោមការដឹកនាំយ៉ាងស្ទាត់ជំនាញបំផុត នៃសម្តេចព្រះពោធិវង្សដ៏ជាទីស្នេហា ទីគោរពរបស់ខ្ញុំ និងពុទ្ធបរិ-ស័ទទូទៅទាំងប្រទេស ដែលបានទទួលកេរ្តិ៍ឈ្មោះយ៉ាងល្បីល្បាញខាងវិស័យព្រះពុទ្ធសាសនា ដោយសារក្រុមជំនុំព្រះត្រៃបិដកយើងនេះក្នុងផ្ទៃពិភពអន្តរជាតិអ្នកកាន់ព្រះពុទ្ធសាសនាដូចគ្នា ។

ហេតុនេះ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងនូវសេចក្ដីសរសើរ និងសេចក្ដីអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ប្រគេន និង ជូន សមាជិកទាំងអស់នៃក្រុមជំនុំព្រះត្រៃបិដក មានសម្ដេចព្រះពោធិវង្សជាអាទិ ហើយសូមទេវតាឆ្នាំថ្មី និង ផលានិសង្ស ដែលហូរចេញពីការបកប្រែព្រះត្រៃបិដកនេះ ជួយអភិបាលថែរក្សាសម្ដេចព្រះពោធិវង្ស និងព្រះសង្ឃគ្រប់ព្រះអង្គ ព្រមទាំងកូនចៅជាទីស្នេហាទាំងអស់ ឲ្យបានប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញ ថ្ងៃទី ៣០ មីនា ១៩៦៦

ព្រះហស្ដលេខា: នរោត្ដមសីហនុ

សហជីវិន ណាង-ហ៊ប់អាន
នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ—

បានចម្លងតាមព្រះរាជចុហ្មាយដើមត្រឹមត្រូវហើយ
ថ្ងៃទី ១ មេសា ឆ្នាំ ១៩៦៦
នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

ណាង-ហ៊ប-អាន

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

# បុណ្យ ជាការលំបាកធ្វើ ឬក៏ងាយ

លោក ផល-ទិត អ្នកនិពន្ធតែងសេចក្តី នៅពុទ្ធសាសនបណ្ឌិត្យ ដកស្រង់ និងរៀបរៀង
ព្រះមុនីកោសល ក្សូរ-ហាយ អធិបតីរងក្រុមជំនុំព្រះត្រៃបិដកពិនិត្យ

អថខោ វច្ឆគោត្តោ បរិព្វាជកោ[១]... គ្រាមួយនោះ មានបរិព្វាជកម្នាក់ ជាវច្ឆគោត្រ បានចូលទៅសុំគាល់ព្រះមានព្រះភាគ ។ លុះចូលទៅដល់ ធ្វើសេចក្តីសំណេះសំណាលជាមួយព្រះមានព្រះភាគ រួចអង្គុយគង់ទីសមគួរហើយ, បរិព្វាជកនោះ ក៏ទូលសួរព្រះមានព្រះភាគថា : សុតំ មេ ភោ គោតម... បពិត្រព្រះគោតម ! ខ្ញុំបានឮគេនិយាយថា ព្រះអង្គទ្រង់ត្រាស់ថា បុគ្គលគួរតែឲ្យទានដល់តថាគត និងសាវ័ករបស់តថាគតបានហើយ, ចូរកុំឲ្យទានដល់ពួកជនដទៃក្រៅពីនេះ, ព្រោះទាន ដែលបុគ្គលឲ្យដល់ព្រះតថាគត និងសាវ័ករបស់ព្រះតថាគត ទើបមានផលច្រើន, ឯទានដែលបុគ្គលឲ្យដល់ពួកជនដទៃ

១ សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ទុតិយភាគ ៤១ ទំព័រ ១៤៣

ក្រៅពីនេះ មិនសូវបានផលទេ ៗ បពិត្រព្រះគោតម ! ខ្ញុំព្រះអង្គនិយាយនេះ គ្មានចេតនានឹងបង្កាច់ពាក្យព្រះអង្គទេ ! ប៉ុន្តែពួកជនដែលនិយាយប្រាប់ខ្ញុំព្រះអង្គយ៉ាងហ្នឹង គេឈ្មោះថានិយាយតាមពាក្យព្រះអង្គ មិននិយាយបង្កាច់ព្រះអង្គដោយពាក្យមិនពិត ឬឈ្មោះថានិយាយសមហេតុ-ផលដែលមិនគួរឲ្យអ្នកផងតិះដៀលបានឬទេ ?

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា :

ម្នាលវច្ឆៈ ! ពួកជនដែលនិយាយយ៉ាងហ្នឹង គឺយកពាក្យពុំពិតពុំទៀងមកបង្កាច់តថាគតទេ ៗ ម្នាលវច្ឆៈ អ្នកណាមួយហាមឃាត់មិនឲ្យគេធ្វើទាន, អ្នកនោះ ឈ្មោះថាបៀតបៀន បំផ្លាញ ដល់ជន ៣ ពួក គឺបំផ្លាញបុណ្យរបស់អ្នកឲ្យ ១ បំផ្លាញលាភរបស់អ្នកទទួល ១ កាស់រំលើងកំចាត់កំចាយនូវគុណល្អរបស់ខ្លួនឯង ដែលមានហើយក្នុងពេលមុន ១ ៗ ម្នាលវច្ឆៈ ចំណែកខាងតថាគត ពោលយ៉ាងនេះថា សូម្បីសត្វល្អិតល្អោចទាំងឡាយ ដែលរស់នៅក្នុងអណ្តូងជ្រាំស្មោកគ្រោក ឬក្នុងរណ្តៅជ្រាំស្មោកគ្រោក, បើជនណាមួយ ចាក់ទឹកលាងចានក្តី ទឹកលាងឆ្នាំងក្តី ទៅក្នុងអណ្តូងរណ្តៅជ្រាំទាំងនោះដោយចេតនាគិតថា « សូមឲ្យពួកសត្វដែលនៅក្នុងទីស្មោកគ្រោកទាំងនោះ បានអាស្រ័យនូវភាគសំណល់អាហារ ដែលអាត្មាអញចាក់ទៅនេះ ដើម្បីឲ្យវាបានមានជីវិតរស់កនទៅចុះ » ៗ

នៃវច្ឆៈ គ្រាន់តែប៉ុណ្ណឹង ក៏តថាគតហៅថា ជាហេតុឲ្យបានបុណ្យទៅហើយដែរ ចាំបាច់និយាយថ្វី ដល់ការឲ្យទានចំពោះមនុស្សត្រឡាំងនោះ ។ ម្នាលវច្ឆៈ ប៉ុន្តែ តថាគតគ្រាន់តែនិយាយថា ការឲ្យទានដល់មនុស្សមានសីល មានផលច្រើន ជាងឲ្យទានដល់មនុស្សឥតសីល តែប៉ុណ្ណោះ ពីព្រោះបុគ្គលមានសីល បានលះអង្គ ៥ នោះ គឺ លះ កាមច្ឆន្ទៈ១ ព្យាបាទៈ១ ថីនមិទ្ធៈ១ ឧទ្ធច្ចកុក្កុច្ចៈ១ វិចិកិច្ឆា ១ ។ ប្រកបដោយអង្គ ៥ នោះគឺ ប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ដោយសមាធិក្ខន្ធជាអសេក្ខៈ១ ដោយបញ្ញាក្ខន្ធជាអសេក្ខៈ១ ដោយវិមុត្តិក្ខន្ធជាអសេក្ខៈ១ ដោយវិមុត្តិញាណទស្សនៈជាអសេក្ខៈ១ ។

តថាគតពោលថា ទានដែលបុគ្គលឲ្យចំពោះបុគ្គលអ្នកលះអង្គ ៥ ប្រកបដោយអង្គ ៥ នេះ ជាទានមានផលច្រើន ដោយប្រការដូច្នេះឯង ។

## សេចក្តីបន្ថែម

ផលនៃបុណ្យ មាន ២ យ៉ាង គឺ

១ – ផលដែលជា វដ្តគាមិ - ផលសម្រាប់ជូនដំណើរក្នុងវដ្តៈ,

២ – ផលដែលជា វិវដ្តគាមិ - ផលសម្រាប់ជូនដំណើរចេញវដ្តៈ ទៅកាន់និព្វាន ។

បណ្តាផលទាំង ២ នេះ, ផលដែលជា វដ្តគាមិ ជាផលជួយ

ទំនុកបំរុងមនុស្សសត្វឲ្យមានសម្បត្តិក្នុងវដ្ដៈ គឺក្នុងមនុស្សលោក, ក្នុងទេវលោក និងក្នុងព្រហ្មលោក, ប៉ុន្តែមិនមែនជាផលអាចរុញច្រានមនុស្សសត្វឲ្យទៅដល់ព្រះនិព្វានបានទេ ។ ចំណែកខាងផលទី ២ គឺ ផលវិវដ្ដគាមិ ទើបជាផលថ្លៃថ្លា ព្រោះអាចឲ្យសម្បត្តិដល់មនុស្សសត្វក្នុងវដ្ដៈនេះផង, អាចជ្រោងមនុស្សសត្វឲ្យផ្លងផុតវដ្ដៈទៅដល់ត្រើយគឺនិព្វានបានទៀតផង ។ ព្រោះហេតុអ្វីក៏ដូច្នោះ? ព្រោះហេតុកម្លាំងផលទាំង ២ នេះខុសគ្នា ។ កម្លាំងផលវដ្ដគាមិ ជាកម្លាំងខ្សោយជាងកម្លាំងរបស់ផលវិវដ្ដគាមិ, បើប្រៀបឲ្យងាយយល់, ដូចជានាវាតូចនិងធំ ៗ នាវាតូច បានដល់ទូកតូចៗដែលសម្រាប់ប្រើប្រាស់ក្នុងស្ទឹងទន្លេផិតៗ, ឯនាវាធំ បានដល់ទូកធំៗដែលហៅថាសំពៅ ឬកប៉ាល់ធំៗដែលសម្រាប់ឆ្លងសមុទ្រពីទ្វីបមួយទៅទ្វីបមួយយ៉ាងឆ្ងាយល្វឹងល្វើយ ។ ទូកតូចនិងទូកធំទាំងពីរនេះ, បើឈ្មោះថានាវាដូចគ្នាយ៉ាងហ្នឹង, តើអាចប្រើប្រាស់បានដូចគ្នាដែរឬ? មិនដូចគ្នាទេ គឺទូកតូចមិនអាចឆ្លងសមុទ្របានឡើយ, តែទូកធំវិញ គេប្រើប្រាស់ក្នុងស្ទឹង ទន្លេក៏បាន ឆ្លងមហាសមុទ្រពីទ្វីបមួយទៅទ្វីបមួយផ្សេងទៀតក៏បាន ។ ទូកទាំងពីរនេះ មានកម្លាំងខុសគ្នាយ៉ាងណា ផលទាំងពីរបែបនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ដូច្នេះយើងអាចវិនិច្ឆ័យបានថា បុណ្យងាយធ្វើណាស់, គ្រាន់តែចាក់ទឹកលាងចាន ឬទឹកបាយចោលទៅក្នុងជ្រាំ ឲ្យតែមានចេតនាប្រកបដោយមេត្តាធម៌ថា "សត្វល្អិតល្អួចដែលនៅក្នុងទីជ្រាំនោះ ហើយដែលតែងអាស្រ័យតែកាកសំណល់ដែលគេចោលទៅ, ចូរអាស្រ័យនូវកាកសំណល់ដែលអាត្មាអញចាក់ចោលនេះ ហើយរស់គង់មានជីវិតនៅឲ្យសុខស្រួលតាមសភាពខ្លួនចុះ" ។ តែប៉ុណ្ណឹងក៏បានបុណ្យដែរទៅហើយ មិនចាំបាច់ចំណាយទ្រព្យសម្បត្តិ ប្រាក់កាសកប់រយពាន់ ឬជ្រើសរើសរកអ្នកទទួលតាមយោបល់របស់ខ្លួននោះទេ ប៉ុន្តែសូមកុំភ្លេចថា បុណ្យអស់ទាំងនេះ ភាគច្រើន ច្រើនតែជា វដ្តគាមិ មិនអាចឲ្យឆ្លងវដ្តៈទៅនិព្វានបានឡើយ លុះណាតែបុណ្យដែលគេធ្វើចំពោះទក្ខិណេយ្យបុគ្គលអ្នកមានសីលនិងធម៌ល្អ ទើបជាបុណ្យ វិវដ្តគាមិ បាន ។

# ចុះពិភពលោកយើងនេះ
# កាលចាប់ផ្ដើមកកើតមានឡើងជាដំបូង
# នោះតើដោយអាស្រ័យហេតុអ្វី ?

លោកប៊ូ-ហ៊ួ រៀបរៀង

សំនួរនេះ បើតាមទ្រឹស្ដីសាសនាព្រាហ្មណ៍, ទ្រឹស្ដីសាសនាគ្រិស្ដ និង ទ្រឹស្ដីសាសនាឥស្លាម គេឆ្លើយស្របគ្នាតែម្យ៉ាងថា ពិភពលោកយើងនេះ កាលចាប់ផ្ដើមកកើតមានឡើងជាដំបូង ដោយអាស្រ័យហេតុព្រះព្រហ្ម ឬ ព្រះម្ចាស់សួគ៌ បានកសាងឲ្យកើតមានឡើង មុនដំបូងលោកឲ្យកើតមានដីទឹក ភ្លើង ខ្យល់ បន្ទាប់មកទៀត ឲ្យកើតមានមនុស្ស សត្វ ព្រៃ ភ្នំ និងវត្ថុគ្រប់មុខ នៅលើផែនដី ដែលយើងហៅកាត់ខ្លីថា ‹‹ពិភពលោក›› ។

ចំណែកទ្រឹស្ដីអ្នកវិទ្យាសាស្ត្រសម័យថ្មីឆ្លើយថា ពិភពលោកយើងនេះ ជាផ្ទៃផែនដីមួយដុំ មូលប្រហែលផ្លែក្រូចត្លុង ហើយវិលជុំវិញព្រះអាទិត្យ តែងកើតមាននៅជាប់ជានិច្ចកាល ឥតប្រែប្រួល ឥតរលត់រលាយ បាត់បង់ទៅ ហើយទើបកកើតឡើងជាថ្មីវិញទៀតទេ ។ ឯមនុស្សកើតក្លាយមកពីសត្វស្វា ឬសត្វពោច ។ សត្វទាំងអស់កើតមកពីធាតុដីទឹក ភ្លើង ខ្យល់ និង ធាតុអាកាស ចូលផ្សំត្រូវកម្រិតគ្នាហើយ ទើបកកើតឡើងជាសត្វបាន ។ ស្មៅនិងដើមឈើ ក៏កើតមកពីធាតុចូលផ្សំត្រូវគ្នាដែរ ។

ខាងទ្រឹស្តីពុទ្ធសាសនាវិញ ហើយខុសស្រឡះពីទ្រឹស្តីទាំង ៤យ៉ាង ខាងដើមនេះ ។ ដូច្នេះ ខ្ញុំសូមស្រង់យកព្រះពុទ្ធដីកា ក្នុងអគ្គញ្ញសូត្រ មកពណ៌នាដោយសង្ខេប ដើម្បីជូនអស់លោក ដែលមានវិចារណញ្ញាណ ពិចារណាមើលចុះ តើនឹងគួរជឿស្តាប់ទ្រឹស្តីណា ក្នុងបណ្តាទ្រឹស្តីទាំង ៥ យ៉ាងដូចតទៅនេះ :

## អគ្គញ្ញសូត្រ[១]

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារ-មាតា ( នាងវិសាខា ) ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ វាសេដ្ឋសាមណេរនិងភារទ្វាជសាមណេរ[២]ចង់បួសជាភិក្ខុ ទើបធ្វើតិត្ថិយ-បរិវាស ក្នុងសំណាក់ភិក្ខុទាំងឡាយ ។ វេលាថ្ងៃរសៀល ព្រះពុទ្ធអង្គទ្រង់ចេញចាកទីសម្ងំ ហើយចុះអំពីប្រាសាទទៅបង្ក្រមក្នុងទីវាល ត្រង់ម្លប់ប្រាសាទ ។ ឯវាសេដ្ឋសាមណេរ និង ភារទ្វាជសាមណេរ នាំគ្នាចូលទៅគាល់ព្រះពុទ្ធអង្គ ថ្វាយបង្គំរួចហើយ ដើរតាមក្រោយព្រះអង្គដែល

---

១) ក្នុងសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ( ច្បាប់ព្រះត្រៃបិដកបាលីខ្មែរលេខទី១៨ ) ។ ២) អដ្ឋកថាថា សាមណេរទាំងពីររូបនេះ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាល មានទ្រព្យ ៤០ កោដិផ្លូវគ្នា បានរៀនចេះចប់ត្រៃវេទ បានស្តាប់វាសេដ្ឋសូត្រហើយក៏ដល់សរណគមន៍ លុះស្តាប់តេវិជ្ជសូត្រហើយក៏បួសជាសាមណេរ ដល់ពេលនេះចង់បួសជាភិក្ខុទៀត ទើបនៅតិត្ថិយបរិវាស ។

កំពុងតែចង្រ្កម ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ អ្នកទាំងពីរជាជាតិព្រាហ្មណ៍ ចេញចាកផ្ទះចូលមកកាន់ផ្នួស ចុះពួកព្រាហ្មណ៍ដ៏ប្រសើរ មិនជេរ មិនប្រទេចអ្នកទាំងពីរទេឬ ? ។

វាសេដ្ឋសាមណេរក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ជេរប្រទេចខ្ញុំព្រះអង្គទាំងពីរនាក់ ដោយពាក្យជេរប្រទេចតាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ ។

– ចុះពួកព្រាហ្មណ៍ជេរប្រទេចអ្នក ដោយពាក្យជេរប្រទេចតាមចិត្តគេពេញទី មិនខ្វះកន្ទះនោះតើដូចម្តេច ?

– បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍និយាយថា មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈ(១)ប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថោកទាប មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍មួយទេ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតមកអំពីព្រហ្ម ព្រហ្មបានតាក់តែងមក ជាទាយាទ(២)របស់ព្រហ្ម ឯអ្នកទាំងឡាយនោះ លះបោលវណ្ណៈដ៏ប្រសើរចេញ ហើយត្រឡប់មកកាន់វណ្ណៈថោកទាបវិញ

---

១) ពាក្យថាវណ្ណៈនេះ សំដៅយកពណ៌សំលៀកបំពាក់ជាគ្រឿងសំគាល់ជាតិ ។

២) ញាតិអ្នកទទួលកេរ្តិ៍សំបាច់ ។

គឺត្រឡប់ចូលទៅក្នុងសំណាក់សមណៈត្រងោល ជាគហបតីវណ្ណៈខ្មៅ ជាពួកនៃមារ កើតអំពីព្រះបាទព្រហ្ម ហេតុនោះពុំប្រពៃ ពុំសមគួរឡើយ ៗ

-អេកាសេដ្ឋៈ ពួកព្រាហ្មណ៍របស់អ្នក មិនបានដឹងនូវការកកើតមានឡើងនៃលោកអំពីដើមដំបូងមកទេ ទើបបានជាហ៊ាននិយាយយ៉ាងនេះ ៗ ឯពួកនាងព្រាហ្មណីដែលមានរដូវក្តី មានគភ៌ក្តី កំពុងសម្រាលកូនក្តី កំពុងបំបៅកូនក្តី សឹងប្រាកដដល់ពួកព្រាហ្មណ៍ គឺថាពួកព្រាហ្មណ៍បានឃើញដឹងច្បាស់ទេងផ្លាល់ខ្លួនឯងស្រាប់ហើយ មិនបាច់តថាគតប្រាប់ទេ ឯពួកព្រាហ្មណ៍ទាំងនោះ ក៏សុទ្ធតែកើតមកអំពីយោនីនាងព្រាហ្មណី ប៉ុន្តែបែរជានិយាយថា មានតែពួកព្រាហ្មណ៍ទេ ទើបជាវណ្ណៈប្រសើរបំផុត ៗ ល ៗ ជាទាយាទរបស់ព្រហ្មប៉ុណ្ណោះទៅវិញ ឯព្រាហ្មណ៍ទាំងនោះឈ្មោះថា និយាយបង្អាប់ព្រហ្មផង និយាយកុហកផង រមែងសោយនូវបាបច្រើន ៗ

ម្នាលវាសេដ្ឋៈ វណ្ណៈមាន ៤ ពួកគឺ ខត្តិយៈ ១ ព្រាហ្មណៈ ១ វេស្សៈ ១ សុទ្ទៈ ១ ៗ ខត្តិយៈពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក - ពាក្យញុះញង់ - ពាក្យទ្រគោះ - ពាក្យឥតប្រយោជន៍ មានសេចក្តីលោភ មានចិត្តព្យាបាទ មានសេចក្តីយល់ខុស ក៏មានដែរ ៗ ព្រោះហេតុ

នេះឯង ធម៌ទាំងឡាយឯណាជាអកុសល ក៏កប់ថា ជាអកុសល ដែលមានទោស ក៏កប់ថា មានទោស ដែលមិនគួរសេព ក៏កប់ថា មិនគួរសេព ដែលមិនសមគួរគុណអរិយភាព ក៏កប់ថា មិនសមគួរគុណអរិយភាព ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងនោះតែងប្រាកដក្នុងខត្តិយៈពួកខ្លះ ក្នុងលោកនេះឯង ។ ព្រាហ្មណ៍ខ្លះ ។ បេ ។ វេស្សៈខ្លះ ។ បេ ។ សុទ្ទៈខ្លះ ។ បេ ។ ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងនោះតែងប្រាកដក្នុងសុទ្ទៈពួកខ្លះ ក្នុងលោកនេះឯង ។

ខត្តិយៈពួកខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ មិនមានសេចក្តីលោភ មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ ក៏មានដែរ ។ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាកុសល ក៏កប់ថា ជាកុសល ដែលឥតទោស ក៏កប់ថា ឥតទោស ដែលគួរសេព ក៏កប់ថា គួរសេព ដែលសមគួរគុណអរិយភាព ក៏កប់ថា សមគួរគុណអរិយភាព ជាធម៌ស មានផលស ដែលវិញ្ញូជនតែងសរសើរ ។ ធម៌ទាំងនោះ តែងប្រាកដក្នុងខត្តិយៈពួកខ្លះ ក្នុងលោកនេះឯង ។ ព្រាហ្មណ៍ខ្លះ ។ បេ ។ វេស្សៈខ្លះ ។ បេ ។ សុទ្ទៈខ្លះ ។ បេ ។

ម្នាលវាសេដ្ឋៈ កាលបើវណ្ណៈទាំង ៤ ពួកនេះឯង ប្រព្រឹត្តប្រឡូកប្រឡំគ្នា ក្នុងធម៌ពីរពួក គឺធម៌ខ្មៅនិងធម៌ស ដែលវិញ្ញូជនតែងតិះដៀល

ខ្លះ សរសើរខ្លះ  បើពួកព្រាហ្មណ៍ដែលកំពុងប្រព្រឹត្តក្នុងធម៌ខ្មៅនិងធម៌ស នោះនិយាយថា មានតែពួកព្រាហ្មណ៍មួយទេ ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថោកទាប ។ល។ ជាទាយាទរបស់ព្រហ្មដូច្នេះ ។ វិញ្ញូជនទាំងឡាយមិនយល់ព្រមតាម គឺមិនសរសើរនូវពាក្យរបស់ពួកព្រាហ្មណ៍ទាំងនោះទេ ។ ដំណើរនោះ តើព្រោះហេតុអ្វី ? ព្រោះថា បណ្តាវណ្ណៈទាំង៤ពួកនេះ វណ្ណៈណាជាភិក្ខុឆ្ងាយចាកកិលេស អស់អាសវៈហើយ ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈគឺកិលេសនិងខន្ធដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនតាមលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ វណ្ណៈនោះប្រាកដជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំងនោះដោយធម៌ពិត មិនមែនដោយអធម៌ទេ ។ ព្រោះថា ធម៌ជាគុណប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្នទាំងបរលោក ។

ម្នាលវាសេដ្ឋៈ ព្រះបាទបសេនទិកោសលទ្រង់ជ្រាបថា ព្រះសមណគោតមជាបុគ្គលខ្ពង់ខ្ពស់ ចេញចាកសក្យៈត្រកូលមកទ្រង់ព្រះផ្នួស ។ ប៉ុន្តែអម្បាលពួកសក្យៈគង់ជាចំណុះ ព្រះបាទបសេនទិកោសលមិនមានចន្លោះ(១) ។ ពួកសក្យៈតែងធ្វើសេចក្តីគោរព ថ្វាយបង្គំ

១) អដ្ឋកថាថា ចុះចូលកោតខ្លាចព្រះបាទបសេនទិកោសលដូចជាត្រកូលរបស់ខ្លួន ។

ក្រោកទទួល អញ្ជលិកម្ម និងសាមីចិកម្មឯណា ៗ ចំពោះព្រះបាទបសេនទិកោសល ។ ឯព្រះបាទបសេនទិកោសលក៏ទ្រង់ធ្វើសេចក្តីគោរពថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្មនិងសាមីចិកម្មនោះៗ ចំពោះតថាគតដែរ ដោយទ្រង់ព្រះតម្រិះថា ព្រះសមណគោតម ព្រះអង្គមានជាតិបរិសុទ្ធ អាត្មាអញជាមនុស្សមានជាតិមិនបរិសុទ្ធទេ ព្រះសមណគោតម ព្រះអង្គមានកម្លាំង អាត្មាអញជាមនុស្សមានកម្លាំងថយ ព្រះសមណគោតម ព្រះអង្គមានសម្បុរជ្រះថ្លា អាត្មាអញជាមនុស្សមានសម្បុរសៅហ្មង ព្រះសមណគោតម ព្រះអង្គមានសក្តានុភាពច្រើន អាត្មាអញជាមនុស្សមានសក្តានុភាពតិច ដូច្នេះ តពីនោះមក ទ្រង់ក៏ធ្វើសក្ការៈចំពោះធម៌នោះ ធ្វើសេចក្តីគោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ ។ បើតាមបរិយាយនេះឯង អ្នកគប្បីដឹងថា ធម៌ជាគុណប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្នទាំងបរលោក ។

ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ អ្នកទាំងពីរមានជាតិផ្សេងៗគ្នា មានឈ្មោះផ្សេងៗគ្នា មានគោត្រផ្សេងៗគ្នា មានត្រកូលផ្សេងៗគ្នា ចេញចាកផ្ទះមកកាន់ផ្នួស បើមានគេសួរថា លោកទាំងឡាយជាអ្វី? ដូច្នេះចូរប្រាប់ទៅគេវិញថា យើងជាសមណសក្យបុត្រ ។ បើជនណាមានសទ្ធាគឺការជឿស៊ប់ចុះស៊ប់ហើយ មានឫសដុះតាំងខ្ជាប់មាំមួនក្នុងតថាគត ទោះបីសមណព្រាហ្មណ៍ ទេវតាព្រហ្មក៏នរណាមួយក្នុង

លោក ក៏មិនអាចនឹងបំបែរឲ្យត្រឡប់បានឡើយ ជននោះគួរនិយាយថា ខ្ញុំជាបុត្រជាឱរសនៃព្រះដ៏មានព្រះភាគ កើតមកអំពីព្រះឱស្ឋរបស់ព្រះដ៏មានព្រះភាគ កើតមកអំពីធម៌ ធម៌តាក់តែងមក ជាទាយាទរបស់ធម៌ ៗ ព្រោះហេតុអ្វី បានជាតថាគតថាដូច្នោះ ព្រោះពាក្យថា ធម្មកាយដូច្នេះក្តី ព្រហ្មកាយដូច្នេះក្តី ធម្មភូតដូច្នេះក្តី ព្រហ្មភូតដូច្នេះក្តី ជាឈ្មោះរបស់តថាគត ។

## ពិភពលោកចាប់កកើតឡើងជាដំបូង(១) ។

ម្នាលវាសេដ្ឋៈ មានសម័យដែលលោកនេះត្រូវវិនាសម្តង ៗ ដោយកាលកន្លងទៅជាយូរអង្វែង កាលដែលលោកកំពុងតែវិនាសទៅនោះ មានពួកសត្វបានទៅកើត ក្នុងអាភស្សរព្រហ្មដោយច្រើន ជាអ្នកកើតដោយឈានចិត្ត(២)មានបីតិជាអាហារ(៣) មានរស្មីភ្លឺចេញឯង ត្រាច់ទៅក្នុងអាកាសបាន ស្ថិតនៅក្នុងវិមានដ៏ល្អ នៅអស់កាលជាយូរអង្វែង ។

ម្នាលវាសេដ្ឋៈ មានសម័យដែលលោកនេះត្រូវចម្រើនឡើងម្តង ៗ ដោយកាលកន្លងទៅជាយូរអង្វែង កាលដែលលោកកំពុងតែចម្រើនឡើងនោះ សត្វទាំងឡាយច្យុតចាកអាភស្សរព្រហ្ម មកកាន់ភាពជាមនុស្ស

---

១- ស្រង់កាត់ខ្លីៗតាមលំអានព្រះពុទ្ធដីកាក្នុងអគ្គញ្ញសូត្រ ។ ២ អដ្ឋកថាថា ក្នុងបឋមកប្ប ពួកសត្វទាំងនោះ សូម្បីមកកើតក្នុងមនុស្សនេះ ក៏គង់កើតជាឱបបាតិកៈកំណើតដែរ គឺកើតតាមចិត្ត ។ ៣ សត្វទាំងនោះ មានបីតិជាអាហារ ក្នុងមនុស្សលោកនេះ ដូចព្រហ្មក្នុងព្រហ្មលោកនោះដែរ ។

នេះ ឯសត្វទាំងនោះជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯង ត្រាច់ទៅក្នុងអាកាសបាន ស្ថិតនៅក្នុងវិមានដ៏ល្អ នៅអស់កាលជាយូរអង្វែង ។

ម្នាលវាសេដ្ឋៈ សម័យនោះ ចក្រវាឡទាំងអស់ក៏រលាយទៅជាទឹកចូលគ្នា មានងងឹតអាប់សូន្យសុង ព្រះចន្ទនិងព្រះអាទិត្យក៏មិនប្រាកដ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយក៏មិនប្រាកដ យប់និងថ្ងៃក៏មិនប្រាកដ ខែមួយនិងកន្លះខែក៏មិនប្រាកដ រដូវនិងឆ្នាំក៏មិនប្រាកដ ស្រីនិងប្រុសក៏មិនប្រាកដ ។ សត្វទាំងឡាយក៏គ្រាន់តែរាប់ថាជាសត្វប៉ុណ្ណោះឯង ។

ម្នាលវាសេដ្ឋៈ លុះកាលកន្លងទៅអង្វែងម្តងៗ ផែនដីមានរសអណ្តែតដាសលើទឹកសម្រាប់សត្វទាំងនោះ ប្រាកដដូចជាទឹកដោះក្តៅរលាយអណ្តែតដាសនៅលើទឹកដូច្នោះ ផែនដីមានរសនោះ មានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែម មានសម្បុរសដូចទឹកដោះថ្លាឬដូចទឹកដោះខាប់ដែលមានរសផ្អែម ផែនដីនោះទុះ មានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំដែលមានកូនឃ្មុំ ជាទឹកឥតមានទោស ។ គ្រានោះ មានសត្វម្នាក់មានជាតិជាអ្នកលេះលោះគិតថា យីអើ នេះជាអ្វីអេះ ក៏យកចង្អុលដៃត្រួះយកផែនដីមានរសមកលិទ្ធភ្លក់មើល រសផែនដីក៏ជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលនូវរស ឯសេចក្តីប្រាថ្នាក្នុងរស ក៏កើត

ដល់សត្វនោះ ៗ មានពួកសត្វដទៃទៀត កាលយកតម្រាប់តាមសត្វនោះ នាំគ្នាយកចង្អុលដៃគ្រឹះយកផែនដីមានរសមកលិទ្ធភ្លក់មើល រសផែនដីក៏ជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលនូវរស ឯសេចក្ដីប្រាថ្នាក្នុងរស ក៏កើតឡើងដល់ពួកសត្វទាំងនោះ ៗ នាំគ្នាយកដៃកកាយផែនដីមានរសមកធ្វើជាដុំទូតហើយបរិភោគ ពន្លឺដែលភ្លឺចេញឯងអំពីកាយរបស់សត្វទាំងនោះក៏សាបសូន្យបាត់ទៅ ព្រះចន្ទនិងព្រះអាទិត្យក៏កើតប្រាកដឡើង នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយក៏កើតប្រាកដឡើង យប់និងថ្ងៃក៏កើតប្រាកដឡើង ខែមួយនិងកន្លះខែក៏កើតប្រាកដឡើង រដូវនិងឆ្នាំក៏កើតប្រាកដឡើង ៗ លោកនេះចម្រើនឡើងវិញដោយហេតុប៉ុណ្ណេះឯង ៗ

ម្នាលវាសេដ្ឋៈ កាលពួកសត្វទាំងនោះនាំគ្នាបរិភោគផែនដីមានរសជាចំណីអាហារហើយ ស្ថិតនៅអស់កាលយូរអង្វែង សេចក្ដីរឹងប៉ុងក្នុងកាយរបស់សត្វទាំងនោះក៏កើតឡើង ទាំងពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង ៗ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ៗ ពួកសត្វមានសម្បុរល្អតែងមើលងាយពួកសត្វមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អលើសជាងពួកសត្វនុះ ៗ មានសម្បុរអាក្រក់ជាងពួកយើង ៗ កាលសត្វទាំងនោះ មានសេចក្ដីប្រកាន់ខ្លួននិងការមើលងាយកើតឡើង ព្រោះបច្ច័យនៃសេចក្ដីមើលងាយនូវសម្បុរគ្នា ផែនដីមាន

រសក៏សាបសូន្យអស់ទៅ ។ សត្វទាំងឡាយក៏ប្រជុំគ្នាហើយត្អូញត្អែរថា ឱ!រសឆ្ងាញ់របស់យើង ឱ!រសឆ្ងាញ់របស់យើង ។ ហេតុនោះក៏ដូចគ្នានឹងមនុស្សទាំងឡាយក្នុងកាលឥឡូវនេះដែរ កាលដែលបានវត្ថុអ្វីមួយមានរសឆ្ងាញ់ហើយតែងនាំគ្នាលាន់មាត់ថា ឱ!រសឆ្ងាញ់របស់យើង ឱ!រសឆ្ងាញ់របស់យើង ។ សត្វទាំងឡាយនាំគ្នានឹករកអក្ខរៈដែលជាច្បាប់ចាស់ (១) នោះឯង ប៉ុន្តែមិនអាចដឹងយល់សេចក្តីនៃអក្ខរៈនោះបានឡើយ ។

ម្នាលវាសេដ្ឋៈ លុះផែនដីមានរសរបស់សត្វទាំងនោះសាបសូន្យអស់ទៅហើយ ក្រមរផែនដីក៏កើតប្រាកដឡើង ។ ក្រមរផែនដីនោះដូចជាផ្សិតក្បាលពស់ បរិបូណ៌ដោយសម្បុរ មានក្លិនក្រអូប មានរសឆ្ងាញ់ មានពណ៌ដូចជាសប្បិសុទ្ធ ឬដូចជានវនីតសុទ្ធ មានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំដែលមានក្លិនឃ្មុំ ជាទឹកឥតមានទោស ។ សត្វទាំងនោះ ក៏នាំគ្នាបរិភោគក្រមរផែនដីជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ។ សេចក្តីរឹងប៉ឹងក្នុងកាយរបស់ពួកសត្វទាំងនោះ ក៏កើតដោយក្រៃលែងលើសប្រមាណ ពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង ។ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ។ ពួកសត្វមានសម្បុរល្អមើលងាយពួកសត្វមានសម្បុរអាក្រក់ថា ពួកយើង

១) អដ្ឋកថាថា បាទនឹងសំដីជាវង្សដែលកើតឡើងសម្រាប់លោក ។

មានសម្បុរល្អជាងពួកសត្វខ្លះ ពួកសត្វទាំងខ្លះមានសម្បុរអាក្រក់ជាងពួកយើង ។

ម្នាលវាសេដ្ឋៈ កាលសត្វទាំងនោះមានសេចក្តីប្រកាន់ខ្លួននិងមើលងាយកើតឡើង ព្រោះសេចក្តីមើលងាយនូវសម្បុរគ្នាជាបច្ច័យ ក្រមរផែនដីមានរសក៏សាបសូន្យអស់ទៅ បទាលតា(១)ក៏កើតប្រាកដឡើង ។ បទាលតានោះកើតប្រាកដឡើងដូចជាវល្លិត្រកួន មានសម្បុរល្អមានក្លិនក្រអូប មានរសឆ្ងាញ់ មានសម្បុរដូចជាសប្បិសុទ្ធឬដូចជានវនីតសុទ្ធ មានរសឆ្ងាញ់ពិសាដូចទឹកឃ្មុំដែលមានក្លិនឃ្មុំ ជាទឹកឥតមានទោស ។ សត្វទាំងនោះក៏នាំគ្នាបរិភោគបទាលតាជាចំណីអាហារស្ថិតនៅអស់កាលយូរអង្វែង ។ សេចក្តីរឹងប៉ឹងក្នុងកាយរបស់សត្វទាំងនោះ ក៏កើតឡើងដោយក្រៃលែងលើសប្រមាណ ទាំងពណ៌សម្បុរប្លែក ៗ គ្នា ខ្លះល្អ ខ្លះអាក្រក់ ទើបកើតចិត្តប្រកាន់ខ្លួននិងមើលងាយគ្នាដូចន័យខាងដើម ។ ព្រោះចិត្តមើលងាយសម្បុរគ្នាជាបច្ច័យ បទាលតាក៏សាបសូន្យអស់ទៅ ។ សត្វទាំងនោះមកប្រជុំគ្នាត្អូញត្អែរថា ឱហ្ន៎បទាលតារបស់យើងធ្លាប់មានហើយ ឱហ្ន៎ បទាលតារបស់យើងបាត់អស់ទៅហើយ ។ ហេតុនោះក៏ដូចគ្នានឹងមនុស្សទាំងឡាយក្នុងកាលឥឡូវនេះដែរ ដែលធម៌ជាទុក្ខណាមួយប៉ះពាល់ ក៏និយាយគ្នាថា ឱហ្ន៎ យើង

១) អដ្ឋកថាថា ជាឈ្មោះវល្លិមួយយ៉ាងមានរសផ្អែម ។

ធ្លាប់មាន ទុក្ខ យើងសាបសូន្យអស់ហើយ ។ សត្វទាំងឡាយនាំគ្នានឹករកអក្សរដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្សរនោះបានឡើយ ។

ម្នាលវាសេដ្ឋៈ កាលបើពាលតាសាបសូន្យអស់ទៅហើយ ស្រូវសាលីដុះឯង ជាស្រូវគ្មានកន្ទក់ គ្មានអង្កាម សស្អាតមានក្លិនក្រអូប មានផ្លែចេញមកជាអង្ករតែម្តងក៏កើតប្រាកដឡើង ។ មនុស្សទាំងឡាយនាំយកស្រូវសាលីត្រង់ទីណាក្នុងវេលាល្ងាច សំរាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ មនុស្សទាំងឡាយនាំយកស្រូវសាលីត្រង់ទីណាក្នុងវេលាព្រឹក សំរាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដហាក់ដូចជាមិនបានច្រូតឡើយ ។ សត្វទាំងឡាយ ក៏បរិភោគស្រូវសាលីដុះឯងជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ។ សេចក្តីរឹងប៉ឹងក្នុងកាយរបស់ពួកសត្វទាំងនោះក៏កើតឡើងលើសប្រមាណ ទាំងពណ៌សម្បុរក៏ប្លែកៗគ្នាប្រាកដឡើង ។ ភេទស្រីក៏ប្រាកដឡើងដល់ស្រី ភេទប្រុសក៏ប្រាកដឡើងដល់ប្រុស ។ បានឮថា ស្រីសម្លឹងមើលប្រុសទាល់តែហួសវេលា ចំណែកខាងប្រុសក៏សំឡឹងមើលស្រីវិញទាល់តែហួសវេលាដែរ ។ កាលសត្វទាំងនោះសំឡឹងមើលគ្នាទៅវិញទៅមកទាល់តែហួសវេលា តម្រេកក៏កើតឡើង

សេចក្តីក្តៅក្រហាយព្រោះតម្រេកក៏ប្រជុំចុះក្នុងកាយ ។ សត្វទាំងនោះក៏នាំគ្នាសេពមេថុនធម្ម ព្រោះសេចក្តីពេលកលជាបច្ច័យ ។ ពួកសត្វណាបានឃើញនូវពួកសត្វដែលកំពុងតែសេពមេថុនធម្ម ពួកសត្វខ្លះក៏យកអាចម៍ដីបោះទៅ សត្វខ្លះយកផេះបាចផាត់ សត្វខ្លះយកអាចម៍គោបោះទៅ និយាយថា នែសលិ[1]លាញទៅ នែសលិលាញទៅ ហង់លាញទៅ ៗ ចុះហេតុម្តេច បានជាសត្វហ៊ានធ្វើអំពើដល់សត្វយ៉ាងនេះ ៗ ហេតុនោះក៏ដូចគ្នានឹងពួកមនុស្សក្នុងកាលឥឡូវនេះដែរ កាលបើស្រីក្នុងជនបទទីមួយមានគេចាប់នាំយកទៅ ពួកខ្លះក៏យកអាចម៍ដីបោះទៅ ពួកខ្លះក៏យកផេះបាចផាត់ ពួកខ្លះក៏យកអាចម៍គោបោះទៅ ៗ សត្វទាំងឡាយនាំគ្នានឹករកអក្សរដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែ មិនអាចនឹងយល់សេចក្តីនៃអក្សរនោះបានឡើយ ៗ

ម្នាលវាសេដ្ឋៈ សម័យនោះឯង អំពើមានការបោះអាចម៍ដីជាដើមនោះ គេសន្មតថា មិនមែនធម៌ តែអំពើនោះក្នុងកាលឥឡូវនេះ គេត្រឡប់សន្មតថាជាធម៌វិញ ៗ សម័យនោះ បើពួកសត្វណាសេពមេថុនធម្ម សត្វទាំងនោះមិនហ៊ានចូលមកកាន់ស្រុកឬនិគម អស់មួយខែក៏មាន ពីរខែក៏មាន ៗ កាលណាបើពួកសត្វទាំងនោះដល់ស៊ប់នូវភាពជាអ្នកសេពចំពោះអសទ្ធម្មនោះហួសវេលាហើយ ក៏នាំគ្នាផ្តើមធ្វើផ្ទះដើម្បីបិទបាំងអសទ្ធម្មនោះឯង ៗ

---

១) ជាពាក្យអាសគ្រាម សម្រាប់ជេរបញ្ចោរ ។

ម្នាលព្រាហ្មណ៍ គ្រានោះឯង មានសត្វម្នាក់ប្រកបដោយជាតិជាអ្នកខ្ជិលច្រអូសបានគិតថា យីអើ អាត្មាអញ កាលដែលនាំយកស្រូវសាលីក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច នាំយកស្រូវសាលីក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក ហៅពេញជាលំបាកខ្លួនអ្វីម្ល៉េះ ណ្ហើយចុះ អាត្មាអញគួរតែនាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្ដងហើយទុកបរិភោគក្នុងវេលាព្រឹកផង ។ សត្វនោះក៏ទៅយកស្រូវសាលីក្នុងវេលាល្ងាចតែម្ដងប៉ុណ្ណោះ សម្រាប់បរិភោគក្នុងវេលាព្រឹកផង ។ មានសត្វម្នាក់ចូលទៅរកសត្វនោះ បាននិយាយបបួលសត្វនោះថា នែសត្វដ៏ចម្រើន អ្នកចូរមក យើងនឹងទៅនាំយកស្រូវសាលីជាអាហារ ។ សត្វនោះឆ្លើយថា នែសត្វដ៏ចម្រើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្ដង ហើយទុកបរិភោគក្នុងវេលាព្រឹកផង ។ ទើបសត្វនោះ បានយកតម្រាប់តាមសត្វនោះ ក៏ទៅនាំយកស្រូវសាលីមកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលីមកតែម្ដងប៉ុណ្ណោះ សម្រាប់បរិភោគបានពីរថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ មានសត្វម្នាក់ទៀតចូលទៅរកសត្វនោះ បាននិយាយបបួលសត្វនោះទៅនាំយកស្រូវសាលីជាអាហារ ។ សត្វនោះឆ្លើយថា ខ្ញុំបាននាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្ដង ហើយទុកបរិភោគវេលាព្រឹកផង ។ ទើបសត្វនោះយកតម្រាប់តាម ។ បេ ។ នាំយកស្រូវសាលីតែម្ដង ហើយទុក

ទុកបរិភោគបានបួនថ្ងៃ ។បេ។ មានសត្វម្នាក់ទៀតយកតម្រាប់តាម។បេ។ ទាំយកស្រូវសាលីតែម្តង ហើយទុកបរិភោគបាន ៨ ថ្ងៃ ។ លុះពួកសត្វទាំងនោះបាននាំគ្នាផ្តើមបរិភោគស្រូវសាលី ដែលខ្លួនសន្សំទុកក្នុងកាលឯណាហើយ កាលនោះឯង គន្ទក់ក៏រុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ សូម្បីកន្លែងដែលគេច្រូតហើយ ក៏លែងដុះឡើងវិញ ប្រាកដជាពេញដូចដើម ស្រូវសាលីទាំងឡាយក៏ដុះមួយគុម្ព ៗ ហាក់ដូចគេចងជាបាច់ ។

ម្នាលវាសេដ្ឋៈ គ្រានោះ ពួកសត្វទាំងនោះមកប្រជុំគ្នាត្អូញត្អែរថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ទុហ្ន ធម៌ដ៏លាមកទាំងឡាយបានកើតប្រាកដក្នុងពួកសត្វហើយ ព្រោះកាលពីដើម ពួកយើងជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯងអំពីកាយ ត្រាច់ទៅក្នុងអាកាសបាន ស្ថិតនៅក្នុងទីដ៏ល្អ បានស្ថិតនៅអស់កាលយូរអង្វែង លុះកាលកន្លងយូរអង្វែងទៅផែនដីមានរស ក៏អណ្តែតជាសលើទឹកសំរាប់ពួកយើង ឯផែនដ់នោះមានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែម ពួកយើងនាំគ្នាយកដៃកកាយផែនដី មានរសមកពូតជាពំនូត ហើយបរិភោគ កាលពួកយើងបរិភោគផែនដីមានរសនោះ ពន្លឺភ្លឺចេញឯងអំពីកាយក៏បាត់ទៅ ព្រះចន្ទនិងព្រះអាទិត្យកើតឡើង នក្ខត្តឫក្សមានរូបជាផ្កាយកើតឡើយ យប់និងថ្ងៃកើតឡើង ខែមួយនិងកន្លះខែកើតឡើង រដូវ

នឹងឆ្ងាំកើតឡើង កាលពួកយើងបរិភោគផែនដីមានរសជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែផែនដីមានរសបាត់ទៅ ព្រោះហេតុនៃអកុសលធម៌ទាំងឡាយដ៏លាមកកើតដល់ពួកយើង លុះផែនដីមានរសបាត់ទៅហើយ ក្រមរផែនដីមានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែមកើតឡើង ពួកយើងនាំគ្នាផ្ដើមបរិភោគក្រមរផែនដីនោះជាចំណីអាហារស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែក្រមរផែនដីនោះបាត់ទៅ ព្រោះហេតុនៃអកុសលធម៌ដ៏លាមកកើតដល់ពួកយើង លុះក្រមរផែនដីបាត់ទៅហើយ បទាលតាមានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែមកើតឡើង ពួកយើងនាំគ្នាផ្ដើមបរិភោគបទាលតាជាចំណីអាហារ ស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែបទាលតានោះបាត់ទៅ ព្រោះហេតុនៃអកុសលធម៌ដ៏លាមកកើតដល់ពួកយើង លុះបទាលតានោះបាត់ទៅហើយ ទើបស្រូវសាលីដុះឯង ឥតកន្ទក់ ឥតអង្កាម ជាស្រូវសស្អាត មានក្លិនក្រអូប មានផ្លែចេញមកជាអង្ករកើតឡើង ពួកយើងនាំយកស្រូវសាលីត្រង់ទីណាក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងក្នុងទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ពួកយើងនាំយកស្រូវសាលីត្រង់ទីណាមកក្នុងវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះប្រាកដហាក់ដូចជាមិនបានច្រូតឡើយ

កាលពួកយើងបរិភោគស្រូវសាលីឆ្អិនឯង ជាចំណីអាហារស្ថិតនៅអស់កាលយូរអង្វែង ស្រាប់តែកន្ទក់រុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ សូម្បីទីដែលច្រូតក៏មិនដុះឡើងវិញពេញដូចដើម ស្រូវសាលីទាំងឡាយដុះមួយគុម្ព ៗ ហាក់ដូចគេចងជាបាច់ ព្រោះហេតុនៃអកុសលធម៌ទាំងឡាយដ៏លាមកកើតដល់យើង បើដូច្នោះគួរតែយើងចែកស្រូវសាលីគ្នា គួរតែបោះព្រំខណ្ឌ ៗ សត្វទាំងឡាយក៏នាំគ្នាចែកស្រូវសាលី បោះព្រំខ័ណ្ឌដោយខ្លួន ៗ ៗ

ម្នាលវាសេដ្ឋៈ គ្រានោះ មានសត្វម្នាក់ជាតិជាអ្នកលេះលោះលាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃដែលគេមិនបានឲ្យមកបរិភោគ ៗ សត្វទាំងឡាយក៏ចាប់សត្វនោះបានហើយស្តីឲ្យថា ឱសត្វអើយ ឯងធ្វើអំពើអាក្រក់ណាស់ មិនគួរបើឯងលាក់សំ·ចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់គេមកបរិភោគសោះ នែសត្វអើយ ឯងកុំធ្វើអំពើបែបនេះទៀតឡើយ ៗ សត្វនោះបានលួចយកចំណែករបស់គេជាគំរប់ពីរដងផង ៗ ជាគំរប់បីដងផង ៗ សត្វទាំងឡាយចាប់សត្វនោះបាន ហើយក៏ស្តីបន្ទោសហាមប្រាមដូចន័យខាងដើម ៗ ពួកសត្វខ្លះគប់ទះសត្វនោះនឹងដៃ ពួកសត្វខ្លះបោលនឹងដុំដី ពួកសត្វខ្លះវាយនឹងដំបង ៗ

ម្នាលវាសេដ្ឋៈ ការលួចទ្រព្យក៏កើតប្រាកដឡើង ការតិះដៀល

គ្នាក៏កើតប្រាកដឡើង ការនិយាយកុហកក៏កើតប្រាកដឡើង ការដាក់អាជ្ញា (ធ្វើទោស) ក៏កើតប្រាកដឡើង តាំងពីកាលនោះជាដើមមកៗ គ្រានោះ ពួកសត្វមកប្រជុំគ្នាហើយត្អូញត្អែរថា យីអើហ្ន៎ ធម៌ដ៏លាមកទាំងឡាយកើតប្រាកដដល់សត្វទាំងឡាយហើយ ព្រោះថាការលួចទ្រព្យគេក៏កើតប្រាកដឡើង ។បេ។ ការដាក់អាជ្ញាក៏កើតប្រាកដឡើង បើដូច្នោះ គួរតែពួកយើងសន្មតសត្វម្នាក់ឲ្យជាអ្នកបន្ទោសសត្វដែលគួរនឹងបន្ទោសតាមហេតុ ឲ្យតិះដៀលសត្វដែលគួរនឹងតិះដៀលតាមហេតុ ឲ្យបណ្ដេញសត្វដែលគួរនឹងបណ្ដេញតាមហេតុ ឲ្យដល់ពួកយើង ចំណែកខាងពួកយើង ត្រូវជូនចំណែកស្រូវសាលីទាំងឡាយឲ្យដល់សត្វនោះៗ ទើបពួកសត្វទាំងនោះ នាំគ្នាចូលទៅរកសត្វដែលជាអ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លាមានសក្តិធំ(១)ជាងពួកសត្វទាំងនោះ លុះចូលទៅដល់ហើយបាននិយាយថា បពិត្រសត្វដ៏ចំរើន អ្នកចូរមកបន្ទោសសត្វដែលគួរបន្ទោសតាមហេតុ ចូរតិះដៀលសត្វដែលគួរតិះដៀលតាមហេតុ ចូរបណ្ដេញសត្វដែលគួរបណ្ដេញតាមហេតុចុះ សឹមពួកយើងនឹងជូនចំណែកស្រូវសាលីទាំងឡាយដល់អ្នក ។ សត្វនោះក៏ទទួលយល់ព្រមធ្វើតាមពាក្យរបស់សត្វទាំងនោះ ។

ម្នាលវាសេដ្ឋៈ សត្វនោះមហាជនសន្មតហើយ ព្រោះហេតុនោះ

---

១-(អដ្ឋកថា) គឺព្រះបរមពោធិសត្វនៃយើង ។

ទើបអក្ខរៈ(១)ជាដំបូងកើតឡើងថា មហាសម្មតៈ ដូច្នេះ ។ សត្វនោះជាអធិបតីនៃស្រែទាំងឡាយ ព្រោះហេតុនោះ ទើបអក្ខរៈទី២កើតឡើងថា ខត្តិយៈ ខត្តិយៈ ដូច្នេះ ។ សត្វនោះញ៉ាំងសត្វទាំងឡាយដទៃឲ្យពេញចិត្តដោយធម៌ ព្រោះហេតុនោះ ទើបអក្ខរៈទី ៣ កើតឡើងថា រាជា រាជា ដូច្នេះ ។ ហេតុដូច្នោះ អក្ខរៈដែលជាច្បាប់ចាស់បាន កើតឡើងដល់ខត្តិយមណ្ឌលនោះយ៉ាងនេះ ។ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះ ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងតែដោយធម៌ប៉ុណ្ណោះឯង មិនមែនដោយខុសធម៌ទេ ។ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក ។

បណ្ដាសត្វទាំងនោះ សត្វពួកខ្លះគិតគ្នាថា មាលអកុសលធម៌ចម្រើនទាំងឡាយ ធម៌ដ៏លាមកទាំងឡាយកើតប្រាកដដល់ពួកសត្វហើយ ព្រោះថា ការលួចទ្រព្យគេ ពាក្យតិះដៀលគ្នា ការនិយាយកុហក ការដាក់អាជ្ញា ការបណ្ដេញក៏កើតមានប្រាកដឡើង បើដូច្នោះ ពួកយើងគួរតែបន្សាត់នូវធម៌ជាអកុសលដ៏លាមកទាំងឡាយចេញ ។ ពួកសត្វទាំងនោះក៏បានបន្សាត់នូវធម៌ជាអកុសលដ៏លាមកចេញ ព្រោះហេតុ

---

១- អក្ខរកថាថា បានដល់ពាក្យសម្រាប់កំណត់ សម្រាប់ចេញឈ្មោះ សម្រាប់បញ្ញត្តិ សម្រាប់និយាយ ។

នោះ ទើបអក្ខរៈទី ១ កើតឡើងថា ព្រាហ្មណៈ ព្រាហ្មណៈ ដូច្នេះ ។ សត្វទាំងនោះបានធ្វើដំរំស្លឹកក្នុងព្រៃរលោង ហើយសំឡឹងអារម្មណ៍ក្នុងដំរំប្រក់ស្លឹកទាំងឡាយ ។ ពួកសត្វទាំងនោះឥតភ្លើងផ្សែងទេ ឥតអង្រែទេ ត្រាច់ទៅកាន់ស្រុកនិគមនិងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាចសម្រាប់បរិភោគក្នុងវេលាល្ងាច ស្វែងរកក្នុងវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក ។ ពួកសត្វទាំងនោះ លុះបានអាហារហើយ ក៏នៅសំឡឹងអារម្មណ៍ក្នុងដំរំស្លឹកទាំងឡាយ ក្នុងព្រៃរលោងទៀត ។ មនុស្សទាំងឡាយ លុះបានឃើញសត្វទាំងនោះហើយ ក៏និយាយគ្នាថា នែគ្នាយើងអើយ ពួកសត្វទាំងនេះធ្វើដំរំស្លឹកក្នុងព្រៃរលោងហើយនៅសំឡឹងអារម្មណ៍ក្នុងដំរំស្លឹក ជាសត្វឥតភ្លើងផ្សែង ឥតអង្រែ តែងត្រាច់ទៅកាន់ស្រុកនិគមនិងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាចសម្រាប់វេលាល្ងាច ស្វែងរកក្នុងវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក ។ ពួកសត្វទាំងនោះលុះបានអាហារហើយ ក៏សំឡឹងអារម្មណ៍ក្នុងដំរំស្លឹកក្នុងព្រៃរលោងទៀត ។ ព្រោះហេតុនោះ ទើបអក្ខរៈទី២កើតឡើងថា ឈាយិកា ឈាយិកា (អ្នកសំឡឹងអារម្មណ៍) ។ បណ្ដាសត្វទាំងនោះ សត្វពួកខ្លះកាលមិនអាចនឹងសំឡឹងអារម្មណ៍ក្នុងដំរំស្លឹកក្នុងព្រៃរលោងបាន ក៏ចូលទៅកាន់ស្រុកជិត និគមជិត តាក់តែងបង្រៀនទូវគន្ថៈ គឺវេទមន្តរួចត្រឡប់មកវិញ ។ ពួកមនុស្សលុះបាន

ឃើញសត្វទាំងនោះហើយនិយាយគ្នាថា ម្នាលគ្នាយើងអើយ ពួកសត្វទាំងនេះមិនអាចទឹងសំឡឹងអារម្មណ៍ ៗ បេ ៗ រួបត្រឡប់មកវិញ ៗ ព្រោះហេតុនោះ ទើបអក្ខរៈទាំងកើតឡើងថា អជ្ឈាយិកា អជ្ឈាយិកា ( អ្នកមិនសំឡឹងអារម្មណ៍ ) ៗ ក្នុងសម័យនោះ ការទ្រទ្រង់និងការបង្រៀនទូវមន្ត គេសន្មតថាជាការថោកទាបទេ តែក្នុងកាលឥឡូវនេះ ការទ្រទ្រង់និងការបង្រៀនទូវមន្តនោះ គេសន្មតថាជាការប្រសើរវិញ ៗ ហេតុដូច្នោះ អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់ព្រាហ្មណ-មណ្ឌលនោះយ៉ាងនេះ ៗ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះ ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែម្យ៉ាងប៉ុណ្ណោះ មិនមែនដោយខុសធម៌ទេ ៗ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក ៗ

ម្នាលវាសេដ្ឋៈ បណ្តាសត្វទាំងនោះ សត្វពួកខ្លះប្រព្រឹត្តកាន់នូវមេថុនធម្មហើយប្រកបការងារផ្សេង ៗ គ្នា ៗ ព្រោះហេតុនេះ អក្ខរៈទើបកើតឡើងថា វេស្សៈ វេស្សៈ ដូច្នេះ ៗ ការកើតអក្ខរៈជាច្បាប់ចាស់ក៏មានឡើងដល់វេស្សមណ្ឌលនុ៎ះយ៉ាងនេះ ៗ សេចក្តីសង្ខេប ៗ

ម្នាលវាសេដ្ឋៈ អក្ខរៈជាច្បាប់ចាស់បានកើតឡើងដល់សុទ្ទមណ្ឌលនោះយ៉ាងនេះ ការកើតអក្ខរៈដល់ពួកសត្វទាំងនោះ ដូចគ្នានឹងសត្វ

តាំងឡាយដទៃដែរ ។ បេ ។ ព្រោះថាធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន តាំងពីបច្ចុប្បន្ន តាំងពីបរលោក ។

ម្នាលវាសេដ្ឋៈ មានសម័យដែលខត្តិយៈខ្លះតិះដៀលធម៌របស់ខ្លួន ហើយចេញចាកផ្ទះចូលមកបួសដោយបំណងថា អាត្មាអញនឹងធ្វើជាសមណៈ ដូច្នេះក៏មាន ។ ព្រាហ្មណ៍ខ្លះ ។ បេ ។ វេស្សៈខ្លះ ។ បេ ។ សុទ្ទៈខ្លះ ។ បេ ។

ម្នាលវាសេដ្ឋៈ ការកើតឡើងនៃសមណមណ្ឌល ក៏បានមានឡើងដោយសារមណ្ឌលតាំង ៤ នេះឯង ការកើតឡើងនៃសមណមណ្ឌលដល់សត្វតាំងនោះ ដូចគ្នានឹងសត្វតាំងឡាយដទៃដែរ ។ បេ ។ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន តាំងពីបច្ចុប្បន្ន តាំងពីបរលោក។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ លុះស្លាប់ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ មានព្រាហ្មណ៍ខ្លះ ។ បេ ។ មានវេស្សៈខ្លះ ។ បេ ។ មានសុទ្ទៈខ្លះ ។ បេ ។ មានសមណៈខ្លះប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ។ បេ ។ អសុរកាយ នរក ។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះប្រព្រឹត្តល្អដោយកាយវាចាចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ លុះស្លាប់ក៏ទៅកើតក្នុងសុគតិសួគ៌

ទេវលោក ។ មានព្រាហ្មណ៍ខ្លះ ។ បេ ។ មានវេស្សៈខ្លះ ។ បេ ។ មានសុទ្ទៈខ្លះ ។ បេ ។ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះជាអ្នកធ្វើអំពើទាំងពីរ គឺជួនកាលធ្វើអំពើអាក្រក់ ជួនកាលធ្វើអំពើល្អដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិច្រឡំគ្នាផ្សេងៗ ប្រកាន់នូវកម្មផលច្រឡំគ្នាផ្សេងៗ លុះស្លាប់ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។ មានព្រាហ្មណ៍ខ្លះ ។ បេ ។ មានវេស្សៈខ្លះ ។ បេ ។ មានសុទ្ទៈខ្លះ ។ បេ ។ មានសមណៈខ្លះ ។ បេ ។ លុះស្លាប់ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។

ម្នាលវាសេដ្ឋៈ មានខត្តិយៈខ្លះ ជាអ្នកសង្រួមដោយកាយវាចាចិត្ត អាស្រ័យនូវការចម្រើនពោធិបក្ខិយធម៌ ៧ កង(១) ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះ ។ មានព្រាហ្មណ៍ខ្លះ ។ បេ ។ មានវេស្សៈខ្លះ ។ បេ ។ មានសុទ្ទៈខ្លះ ។ បេ ។

ម្នាលវាសេដ្ឋៈ បណ្តាវណ្ណៈទាំង ៤ នេះ វណ្ណៈណាជាភិក្ខុ ជាអរហន្ត ជាខីណាស្រព ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួន

---

១) ពោធិបក្ខិយធម៌ ៧ កង រាប់យកសតិបដ្ឋាន ៤ ជាកង ១ រហូតដល់អដ្ឋង្គិកមគ្គជាកងទីបំផុត ។

ដោយលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ អ្នកនោះប្រាកដថាជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំង ៤ នោះ តាមធម៌ពិត មិនមែនមិនតាមធម៌ទេ ។ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន ទាំងបរលោក ។ សូម្បីព្រហ្មឈ្មោះសនង្កុមារ ក៏បានពោលគាថាទុកថា :

ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេតិ ។

ខត្តិយៈ ជាជាតិប្រសើរបំផុតក្នុងប្រជុំជន ជាអ្នកដែលរឭកដល់គោត្រ អ្នកដែលបរិបូណ៌ដោយវិជ្ជានិងចរណៈប្រសើរបំផុតក្នុងពួកទេវតានិងមនុស្ស ។

ម្នាលវាសេដ្ឋៈ ឯគាថានេះឯង ព្រហ្មឈ្មោះសនង្កុមារ បានពោលពិតហើយ មិនមែនពោលមិនពិតទេ បានសំដែងល្អហើយ មិនមែនសំដែងមិនល្អទេ ជាគាថាប្រកបដោយប្រយោជន៍ មិនមែនជាមិនប្រកប

ដោយប្រយោជន៍ឡើយ តថាគត ក៏យល់ព្រមតាមដែរ ។ ចំណែកតថាគត ក៏បានពោលគាថា ដូចគ្នានឹងគាថារបស់សនង្កុមារព្រហ្មនោះរួចហើយដែរ ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ វាសេដ្ឋសាមណេរនិងភារទ្វាជសាមណេរ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់អគ្គញ្ញសូត្រ

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

## វិបត្តានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង ខាត់ រៀបរៀង*

**អនុគ្រហណ** នបុំ. កិរិយាអនុគ្រោះ ។

**អនុគ្រហិត** គុ. ដែលកាន់កាប់ ។

**អនុគ្រាហ្យ** គុ. ដែលគប្បីអនុគ្រោះ ។ -ហ្យា ស្ត្រី. ភាវៈនៃបុគ្គល គប្បីអនុគ្រោះ ។

**អនុឃដ្ដន** នបុំ. កិរិយាគុ, ការបន្ត (រឿង) ។

**អនុប្រោ** ធាតុ. ហិត ។

**អនុចរ** ធាតុ. ប្រព្រឹត្តរឿយៗ, តាម, តាមរក, ។ **អនុចរិត** នបុំ. អនុចរិត, ព្រឹត្តិការណ៍

អនុចរ គុ. ដែលតាម, ។ បុំ. អ្នកតាម, អ្នកជួយ, អ្នកបំរើ, ។ ពហុ.

បរិវារ, អ្នកហែហម ។

អនុចិត គុ. (អន៍+ឧចិត) ដែលមិនគួរ, ដែលមិនធ្លាប់ ។

អនុចិន្តន នបុំ. កិរិយាគិតរឿយៗ, កិរិយារិះគិត ។ អនុចិន្តា ស្រ្តី.

អនុចិន្តា ។

អនុច្ចិត គុ. (អន៍+ឧច្ចិត) ដែលរេចះ, ដែលជ្រើសរើស, ដែលសន្សំ ។

អនុច្ឆិដ្ឋ នបុំ. (វត្ថុ) មិនមែនសំណល់ ។ គុ. បរិសុទ្ធ, ដែលនៅថ្មោង ។

អនុច្ចាស បុំ. កិរិយាមិនដកដង្ហើម ។

អនុជ គុ ដែលកើតបន្ទាប់, ដែលកើតក្រោយ, បុំ. ប្អូន ។ អនុជា

ស្រ្តី. ប្អូនស្រី ។ អនុជន្មិ បុំ. អ្នកកើតក្រោយ, ប្អូន ។

អនុជនិ ធាតុ. កើតបន្ទាប់, កើតក្រោយ ។ អនុជាត គុ. ដែលកើត

ក្រោយ, ដែលកើតតាម, ដែលកើតមក (មានលក្ខណៈដូច

មាតាបិតា) ។

អនុជល្ប ធាតុ. និយាយតាម, និយាយគ្រាប់បន្តិចៗ ។

អនុជល្ប៍ ធាតុ និយាយក្រោយ, និយាយបន្ទាប់ ។

អនុជាគ្ឫ ធាតុ. ភ្ញាក់ ដេកមិនលក់ ។

អនុជានុមធ្យមំ ក្រិ. វិ. ខ្នងកណ្ដាលជង្គង់ ។

អនុជិ ធាតុ. ឈ្នះរឿយៗ ឲ្យតាំងនៅក្នុងច្បាប់ ។

អនុជីវ ធាតុ. រស់នៅរឿយៗ, រស់តាម ។

អនុជីវិន៑ គុ. ដែលរស់នៅតាម, ដែលរស់នៅដោយសារគេ, ដែលប្រតិបត្តិ

តាម ។

អនុជីវ្យ គុ. ដែលគប្បីរស់នៅតាម ។

អនុជុប៑ ធាតុ. ប្រគល់ខ្លួន, បូជាខ្លួន, ឧទ្ទិសខ្លួន ។

អនុជ្ញា ធាតុ. អនុញ្ញាត, យល់ព្រម ។

អនុជ្ញា ស្ត្រី. សេចក្ដីអនុញ្ញាត, សេចក្ដីយល់ព្រម ។

អនុជ្ញាត្ឫ ក. ន. អ្នកអនុញ្ញាត ។

អនុជ្យេឞ្ឋម៑ ក្រិ. វិ. តាមលំដាប់ចាស់ទុំ ។

អនុតដម៑ ក្រិ. វិ. តាមដងស្ទឹង ។

អនុតន៑ ធាតុ. លាត ឬទាញរឿយៗ, បន្ត ។

អនុតប៑ ធាតុ. ក្ដៅរឿយៗ, ឆេះរឿយៗ, ស្ដាយក្រោយ ។

( នៅមានត )

# ប្រវត្តិនៃខេត្តស្វាយរៀង

ព្រះមុនីកោសល សូរ-ហាយ រៀបរៀង

## ហេតុដូចម្ដេច ទើបគេហៅថា ខេត្តស្វាយរៀង ?

បានជាគេហៅថា " ខេត្តស្វាយរៀង " ព្រោះមានប្រវត្តិជាបុព្វហេតុនាំឲ្យគេហៅ ដូចសេចក្ដីឆ្លើយ រៀបរាប់តទៅនេះ :

អ្វី ៗ ទាំងអស់សុទ្ធតែមានប្រវត្តិជាដរាប បើមិនមានប្រវត្តិទេនោះ ក៏មិនអាចមានឈ្មោះឲ្យឃើញប្រាកដបានឡើយ ប៉ុន្តែប្រវត្តិទាំងនោះ ជួនកាលឃ្លៀងឃ្លាត ខុសពីគោលដើមខ្លះក៏មាន ខុសស្រឡះពីមូលហេតុដើមក៏មាន ដោយហេតុតែមនុស្សជាន់ក្រោយភ្លេចរឿងរ៉ាវដែលជារឿងពិតជាន់មុនអស់ទៅ ម្ល៉ោះហើយមនុស្សជាន់ក្រោយ ត្រូវការសរសេរ ឬ និយាយតៗគ្នាមក ក៏ចេះតែឃ្លៀងឃ្លាតរឿងដើមក៏មាន ខុសស្រឡះសោះទៅក៏មាន ។ ការចេះចាំដំណើរហេតុការណ៍ នៃប្រវត្តិឈ្មោះស្រុកទេស ឈ្មោះមនុស្សដែលជាអ្នកមានគុណសម្បត្តិ ឬមានគុណវិបត្តិនេះជាការប្រសើរណាស់ ព្រោះជាហេតុនាំឲ្យមានការប្រៀបធៀបថ្លឹងកិច្ចការ ដែលកន្លងផុតទៅៈហើយនោះ អាចយកមកស្ទាបស្ទង់ពិចារណាមើលកិច្ចការ ដើម្បីលៃប្រែកបការតម្រូវឲ្យសមហេតុផលដែលត្រូវធ្វើក្នុងបច្ចុប្បន្ន ។ អ្នកដែលចេះចាំប្រវត្តិ រឿងរ៉ាវបានច្រើនទៀត

តែធ្វើការបានផលប្រយោជន៍ក៏ច្រើនដែរ ។ នេះជាសេចក្ដីពិតមួយដែលគួរកត់ទុកក្នុងចិត្ត ពុំគួរបំភ្លេចចោលឡើយ ។

អ្នកកាន់សាសនាក្នុងសកលលោក ដែលកាចមានជំហររឹងប៉ឹងក្នុងការគោរពជឿកាន់សាសនារបស់ខ្លួនទៅបាននោះ ត្រូវអាស្រ័យការចេះដឹងប្រវត្តិសាសនារបស់ខ្លួន ដូចការដឹងថា អ្នកបង្កើតសាសនា របស់ខ្លួនឡើង តើឈ្មោះអ្វី? មានជីវប្រវត្តិយ៉ាងណា? ប៉ុណ្ណេះជាដើម ទើបឈ្មោះថា អ្នកជឿកាន់គោរពសាសនាជាប់ជាស្ថាពរតទៅបាន គឺថាការជឿកាន់នោះទុកថាជាមូលដ្ឋានមួយដ៏មាំមួនបំផុតរបស់សាសនា ។

ឃុំ ស្រុក ខេត្ត ក្នុងប្រទេសនីមួយ ៗ ដែលគេឲ្យឈ្មោះឡើងទាំងប៉ុន្មាន សុទ្ធតែមានប្រវត្តិទាំងអស់ ប៉ុន្តែឃុំ ស្រុក ខេត្តខ្លះ ដោយពុំមានអ្នកណាមួយសរសេរ រៀបរៀង ចងក្រងជាប្រវត្តិឡើងប៉ុណ្ណោះ ។ ដូចពាក្យថា " ខេត្តស្វាយរៀង តើមានប្រវត្តិយ៉ាងណា ? " សូមឆ្លើយរៀបរាប់អំពីបុព្វហេតុនៃពាក្យថា " ខេត្តស្វាយរៀង " ដោយសង្ខេបតាមការដឹងឮមកដូចខាងក្រោមនេះ :

អ្នកដែលធ្វើដំណើរតាមផ្លូវជាតិកាត់ខេត្តស្វាយរៀង ប្រហែលជាមានសេចក្ដីនឹកគិតថា " ខេត្តនេះឈ្មោះថា ខេត្តស្វាយរៀង ប៉ុន្តែម្ដេចក៏មិនឃើញដើមស្វាយដុះជាជួររៀងតាមផ្លូវជាតិនេះសោះ ? " ពាក្យថា " ខេត្តស្វាយរៀង ដោយគេយកដើមស្វាយមកជានិមិត្តរូបឲ្យឈ្មោះឡើង

រវាង គ.ស. ១៩១៩ ” ។ កាលនោះ មានមេឃុំចាស់ម្នាក់ឈ្មោះ ទេព-ព្រហ្ម ក្នុងឃុំគ្រោលគោល ក្នុងកាលដែលឈប់ធ្វើជាមេឃុំហើយ គាត់បានទទួលនាទីជាទីប្រឹក្សាខេត្ត, គេហៅជាពាក្យចាក់ដឹថា កុង្សីយេ ប្រូវាំងស្យ៉ាល់” ដោយលោករេស៊ីដង់ខេត្តបានតាំងឡើងបណ្ដោះអាសន្ន ពីព្រោះក្នុងរវាង គ.ស. ១៩១៩ នោះមិនទាន់មានពាក្យថា “ខេត្តស្វាយ-រៀង” នៅឡើយទេ មានតែពាក្យថា “ខេត្តរំដួល, ខេត្តរមាសហែក, ខេត្តស្វាយទាប” ។ ឈ្មោះស្រុកក៏ពុំទាន់មានដែរ លុះកាលជាខាង ក្រោយមកក្នុង គ.ស ១៩១៩ នោះរាជការបានកែប្រែខេត្តទាំងនោះ ឲ្យឈ្មោះទៅជាស្រុក គឺឈ្មោះស្រុករំដួល, ស្រុករមាសហែក, ស្រុក ស្វាយទាបវិញ ហើយត្រូវរើសឈ្មោះខេត្តដាក់ជាថ្មីទៀត ។ កាលនោះ លោករេស៊ីដង់ បានចេញសំបុត្រហៅមេឃុំ ចាស់ទុំ និងទីប្រឹក្សាខេត្ត មកប្រជុំនៅសាលាខេត្ត ដើម្បីពិគ្រោះគ្នារកឈ្មោះខេត្តថា ឥឡូវនេះខេត្ត ទាំងបីខាងលើ រាជការកែប្រែឲ្យទៅជាឈ្មោះស្រុកវិញហើយ ត្រូវនៅ ឈ្មោះខេត្តតែមួយ តើឲ្យឈ្មោះដូចម្ដេច ? នៅសម័យនោះលោករេស៊ី-ដង់ខេត្តបានសាកសួរដេញដោលគ្រប់មេឃុំ គ្រប់ទីប្រឹក្សាខេត្តដែលបាន ទៅប្រជុំ ដើម្បីយកពាក្យមានធ្វើសេចក្ដីកត់ហេតុបញ្ជាក់ជាផ្លូវការ ។ មេឃុំ និងទីប្រឹក្សាបានឆ្លើយជម្រាបចំពោះទីប្រជុំផ្សេងៗពីគ្នា ខ្លះថាដូច្នេះ ខ្លះថាដូច្នោះ តាមសេចក្ដីយល់ឃើញតែរៀងៗខ្លួនដោយពុំសូវសមហេតុ

ផល   លុះដល់លោករេស៊ីដន្តស្ពួរចំមកលើទីប្រឹក្សាខេត្ត ទេព-ព្រហ្ម ជាអតីតមេឃុំនៃឃុំក្រោលគោ លោក ទេព-ព្រហ្ម ក៏ក្រោកឈរឡើង ជម្រាបទីប្រជុំដោយពិស្តារទាំងសមហេតុផលផងថា «ដីមួយជួរតាំងពីព្រៃវែងខេត្តបាភ្នំមកទិសខាងកើតនេះ មានឈ្មោះចម្លែកណាស់ជាងដីស្រុកឯទៀតៗ គឺមានពាក្យថា ស្វាយ ស្វាយ ជាច្រើនកន្លែងរៀងៗគ្នា តាំងពីព្រំប្រទល់ខេត្តបាភ្នំមកទិសខាងកើតនេះ គឺបើរាប់អំពីទិសខាងលិចមក មានឈ្មោះថា ស្វាយជម្រៅ, ស្វាយយារ, ស្វាយអង្គ, ស្វាយផ្អែម, ស្វាយព្រហូត, ស្វាយជ្រំ, ស្វាយបេក, ស្វាយតឿ, ស្វាយទាប ស្វាយតាយាន" ឈ្មោះភូមិស្វាយទាំងនេះ ចម្លែកជាងដីស្រុកឯទៀត ហើយរៀងៗគ្នា តាំងអំពីទីបំផុតដីខេត្តខាងលិចរហូតដល់ទីបំផុតខាងកើត ព្រោះហេតុនោះ បើត្រូវការដាក់ឈ្មោះខេត្តនេះ គួរឲ្យឈ្មោះថា «ខេត្តស្វាយរៀង»វិញល្អជាង ដោយយកពាក្យថា "ស្វាយ ស្វាយ" នៅរៀងគ្នានោះមកជានិមិត្តរូប ។

## ឈ្មោះភូមិ-វត្តដែលឋិតនៅរៀងគ្នា

ឈ្មោះភូមិដែលមានពាក្យថា « ស្វាយ ស្វាយ » ដូចរាប់ខាងលើនេះ មានឈ្មោះជាប់មករៀងៗគ្នា តាំងពីទិសខាងលិចរហូតទៅទិសខាងកើត ដែលអ្នកស្រុក បានស្គាល់បានហៅរហូតមកដល់សព្វថ្ងៃនេះគឺ :

១. ភូមិស្វាយជម្រៅ នៅចុងខាងលិចបំផុត ប៉ែកគិតពីថ្នល់ជាតិទៅចម្ងាយប្រហែលជា ១០ គីឡូម៉ែត្រ ។

២. ស្វាយយារ មានឈ្មោះភូមិផង ឈ្មោះវត្តផង គេហៅថា វត្តស្វាយយារ គិតពីថ្នល់ជាតិទៅប្រហែលជាជាង ១០ គីឡូម៉ែត្រដែរ ។

៣. ស្វាយអង្គ មានឈ្មោះភូមិផង ឈ្មោះឃុំផង ពីថ្នល់ជាតិទៅប្រហែលជា ៨ គីឡូម៉ែត្រ ។

៤. ស្វាយផ្អែម មានឈ្មោះវត្ត គេហៅថា វត្តស្វាយផ្អែម ពីថ្នល់ជាតិទៅប្រហែលជា ៨ គីឡូម៉ែត្រដែរ ។

៥. ស្វាយព្រប្យូត មានឈ្មោះភូមិផង ឈ្មោះវត្តផង ពីថ្នល់ជាតិទៅប្រហែលជា ៤ គីឡូម៉ែត្រ ។

៦. ស្វាយជ្រុំ មានឈ្មោះវត្ត ហៅថា វត្តស្វាយជ្រុំ ពីថ្នល់ជាតិទៅប្រហែលជា ២ គីឡូម៉ែត្រ ។

៧. ស្វាយបេក មានឈ្មោះវត្ត ហៅថា វត្តស្វាយបេក ពីថ្នល់ជាតិទៅប្រហែលជាង ១០ គីឡូម៉ែត្រ ។ ឈ្មោះភូមិ ឈ្មោះវត្ត ដូចរាប់មកនេះ សុទ្ធតែនៅខាងជើងថ្នល់ជាតិ ។

៨. ស្វាយតឿ មានឈ្មោះភូមិ ហៅថា ភូមិស្វាយតឿ នៅខាងលិចផ្សារប្រសូត ខាងត្បូងថ្នល់ជាតិជាង ១ គីឡូម៉ែត្រ ។

៩- ស្វាយទាប ជាឈ្មោះសាលាស្រុក ដោយគេយកភូមិមកឲ្យឈ្មោះជាស្រុកស្វាយទាបសព្វថ្ងៃនេះ នៅជាប់នឹងថ្នល់ជាតិ ។

១០. ស្វាយតាយាន មានឈ្មោះវត្ត ហៅថា វត្តស្វាយតាយានខាងត្បូងថ្នល់ជាតិប្រហែលជាង ១ គីឡូម៉ែត្រ ។

ឈ្មោះភូមិ ឈ្មោះវត្តដោយមានពាក្យថា "ស្វាយ ស្វាយ" ១០ កន្លែងដែលឋិតនៅជាជួររៀងៗគ្នាដូច្នេះបានជាលោកទីប្រឹក្សាខេត្ត ទេព-ព្រហ្មអធិប្បាយជម្រាបទីប្រជុំថា គួរឲ្យឈ្មោះថា "ខេត្តស្វាយរៀង", ទីប្រជុំយល់ស្របគ្នាជាឯកច្ឆន្ទថា "ខេត្តស្វាយរៀង" ។ កុងពេលនោះលោករេស៊ីដង់ ក៏មានសេចក្ដីពេញចិត្តចំពោះពាក្យឆ្លើយរបស់លោកទេព-ព្រហ្មដោយឃើញថាសមហេតុផលល្អជាងគេ រួចធ្វើសេចក្ដីកត់ហេតុតាមយោបល់របស់លោក ទេព-ព្រហ្ម ផ្ញើទៅរាជការជាន់ខ្ពស់ក្រុងភ្នំពេញ បានសម្រេចយកឈ្មោះថា "ខេត្តស្វាយរៀង" តាមផ្លូវការតាំងពីជាន់នោះជាប់រៀងរហូតមកដល់សព្វថ្ងៃនេះ ។

# ព្រះរាជនិពន្ធរាមកេរ្តិ៍

(ត)

ភាគ ៩

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

ព្រះរាជនិពន្ធរាមកេរ្តិ៍ខ្សែ៩នេះ និយាយតាំងពីព្រះបាទទសរថ ច្បាំងនឹងហេរ័ណ្យទូក រក្លូតទៅដល់នាងទាំងបីអង្គ ទ្រង់ប្រសូតព្រះរាជឱរស ហើយព្រះរាមាលើកធ្នូសិល្បបាន នាងសីតា ហើយព្រះបាទកៃកេស មានរាជសារមកសូមព្រះភិរុទ្ធ ទៅគ្រងនគរហោង ។

*លុះអសុរកាំដេញតាមបានសត្វហើយ វាក៏សំពងវាយស្លាប់ ហើយក៏ទំពាខាំស៊ីជាភក្សាហារស្រេច ក៏ត្រាច់ចរចូលទៅក្នុងព្រៃជ្រៅ ដោយទូវចិត្តព្រហើនហានក្លា លុះឃើញពួកពលមនុស្ស ដែលនោះសុទ្ធសឹងកាន់គ្រឿងសស្ត្រាវុធពេញពាសដាស់ក្នុងព្រៃពនាវេសន៍ អសុរក៏សង្កេតមើល ហើយក៏រំពឹងគិតក្នុងចិត្តថា អ្នកណាអេះ ក៏អាចហានចូលមកក្នុងទីនេះ ម៉្លេះហើយអញនឹងកាប់សម្លាប់ឲ្យស្លាប់ទាំងអស់ ហើយក៏ផ្លោះសំដៅដែនអំណាចអាចខាំមាត់សង្កត់ធ្មេញពេញមុខ ហើយក៏ស្រែកសន្ធាប់ទៅឮគឹកកងរំពងព្រៃ កក្រើកទាំងផែនដី អសុរក៏ចំអើតលោតពារចូលទៅដេញតាបដូច្នោះ ហើយអស់ពួកពលយោធា គ្រានោះ ក៏ក្រឡេកមើលទៅឃើញរូបអសុរ ចូលមកដេញតាមកាប់សម្លាប់ដូច្នោះហើយ ក៏ភ័យគិត*

តក្កមាខ្លាចរិទ្ធិអសុរ ខ្លះក៏ប្រវាចាប់កាំភ្លើងឡើងបាញ់ព្រះ ហើយដោះដៃ រត់ចូលព្រៃពន្ធ័ពួនលាក់ខ្លួនលាក់កាយ ។ កាលគ្រានោះ ព្រះបាទធតរដ្ឋរិទ្ធិសាយ ឃើញពួកពលយោធាទាំងឡាយ រត់ព្រាងព្រាយទៅទីដៃ ។ ក្សត្រិយ៍ក៏ទ្រង់ទស្សនាមើលទៅខាងឆ្វេងឃើញអសុរ គ្រវីធ្នូសរថ្វាដេញចូលមក ព្រះអង្គក៏ចាប់យកព្រះខ័នពេជ្រ ចេញទៅឈរកាំងពាំងពីមុខ អសុរីចក្រក៏គ្រវីខ័នថ្វាគ្រវីគ្រវាសវៃលវង់ ។ កាលនោះរហេវ័ណ្យទូតកំហល់ដេញពលយោធាមកដល់ទីជាយពនាស័យ ឃើញមនុស្សឈរកាំងពាំងពីមុខ មានដៃនោះកាន់ព្រះខ័នគ្រវីសង្ហា ធ្វើក្លាហានមហិមា ទើបកុម្ភណ្ឌអសុរ ក៏ខឹងខឹងក្រញឹងក្រញៀងគ្រវែងខ្លួនថា នរណាអេះក៏អាចហ៊ានមកល្បងរិទ្ធា ហើយមាននាំអស់ស្រីៗល្អៗមក ប្រពាតលេងក្នុងព្រៃដូចស្រីទេពកញ្ញាកំព្រាដូចដួងព្រះច័ន្ទពេញបូណ៌មី ណ្ហើយចុះ អញនឹងសម្លាប់ប្ដីវាឲ្យស្លាប់ ហើយនឹងយកប្រពន្ធរបស់វាមករួមស្នេហា គិតហើយអសុរក៏ស្រែកសួរទៅថា រុំយនៃមនុស្សខ្លួនឯងនេះគឺជាពូជពង្សវង្សាស្ដេចណា ហើយមាននាមនោះឈ្មោះអ្វីហ្ន៎ ទើបបានជាឯងមោះមុះចិត្តអហំការក្លាហាន គ្មានកោតក្រែងខ្លាចអំណាច អង្គអញសោះឡើយ ហើយក៏ហ៊ាននាំអស់ពួកពលសេនាក្លា ចូលមកក្នុងសង្កាត់ដែនព្រៃហិម-ពាន្ត ជាទីស្ថានដែនខេត្តរបស់អញ ឯងនេះហៅព្រហើនហួស មិនគិតពីគ្រោះដល់ជីវិតក្ស័យនឹងដៃអញពុំខាន ។ កាលនោះ ព្រះបាទធតរដ្ឋ

ថ្កើងថ្កានធិបតី ស្ដេចបានស្ដាប់ពាក្យអសុរហើយ ព្រះអង្គក៏ទ្រង់ឆ្លើយតប ទៅវិញថា នែម្នាលអសុរកសាមាន្យ អាឯងកុំអាលអួតប្រាណថាមានឫទ្ធា ក្លៀវក្លាហាន រីខ្លូនប្រាណអញនេះក៏ពប់ថា ជាមនុស្សប្រុសប្រាជ្ញអាចមាន ឫទ្ធិអានុភាពមហិមា រីពូជពង្សអញនោះ គឺឈ្មោះព្រះបាទអជបាលសុរិយ-វង្សពង្សព្រះនារាយណ៍ឫទ្ធី រីរូបអញនេះឈ្មោះព្រះបាទធតរដ្ឋវង្ស គ្រង ក្រុងសិរីអយុធ្យាធានី ជាទីពំនាក់នៃត្រៃលោក អញមកលេងព្រៃព្រឹក្សា អរញ្ញវេសន៍មិនដឹងថាជាខេត្តខណ្ឌ របស់អាកុម្ភណ្ឌឯងសោះឡើយ ហើយ ឯងតើឈ្មោះអ្វី ក៏ហ៊ានតតេជដៃនឹងអញដ៏មានចេស្ដា ។ ទើបហោរណ្យទូត អសុរកបានស្ដាប់ហើយក៏ក្រេវក្រោធប្រឡោតខឹង ដូចភ្លើងប្រល័យកល្ប-កល្បក្រឡាប់សន្ធាប់ទះដៃផូងផាងកាងក្រពា ហើយក៏ស្រែកថា ដើះដើ មើលមើល៍អាមនុស្សា រាក៏ហ៊ានក្លាមកអួតអាងថា មានឫទ្ធីចេស្ដាពលាកាយ ចង់តតាំងច្បាំងនឹងអញ រីអញនេះឈ្មោះហៅហោរណ្យទូតយុនយក្សដ៏មាន ឫទ្ធីហឹកហាក់ពូកែ ក្នុងជម្ពូទ្វីបនេះ រហូតដល់ទៅតុសិតក៏គង់ក្រែងខ្លាច ឫទ្ធី អញនេះពូកែទៅតាំង ១០ ទិសា រីពួកបច្ចាមិត្រមិនហ៊ានតតេជដៃ ខ្លួន ឯងនេះទុចមាប្រៀបដូចម្រឹគា អញមើលទៅឃើញជាមិនរួចពីដៃអញ ឡើយ ហើយតាំងពួកពលយោធាទាំងអស់នោះ អញនឹងចាប់យកធ្វើជា អាហារ អសុរកថាហើយ ក៏សេពសូត្រកាយវេទវិជ្ជាដ៏មានឫទ្ធីក៏និម្មិតកាយ ក្លាយកើតជាកុម្ភណ្ឌពីររូប ដ៏មានខ្លួននោះធំមាំមួនក្រអួតក្រអើតខ្ពស់ត្រៃ

ពេកក្អែកនោះក្រហមប្រាលដាលដូចភ្លើងកប្ប ខាំមាត់សង្កត់ធ្មេញ បញ្ចេញ
ឫទ្ធិបង្កឹមនោះសរៃងស្រួច រួចរូបនិម្មិតនោះក៏កាន់ដំបងគប្រិគ្រាំសវិលវង់
វីរូបអង្គអសុរនោះ ចំពោះកាន់ឱ្យសិល្បជ័យ ហើយរូបនិម្មិតនោះវៃ ស្ទុះ
ចូលតយុទ្ធបេស្តា ៗ វីព្រះបាទធតរដ្ឋបុត្តា ស្តេចក៏ចូលតតាំងច្បាំងនឹងអសុរ
បានបន្តិច ស្តេចក៏យារព្រះខ័នពេជ្រលើកឡើងនឹងកាប់ អសុរក៏ចាប់
ព្រះហត្ថាជាប់ក្រឡាប់លើកដំបងសំពងទៅព្រះអង្គ ស្តេចក៏ទ្រង់យកព្រះ
ខ័នបាំការកាត់ទាត់ចេញមិនឲ្យត្រូវឡើយ ។ គ្រានោះវីហោរណ្យទូតអសុរ
ក៏ទន្ទ្រាំបាទា ហើយក៏ស្ទុះលោតទៅបំពានបំពារ ដេញចាប់យកនាងទាំង
បីដោយឫទ្ធិអសុរីយក្បា ស្ទុះចូលទៅប្រវាចាប់ដោះនាងកែវសុរិយា ហើយ
វាក៏ប្រវាទៅចាប់នាងកៃកេសរីមិនបានទៀតសោះឡើយ ហើយវាក៏ដេញ
ចាប់កៃរីជាទីកោលាហល ៗ កាលនោះ វីនាងនិម្មលទាំង ៣ អង្គ
នោះក៏ស្ទុះគេចកាយវេះវត់ពីអសុរ ព្រាត់ព្រាយទៅទីទៃភ័យស្ទើរនឹងក្ស័យ
ប្រល័យជីវិតសែនកិតតក់ស្លុតរន្ធត់ប្រឹងរត់វេវឹកទៅវិញទៅមក ហើយនាង
ក៏ស្រែកថាព្រះអង្គម្ចាស់អើយ ជួយខ្ញុំម្ចាស់ផង ហេតុតែបារមីចម្ងន់បុណ្យ
នៃពជគុរសនៅក្នុងព្រះទេវវរពជវេតានោះ ពេញចំពោះអសុរដេញ
ចាប់ មិនទាន់ឆងសោះឡើយ ៗ កាលនោះ វីព្រះបាទធតរដ្ឋ
គ្រាណាត្រើយនោះ ស្តេចស្តាប់សព្ទព្រះរាជទេពីស្រែកហៅដូច្នោះហើយ
ព្រះអង្គក៏ទ្រង់ខ្ញាល់ខ្លាំងក្រៃពេកណាស់ ស្តេចក៏ក្រឡេះកាប់នឹងព្រះខ័ន

កែវឫទ្ធិ ក៏ត្រូវរូបនិម្មិតអសុរកនោះនឹងចូលជិតមិនបានឡើយ ហើយព្រះអង្គ ក៏ស្ទុះទៅរកនាងទាំងបីអង្គ ទើបទ្រង់មធុរសព្ទថា ម្នាលនាងកល្យាណី ឆោមឆាយអូនអើយនាងកុំខ្លាចអសុរក កុំថាតែមួយនាក់នឹងពីរនាក់នោះ ឡើយកែវអើយឲ្យបានដល់ ១០០.០០០ កោដិក្តី ក៏បងមិនខ្លាចទេ បង នឹងផ្តាច់ជីវិត ឲ្យក្ស័យទាំងអស់បាន ថាហើយក្សត្រក្សាន្តក៏គ្រវីព្រះខ័ន ពេជ្រក្តីក្រោងក្រាយដូចភ្លើងឆេះសន្ធោសន្ធៅ ហើយស្តេចក៏ស្ទុះចូល ទៅតទល់នឹងអសុរកទៅវិញទៅមកប្រឡូកប្រឡងពេស្តា ៗ កាលនោះ រីហេរណ្យទូតអសុរកនឹងរូបនិម្មិតមារដ៏កោឡាហល ទល់តប្តូបណាកាយ ក៏មិនគេចរត់សោះឡើយ ខិតគាំង ច្បាំងគ្នាទាំងបីអង្គសុទ្ធតែទ្រង់ក្លៀវក្លា ហាន លុះយូរបានបន្តិចទៅ ព្រះបាទធតរដ្ឋធិបតីចក្រ ក៏ចាប់អសុរកទាំង ពីរ ហើយព្រះអង្គក៏ស្ទុះជាន់លើស្មាគាត់ហេរណ្យទូតអសុរក ហើយព្រះបាទា ខាងឆ្វេងស្តេចជាន់លើក្បាលដង្គង់អសុរករូបនិម្មិត ព្រះហស្តស្តាំទ្រង់ឫទ្ធិ ស្តេចក៏ចាប់ក្បាលអសុរីជាប់ ទៅវិញទៅមក ហើយព្រះអង្គក៏កាប់នឹងព្រះ ខ័នពេជ្រត្រូវរូបអសុរកហេរណ្យទូតដាច់ក្បាលធ្លាក់ទៅ រីរូបនិម្មិតនោះក៏ បាត់ទៅ ១ រំពេចដោយឫទ្ធិព្រះអង្គ ៗ កាលនោះ ហេរណ្យទូតអសុរ- ពង្សនោះឲ្យសែនក្រេវក្រោធពិពេកក្រៃ លុះត្រូវនឹងព្រះខ័នជ័យកាល ណា ហើយ ក៏រឹងឈឺធៀបល្បួលក្តៅទាំងកាយក្រហាយខ្លាំងពេកក្តាត ក៏ខំ ទំមាត់អត់សង្កត់ចិត្ត ហើយក៏ចាប់យកសរជ័យផ្លែងទៅប្រាថ្នាបុនបង

ទីងប្តិលផ្តាច់ផន្ទា រីឯវិស្សរថ្មានោះ ក៏ឮលាន់សន្ធឹកសន្ធាប់តាំងស្មុគពាស
ដូចរន្ទះអសនី រីសរអសុរនោះ ក៏ទៅបង្កើតជាភ្លើងឆេះឡើងរុងរឿងធ្លាក់
មកពេញពាសដាសប្រថពី ក៏ក្តៅដូចអគ្គីខាំងក្រៃ ៗ កាលនោះព្រះ
បាទធតរដ្ឋធិបតី ឃើញសរអសុរនោះចំពោះបង្កើត ជាអណ្តាតភ្លើងឆេះ
សន្ធៅ ទើបអង្គព្រះចមបៅ ស្តេចក៏ចាប់យកព្រះសែងទេវទេដ៏មាន
តេជៈផ្ទាប់បង្ក្រាបប្រាបដល់ដែនត្រៃលោកបាន អវតារក៏គ្រវែងបាលទៅ
ដោយកម្លាំងឫទ្ធិចេស្តា ក៏លាន់ឮសព្ទនោះកោលាហល ស្ទើរហាក់ទឹក
ធុះធ្លាយធ្លាក់ចុះមកពីលើមេឃា ហើយឮដូចរន្ទះទាំងពាន់ហោង ៗ រីព្រះខ័ន
ជ័យនោះផងក៏ទៅបំផ្លាញសរអសុរ ហើយក៏លត់ភ្លើងអសុរី ព្រះខ័នជ័យ
នោះ ក៏បណ្តាលកើតជាភ្លៀងធ្លាក់ចុះមក ហើយក៏ហួសទៅប្រហារដីវ
ហេរ័ណ្យខូតក្ស័ណក្ស័យផន្ទា ។ កាលគ្រានោះទេវបុត្រទិងនាងទេពកញ្ញា
គ្រប់ពសីទាំងទេពរុក្ខស្ថិតនៅដោយព្រៃពនាល័យ ទាំងទេពគិរីគ្រប់ទិវិមាន
មាសសោភ័ណ រហូតទៅដល់ជាន់ទាំង ៦ នោះ លុះឃើញហេរ័ណ្យខូត
អសុរក្ស័យផន្ទាដូច្នោះហើយ ក៏មានចិត្តនោះសោមនស្សក្រៃពេក ក៏
ស្រែកឡេសព្ទសាធុការគងរំពង ទាំងអាកាសវេហាស៍ ហើយក៏បាចសាច
នូវមាលាបុប្ផាជ្រុះចុះមកលើក្រឡាមហាប្រថពីដេរដាស ពាសពេញទាំង
ព្រៃព្រឹក្សា ទេវាខ្លះក៏ស្រែកឡើងមង្គលជ័យាតិរេក ឮគឹកកងរំពងទាំងវិមាន
មាសហោង ៗ គ្រានោះ រីពួកពលសកលយោធាទាំងអស់នោះ ចំពោះ

ឃើញថា អសុរមរណៈ ហើយក៏នាំគ្នាចេញចាកពិភពនាល័យ មកឃើញ ហោរ័ណ្យទូតស្តាប់ស្គរជ្រើង ប៉ុនទីងកំព្រះសុមេរុ ក៏លើកដៃវន្ទបង្គំ សរសើរបុណ្យបារមីព្រះអង្គនោះ ឮលាន់កក្រើកអំពើកទាំងព្រៃព្រឹក្សា ៗ កាលនោះ ព្រះវង្សទេពនោះ លុះប្រហារជីវិតអសុរហើយ ក៏ស្តេច នាំនាងទៅទាំងបី ឡើងលើរាជរថជ័យប្រសើរ ស្តេចល្អស្មើនឹងអង្គ សហស្សន័យន៍ ត្រៃនេត្រទ្រង់មហាវិជ័យយន្ត ទើបអង្គព្រះសាក័ណ ស្តេចក៏ឲ្យលើកពលយោធា លីលាវិលត្រឡប់មកធានីរាជស្ថានវិញ ហោង ៗ លុះអង្គព្រះបាសប្បង ស្តេចយាងមកដល់កើយកែវ អលង្ការ ស្តេចក៏ចុះពីរថមណី ស្តេចក៏នាំរាជទេពីទាំងបី រីអគ្គមហេសី យាងកាន់ប្រាសាទ សុវណ្ណដូចដើមហោង ៗ កាលនោះ អគ្គ-មហេសីទាំងបីស្នេហ៍ស្នងនោះ តាំងតែពីថ្ងៃនាងទ្រង់គភ៌ព្រះរាជឱរស ព្រះវង្សាទុំវង្សបំរុង រក្សាព្យាបាលមិនឲ្យមានរោគាព្យាធិឡើយ ហើយ នាងក៏សែនសេពសោយសម្បត្តិសម្បូណ៌ឥស្សរសក្ការជាសុខា ក្សេមក្សាន្ត សំរាន្តកាយា លុះគំរប់មាសាជិតដល់នឹងប្រសូតរាជឱរស នោះក៏មាន ខ្យល់កម្មជ្វាតបក់បង្វិលក្នុងគភ៌នាង នាងក៏ឈឺស្រពន់ចាប់ចុកអស់ព្រះ អង្គា គ្រានោះរីអស់ពួកកំណាន់ស្រីបំរើចាស់ទុំមេនំមេនាងរាល់គ្នា ក៏ភ័យ ជ្រួលជ្រួល សស្រោក ចូលចេញទៅវិញទៅមកទាំងក្នុងទាំងក្រៅ ខ្លះ ក៏ចូលទៅគក់ប្រាប់តែថ្លៃនាងទេវី ក៏នាំគ្នាគ្រឹកគរ ខ្លះក៏រត់ទៅវិញទៅមក

រកពេទ្យហ្វាកោលាហល ។ កាលនោះ ឯអង្គព្រះឥន្ទទសពល នោះស្តេចគង់លើទែនកែវទុកាសក្នុងទីវិមានមាសវិជយន្ត ព្រមទាំងទេពកញ្ញាកំណាន់និករបរិវារគង់គាល់បំរើ ច្រៀងរាំរបាំនូវភ្លេងដូរ្យតន្ត្រីក្រៃស័ន្ធស្លូតនោះ ចំពោះក៏បណ្តាលក្តៅដល់អាសនៈដូចភ្លើងឆេះ សហស្សនេត្រក៏ក្រឡេកទិព្វចក្ខុទតរមិលមើលមកក្នុងជម្ពូទ្វីប មនុស្សលោកនេះក៏ឃើញថា មហាអគ្គមហេសីទាំងបីព្រះអង្គ នឹងទ្រង់ប្រសូតរាជបុត្រដូច្នោះហើយ ពុំលង់ឡើយក៏នាំនាងសុជាតាទាំង ៤ ហើយនឹងទេពកញ្ញានោះហោះទៅកាន់នគរបុរីអយុធ្យាធានី លុះដល់ហើយព្រះកោសិទ្ធវីន្ទក៏ស្តេចចុះមកយាត្រានាំងអស់ហ្វូងទេពកញ្ញាតូចធំមាននាងសុជាតាជាដើម ចូលទៅក្នុងព្រះរាជពេនជ័យ ។ កាលនោះ ព្រះកូរន័យធតរដ្ឋនោះ លុះឃើញសម្តេចព្រះឥន្ទ្រកោសិយ នាំស្រីទេពនារីមកជួយអភិបាលនោះ ក៏ក្រេកអរសោមនស្សពេកក្រៃ ព្រះអង្គក៏លើកដៃទាំងពីរអញ្ជលីករដាក់លើសិរសា ហើយក៏ស្តេចអញ្ជើញអង្គព្រះឥន្ទ្រាឡើងលើប្រាសាទកែវសូរ្យកាន្ត ។ កាលនោះ អង្គសហស្សនេយន៍ត្រៃត្រឹង្សស្ថាន ស្តេចក៏គង់លើខែនសូរ្យកាន្តអលង្ការហើយ ព្រះអង្គមានទេវបញ្ជាថា ម្នាលព្រះបាទធតរដ្ឋចមចក្រពង្សទម្រង់រាជ្យ ដោយទសពិធរាជធម៌ទាំង១០ប្រការ កុំស្តេចព្រួយព្រះទ័យឡើយ ហើយអស់យើងខ្ញុំមកនឹងសុំជួយព្រះរាជទេពីទាំងបីមិនឲ្យក្តីវេទនា ត្រាស់ហើយព្រះឥន្ទ្រាក៏មានពាក្យប្រាប់ទៅមហេសីទាំង៤

ថា ម្នាលនាងទាំង ៦ អង្គចូរទៅជួយសម្តេចព្រះទេពីទាំងបីអង្គ ក្នុងទីប្រាសាទទើបប្រសូតពជ្ឈរសា ។ កាលនោះ វីនាងទាំង ៦ មហេសីឥន្រ្ទានោះ ក៏លើកដៃថ្វាយទទួលទៅទុក្ករហើយ ពុំលង់ឡើយក៏នាំអស់ហ្វូងទេពកញ្ញាបរិវារ ចូលទៅកាន់វិមានបន្ទប់ទេវកៃវវិសេយ្យា នាងសុជាតាទិនហ្វូងទេពធីតាចូលទៅស្ទាបផ្ទៃនៃនាងកៃវសុរិយា វីនាងកៃ-កេសីនោះ នាងសុចិត្រាចូលទៅជួយថែទាំព្រាំរក្សា នាងសុធម្មាសុនន្ទានោះ ក៏ចូលទៅជួយរក្សានាងសមុទ្រទេវីហោង ។ លុះកន្លងដល់មជ្ឈិមយាមយប់ស្ងាត់ ព្រះឥន្រ្ទាមានរស្មីភ្លឺត្រចះស្រឡះ ទ្រង់បាំងឆត្រកណ្តាលវេហាស៍គ្មានពពកបិទបាំងឡើយ ហើយទិព្វគ្រប់ពស៌ ក៏ប្រជុំលក្ខណាស្និទ្ធព្រមគ្នាក្នុងពសីមេស ជាពិសេសឧត្តុងឧត្តម ជាតាដូចព្រះបាទមហាចក្រ ជាមហាសក្តិបុគ្គប្រសិទ្ធណាស់ហោង ។ វីនាងកៃវសុរិយាផោម ល្អង់ក៏ប្រសូតអង្គព្រះរក្រានាពយណ៍ បុត្តាមានពណ៌ស្មៅសម្បុរខៀវបៃតងភ្លឺថ្លា ឧបមាបីដូចជានីលរត្នមណីរតនា ។ លុះដល់វេលាព្រះអរុណោទ័យដ្រះស្វាង ក៏នាងកៃកេសីនោះប្រសូតព្រះពជ្ឈរសរស្មីពណ៌សម្បុរនោះដូចផ្កាទទឹម ។ លុះម៉ោង ៣ បាទ ៥ នោះ ចំពោះនាងសមុទ្រទេវីនោះនាងក៏ប្រសូតពជ្ឈរស មានពណ៌រស្មីនោះ សម្បុរដូចមាសនព្វគុណ ។ លុះកន្លងចូលដល់ម៉ោង ៦ បាយ នាងក៏ប្រសូត

ព្រះរាជទេវី ពណ៌ស្រស់សប្បុរសនោះសុទ្ធទ្រ មានស្រីលក្ខណាទាំង ៤
ព្រះអង្គនោះក៏ល្អៗ ទើតឆាយទាំងកាយឥន្ទ្រីយ ។ កាលនោះ វីអង្គព្រះ
គោសិយទេវរាជនោះ លុះបានឃើញពង្សព្រះបាទធតរដ្ឋាធិបតីថា ព្រះ
រាជបុត្រាកុមារនោះល្អល្អះវិសេសណាស់ ប្រសិទ្ធិក្រ ស្ដេចក៏ផ្ចុំវេជយន្ត
យុទ្ធមហាសង្ខ វិសមេឌសង្ខនោះ ក៏ឮដូចផ្គរខ្ទរទាំងអាណាចក្រ វិហ្វង
ទេពអនន្តទ្រង់លក្ខណ៍គ្រប់ភ្នាក់ងារ ពួកតូរ្យតន្ត្រីក៏ខឹនាំគ្នា បំរើរាជទេពី
ទាំងគេរីនាគពាទ្យ ពីណស្រវៀក៏វាយគងជ័យបីដងយកជ័យ វេលាជា
គោណហលកក្រើកទាំងមណ្ឌលភាព កាលនោះ វីនាងសុជាតា និង
ទេពធីតាទាំងពួងព្រមគ្នា ធីតាខ្លះក៏កាន់ពានមាសទិព្វរត្ន ។ ត្រាបរង
រាជកុមារនឹងព្រះពស្ត្រទុកូលកស្ត្រ គឺព្រះនាពយណ៌ពមាហោង ។
ទាំងបីព្រះរាជទេវីនោះក៏ជាអណ្ដាប់ៗមក ហើយក៏អញ្ជើញយកព្រះ
រាជទេវីឲ្យស្រង់ព្រះសព្វទេវីសៃវទឹកទិព្វលាយទូវបុប្ផាស្រែចហើយ ក៏
ដាក់ព្រះរាជកុមារចុះ ឲ្យផ្ទុំលើពានមាសរតនាអលង្ការ ។ កាលនោះ
វីអង្គព្រះចមមកុដលោកាគិរីស្ថានកៃលាស លោកទាំងពួងពួកហ្វូងទេពទេវ
ជាបរិវារក៏ទ្រង់ក្បេមក្សាន្ត សាទរក៏ជួយឲ្យពរសព្វសាធុការ ចូរស្ដេចកុំឲ្យ
មានរោគភយន្តរាយមកបៀតបៀនបំណ្ឌាយាយីឡើយ ហើយសូមឲ្យស្ដេច
មានតេជរតេជៈ ដោយសិល្បសាស្ត្រ មន្តវិជ្ជា សរសក្តិ ពួកអសុរ-

ពាលបច្ចាមិត្រដែលរំមកគិតគតគេតដៃនឹងព្រះអង្គ កាលណាសូមឲ្យវិនាស ឲ្យព្រះអង្គឈ្នះទាំងត្រៃចក្រលោកាហោង ៗ លុះស្រេចហើយផង ព្រះអង្គក៏ចាកអាសនៈសុវណ្ណរត្នមណី ព្រមដោយទេពនារីហោះទៅកាន់ទីវិមានហោង ៗ កាលនោះ ព្រះបាទធតរដ្ឋរទ្ធីឫទ្ធិនោះ លុះឃើញព្រះរាជទ្រាស ទាំង ៤ នោះ មានដួងព្រះកក្រលក្ខណា ថាល្អប្រសិទ្ធផ្ទើ-រឿងត្រចះត្រចង់ ព្រះអង្គក៏មានព្រះទ័យនោះ ត្រេកអរសោទរសោមនស្ស បីដូចជាបានស្ថានត្រៃត្រឹង្ស ព្រះចក្រាក៏មានប្រតិព័ទ្ធស្នេហាស្រឡាញ់ស្មើដួងជីវិត ទើបអង្គព្រះទ្រង់ឫទ្ធិ ស្ដេចក៏ចាតឲ្យកំលៀងស្រីស្នំក្រមការចាស់ទុំបំរើជាប្រក្រតីហោង ៗ កាលនោះ ទើបអស់ពួកយាយអករផង នូវចាស់ទុំជាធំបានស្ដាប់ព្រះឧង្ការហើយ ក៏ក្រាបថ្វាយបង្គំលារថយមក ក៏នាំគ្នាចាត់រើសរកយកស្រីស្នំបំរើនោះ បំពោះជ្រើសរើសរកយកតែស្រីមានរូបឆោមពាយល្អប្រិមប្រិយ ត្រចះត្រចង់ក្នុងសុរ្យវង្សរាជត្រកូល ខត្តិយា វៀរតែស្រីដែលមានទោសទាំង ៦ ប្រការនោះ លោកមិនឲ្យយកមកទេ គឺខ្ពស់ ទាប ខ្មៅ ស ស្គម ធាត់ ស្ដេចឲ្យរើសរកយកតែមានលក្ខណាល្អព្រមល្មមទឹកដោះនោះផ្គូមផ្គាញ់ពាំសា ៦៤ អង្គបំរុងការ ជាស្រីស្នំកំលៀងបំរើគ្នាក់ឆាដោទីបម្រើនចិត្ត ៗ មួយទៀតឲ្យរើសយកយាយចាស់ទុំនោះ បំពោះតែព្រះញាតិវង្ស ថ្វាយព្រះពុទ្ធពង្សជាព្រះជេដ្ឋា នឹងសម្ដេចព្រះ

អនុជ ក៏ដូចគ្នាតាមព្រះរាជឱង្ការហោង ។ កាលនោះ ព្រះបាទធតរដ្ឋនោះ លុះគំរប់បីរាត្រីហើយ ព្រះត្រាណត្រើយស្ដេចក៏ទ្រង់ត្រាស់បង្គាប់ប្រាប់ទៅសេនា អាមាត្យថា អញ្ជើញសម្ដេចព្រះរាជកុមារ ចូលឯងចាត់ចែងការមង្គលអញ្ជើញចម្រើនព្រលឹងរាជឱរសា ហើយឯងទៅនិមន្តព្រះអាចារ្យមហាឥសីទាំង ៤ អង្គ ឲ្យចូលមកក្នុងរាជធានីវៀងជ័យ ។ គ្រានោះ រីមន្ត្រីសេនានោះ ក៏ទទួលព្រះរាជឱង្ការ ហើយក៏នាំគ្នារៀបចាត់ចែងតែងតាមព្រះរាជបង្គាប់ប្រាប់ប្រើ ទើបនាំគ្នាធ្វើ ររៀបមហាប្រាសាទឧត្ដម សម្រាប់ដោយរាជពិធី ក្រាលបៀមបំព្រាំព្រពូកខ្នល់ខ្នើយ ហើយមាន,នាំងរាំងនន បើកបាំងតាំងបាយសីមាស បាយសីប្រាក់ធើតធាយរៀងរាយរចនាលេខា មានពានមាសសុវណ្ណដាក់ចំពៀនរត្នស្រេចស្រាប់ ប្រដាប់តាំងគ្រឿងសុគន្ធ មាលីនឹងទៀនជ័យ កណ្ដាលនោះនៃក៏តាំងធ្វើជាបល្ល័ង្គរតនមណីសូរ្យកាន្ដជាម្ដង ហើយចងស្វេតឆត្រនឹងផ្ទើមព្រះរាជឱរសា ហើយចងពាំងពិតាន មានរំយោលភ្ជួងមាល័យរៀងរាយជាទីល្អរុងរឿងថ្កើងក្រៃ ស្រេចហើយក៏បង្គាប់ទៅសង្ឃការី ឲ្យទៅព្រៃព្រះហេមវន្ត ពនាល័យទៅនិមន្តព្រះមុនីឥសីទាំង ៤ អង្គ មកនឹងពួកសិស្សានុសិស្សផងជាបរិវារ ។ គ្រានោះ រីសង្ឃការីនោះ លុះបានស្ដាប់ហើយពុំលង់ឡើយ ហើយក៏នាំគ្នាលីលាទៅកាន់ស្ថានសាលាអាស្រមកុដិ ។

លុះបានដល់ហើយនៃ ក៏ទ្ទនាំគ្នាចូលទៅក្រាបថ្វាយបង្គំនមស្សការមហា-ឥសីទាំង ៤ អង្គទូលពុទ្ធដីកាថា ឥឡូវនេះ ព្រះអគ្គជាយាទេពីទាំងបីអង្គទ្រង់ប្រសូតព្រះរាជបុត្រហើយ ៗ ស្ដេចមានព្រះឱង្ការ ឲ្យមកនិមន្តព្រះតា-បស ទូវអស់ពួកគណៈព្រះឥសីផង កំណត់ឲ្យទាន់ក្នុងវេលាថ្ងៃនេះ ៗ កាលនោះ រីឯអង្គព្រះមហាឥសី បានស្ដាប់សេចក្ដីសង្ឃការីទូលហើយ ក៏មានព្រះទ័យនោះត្រេកអរណាស់ ហាក់បីដូចបានទិព្វវារីមកស្រោចស្រង់ផាន់ ទើបមានពុទ្ធដីកាប្រាប់គ្នាតាមដោយអណ្ដាប់ហើយ ពុំលង់ឡើយ ក៏នាំគ្នាទ្រង់គ្រឿងបរិក្ខារ សម្រាប់អាត្មាហើយ ក៏ចុះចាកពីកុដិអាស្រមស្ថាន ទាំងប៉ុន្មានអង្គតម្រង់ទៅកាន់អយុធ្យាបុរី ៗ លុះឥសីនិមន្តមកដល់មណ្ឌលភាព ក៏នាំគ្នាលីលាឡើងលើប្រាសាទសុវណ្ណ អង្គុយតាមអណ្ដាប់គ្នាទៅហោង ៗ កាលនោះ ព្រះបាទធតរដ្ឋបុទ្ធីច្បងនោះ លុះឃើញព្រះសិទ្ធាចារ្យនិមន្តមកព្រមគ្នាហើយ ព្រះអង្គក៏នមស្សការថ្វាយបង្គំ បូជាទៀន ធូប មាលាលាជទូវគ្រឿងសុគន្ធវិលេបនៈ ទៅព្រះតាបស ទើបស្ដេចមានមធុរសព្ទាថា ឥឡូវនេះញោមបានបុត្រាដូចរាទី សម្ដេចព្រះមុនីឥស្សរោមោលីលោកតាមកិច្ចពិធីព្រះករុណាជាម្ចាស់ ៗ ត្រាស់ហើយ ទើបស្ដេចមានព្រះឱង្ការ ឲ្យអញ្ជើញព្រះរាជកុមារទាំង ៤ អង្គមកថ្វាយបង្គំព្រះមុនីឧត្ដម កាលនោះ រីនាងព្រះស្នំបានស្ដាប់ព្រះរាជឱង្ការ ហើយក៏

ថ្វាយបង្គំលាមកកាន់ល្វែងទែនកែវអលង្ការ ហើយក៏អញ្ជើញសម្តេចព្រះបរមចក្រពង្ស ទាំង ៣ អង្គអនុជនូវទាំងកីលៀងសុរ្យវង្ស ពង្សញាតិជាតិកំណាន់នោះ ក៏ហែហមឡូមឡោមតាមជុំមកហោង ៗ លុះបានមកដល់ហើយក៏ដាក់ព្រះរាជកុមារលើទែនកែវសុរ្យកាន្តរត្ន ក្រោមស្វេត្រឆត្រឆើតឆាយ រីព្រះរូបកាយកត្រ្តារាជកុមារ នោះល្អថាដូចដួងព្រះច័ន្ទពេញបូណ៌មី ៗ កាលនោះ ព្រះមហាឥសីទាំង ៤ អង្គទ្រង់ពិនិត្យមើលរាជកុមារនោះ ដ៏មានលក្ខណាឆោមឆាយល្អ ៗ ក៏ដូចគ្នាទាំង៤អង្គ ឥសីក៏ទ្រង់សរសើរទាំងអស់អង្គថា ហើយទើបមានវាចាថាក្នុងគ្រានេះ ពួកអសុរនិងសុរ្យពង្សវង្សសន្តាន ដោយអំណាចព្រះអវតារណាចក្រពង្សទ្រង់គ្រោធពុំលែងឡើយ ហើយត្រែកតទាំងបីរហូតទៅដល់សកលទេវលោកា ទឹងបានជាទីពឹងដោយតេជានុភាពបុទ្ធព្រះដ៏ទ្រង់សរសេក្តា ដូចឆត្រកែវបើកបាំងសិរសា ជាម្លប់តំរៅព្រះអាទិត្យហោង ៗ កាលនោះ រីអស់ពួកបុរោហិតព្រាហ្មណ៍ ព្រឹទ្ធាចារ្យជាធំ បម្លងលុះបានឫក្សពារពេលាហើយក៏អុជទៀនជ័យបិទជាប់នឹងចិញ្ចៀន រគនា ហើយឲ្យបង្វិលប្រទក្សិណាពីឆ្វេង ទៅស្តាំហោរាចារ្យជាធំនោះ ក៏គោះគងជ័យបីដងស្រេចក៏លេងភ្លេងស្គរត្បូរតន្ត្រីត្រែសង្ខព្រាម ៗ គ្នា ទើបរាជគ្រូបុរោហិតនូវអស់ នាម៉ឺន មន្ត្រីសេនីយ៍សេនាបតី និងព្រះសុរ្យវង្ស ពង្សាទាំងអស់គ្នានោះ លុះ

ប្រទក្ខិណាទៀនជ័យបាន ៧ ជុំ តាមតម្រាប់តម្រាសៃយ ហើយក៏លត់ ទៀនជ័យ បក់ផ្សែងចំរើនព្រលឹង ឲ្យព្រះរាជពុទ្ធពង្សវង្សនារាយណ៍ ហើយក៏បក់ផ្សែងថ្វាយរាជអនុជទាំងបីអង្គផង ហើយក៏តាំងសូត្រស្មូតជ័យព្រះ ទូលព្រះវេទមន្តពីព្រហ្ម ហើយក៏ថ្វាយព្រះពរសុវត្ថិមង្គលសិរីទីឃាយុយឺនយោង ៗ គ្រានោះ អង្គព្រះតាបសទាំង ៤ អង្គទើបទ្រង់សន្មតថ្វាយតាមបណ្ដាំព្រះឥស្សរាធិបតីដោយសិរីជ័យសព្វប្រការណ៍ ព្រះជេដ្ឋាគឺព្រះនារាយណ៍ទេវេសនោះ ឈ្មោះថា ព្រះរាមាធិបតីបុទ្ធី ព្រះអនុជទី ២ គឺចក្រកែវ ឲ្យឈ្មោះជាព្រះភិរុទ្ធវឿងវង្ស អនុជទី ៣ នោះ គឺបល្ល័ង្កនាគនិងស័ង្ខ ឈ្មោះព្រះលក្សណ៍បុទ្ធវង្គ អនុជអង្គទី ៤ នោះ គឺដំបងពេជ្រ ឈ្មោះសត្រុតរុណ តាំងព្រះនាមរាជនុវេស ហើយមហាឥសីក៏ថ្វាយព្រះពរជ័យមង្គលសិរី ចូរឲ្យរឿងបុទ្ធិបារមីលើសត្រៃលោកទាំងពួង រីអស់ក្រសួងពួកពាលបច្ចាមិត្រសូមឲ្យបាញ់បុទ្ធិតេជផ្ទុះទៅទាំងចក្រវាឡយោង ៗ លុះស្រេចការផង ព្រះមហាឥសីទាំង ៤ អង្គទ្រង់ចូលព្រះពលា ព្រះបាទធតរដ្ឋវិលទៅអាស្រមកុដិវិញយោង កាលនោះ ព្រះចមកពលប់លើលោកា លុះស្រេចសម្ភោធព្រះរាជកុមារហើយ ព្រះត្រាណត្រើយទើបមានព្រះតម្រាស់ត្រាស់ទៅនឹងសេនីយ៍ថា ចូរអ្នកចាត់សែរកយកកុមារីដែលមានត្រកូលសមនូវរូបឆោមឲ្យ

ល្អ បាន ៤ ម៉ឺនរូបជាអ្នកមានពូជពង្សវង្សត្រកូលខ្ពស់ ហើយទូរអស់គីលៀនកុមារសុទ្ធតែសុរិយវង្ស ទ្រង់មានយសសក្តិឲ្យព្រះរាមាធិបតីសំរាប់បំរើបាទបារមី និង ៣ អនុជកុមារតាមអណ្តាប់គ្នាហោង ៗ ទើបសេនាបតីនោះផងទទួលព្រះឱង្ការហើយ ក៏ក្រាបថ្វាយលាចេញមកតាំងចាត់រើសរកគីលៀន ១៦ អង្គសុទ្ធតែពង្សក្សត្រពូជខ្ពស់ធំសមសក្តិ និងពួកកុមារតូច ៗ ជាទីបំរើនព្រះទ័យនោះ ៤ ម៉ឺនយកតែពីអាយុ ១២ ឆ្នាំស្រេចហើយក៏នាំយកមកថ្វាយសម្តេចព្រះនាគយណ៌ពមា និងសម្តេចព្រះអនុជទាំងបីអង្គ តាមដោយព្រះរាជបញ្ជាត្រាស់បង្គាប់ហោង ៗ

នេះនឹងសម្តែងពីនាងមណ្ឌាគីរីនោះវិញ តាំងតែពីបានសោយបាយទិព្វពិជកម្មកាលា នាងក៏ទ្រង់គភ៌នោះ លុះបំរើនកាលណា អង្គទសកក្រអសុរក៏ចាត់អស់ស្រីស្នំក្រមការទ្រង់រូបតាមលក្ខណានោះ ល្អដូចទេពអប្សរបំរុងបំរើនាងជានិច្ចនិរន្តរ៍ នាងក៏មានសេចក្តីសុខរៀងមក ៗ លុះគំរប់ទសមាសហើយក៏មានខ្យល់កម្មជ្ជវាត បក់បង្អិលហើយនាងក៏ឈឺសព្វសពាង្គកាយស្មើនឹងសន្ទូចចំប្រប់សព្វមំសា កាលគ្រានោះ រីអស់ពួកនារីបំរើឃើញនាងប្រឈួនព្រះឧទរខ្លាំង ក៏មានក្តីភិតភ័យតក្កមាតែរាល់គ្នា ខ្លះក៏រត់ចូលទៅគក់ច្រហាច់តែរួតទូតកាសខ្លួន ខាងខ្លះផងក៏អង្គុយលោមបោមផ្ទុំហ៊ុំជិត ជួយគម្រង់ទ្រព្រះឧទរនាងតាមយល់ ៗ

(នៅមានត)

# អធិប្បាយភាសិត

សាស្ត្រាចារ្យ ឈឹម-ស៊ុម តែងជាកាព្យ

## បទពំនោល ( តពីលេខ ២ )

ប្រែថា

ទក្ខីយ៍សុរីយ៍បញ្ញា[1] ធម៌ ៣ នេះថ្លា មានដល់ជនណាដូចអ្នក ។
បពិត្រពន់ទ្រឹងឯកអគ្គ ជននោះដៀងជាក់ ទឹងបានដល់ថ្នាក់ជានាយ ។ ជា
មេនៃជនទាំងឡាយ នាំខ្លួនអន្តរាយ មិនងាយគេជិះជាន់បាន ។

សរសើរហើយសួរទៅថ្កាន ថាអ្នកចង់បាន ផ្កាឈូកយកទៅធ្វើអ្វី ។
ពោធិសត្វតបវិញថ្វី ថាព្រះចក្រី បិតាខ្ញុំឲ្យមកបេះ ។
ឲ្យបានផ្កាឈូកដូច្នេះ យកទៅប្រឡេះ ដាក់ក្នុងពិធីអភិសេក ។
តាំងខ្ញុំឲ្យបានជាឯក អគ្គរាជចម្លែក ថ្ងៃស្អែកនេះណា៎ លោកណា៎ ។
ទើបយកក្រលាន់មាត់ថា ហ្ន៎ យើងទៅដែរណា៎ ដើម្បីជួយរៀបអភិសេក ។
ថាហើយជ្រើសផ្កាឯកៗ ពណ៌ល្អប្លែកៗ បានមួយកងលីលើស្មា ។

---

១ ទក្ខិយ ប្រែថា ឆ្លៀវឆ្លាស, ឈ្លាសវៃ, ប៉ិនប្រសប់ ។ សុរិយ ប្រែថា ក្លៀវក្លា, ក្លាហាន, អង់អាច, ហ៊ាន ។ បញ្ញា ប្រែថា ប្រាជ្ញា, ការយល់ច្បាស់, ការមិនភាំងគំនិត ។ ធម៌ទាំង ៣ នេះ មានក្នុងជនណា, ជននោះគួរទទួលតំណែងជានាយ ជាចៅហ្វាយ ជានាយក ។ នាយចៅហ្វាយប្រកបដោយធម៌ ៣ ប្រការនេះ បច្ចាមិត្រជិះជាន់ពុំបាន ។

ដើរតាមពង្រពានព ដល់ទីពនា– ល័យលាស់សាខាដង្គុំ ។
ពានរិន្ទមានសំជួបជុំ បរិពារព័ទ្ធហ៊ុម រីករាយសប្បាយពេកក្តាត់ ។
លុះឃើញព្រះពោធិសត្វ ដែលយក្សប្រតិបត្តិ លីបាច់ផ្កាដើរតាមក្រោយ ។
កំកើតកំហឹងខឹងដោយ– សារចង់ឲ្យផ្ដាយ ឲ្យស្លាប់ហើយបែរជារស់ ។
ថែមទាំងបានយក្សមានយសជួយសួយឲ្យខ្ពស់ ឲ្យថ្កើងឡើងធំថែមទៀត ។
ពានរិន្ទតឹងទ្រូងចង្អៀត ក្ដៅហើយក្ដៅទៀត ទាល់តែរហែកទ្រូងស្លាប់ ។
ពោធិសត្វសោកប្រញាប់ ចាត់រៀបរណ្ដាប់ ប្រញាប់លើកសព
សង្ការ(១) ។ ហើយទូន្មានបរិវារ ឲ្យយល់សង្ខារ ថាជាធម្មជាតិមិនទៀង ។
មិនគួរប្រព្រឹត្តឲ្យល្អៀង គួររកធម៌ទៀង គឺសច្ចៈសុចរិត ។
យុត្តិធម៌តាមការពិត កុំឲ្យវិបរិត ញៀនញ៉ាមគំនិតខូចខិល ។
ត្រូវមានឧស្សាហ៍កុំខ្ជិល កុំខូចកុំខិល នាំខកខាតពេលឥតការ ។
តមកពួកពលបរិវារ នាំគ្នាចាត់ការ ធ្វើពិធីអភិសេក(២) ។
យក្សជាទីប្រឹក្សាឯក ចាត់ការអភិសេក ថ្វាយរាជ្យព្រះពោធិសត្វ ។
ព្រះអង្គជាស្ដេចបរមត្ថ ពានរច្រើនក្តាត់ បានក្ដីសុខសាន្តសប្បាយ ។

---

(១) ពាក្យថា “សង្កា” និយាយបានតែជាមួយនឹងពាក្យថា “លើកសព” ។ បើប្រើឲ្យត្រឹមត្រូវគួរសរសេរថា លើកសពសំស្ការ ។ (២) ទស្សនាវដ្ដីអក្សរសាស្ត្រលេខ ១៨ ឆ្នាំ ១៩៦៤ មានចែងថា ឈ្មោះយាយពៅ នៅស្រុកត្រាំកក់ ជាអ្នកដើរព្រៃដើម្បីបេះផ្លែឈើ បានឃើញសត្វទោចរៀបការញីឈ្មោល ហើយមានភ្ញៀវប្រហែលសាមសែសិប ជប់លៀងដោយផ្លែម៉ាក់ប្រាង ប្រហែល ១ រទេះ ។ អ្នកចង់ដឹងទំនៀមដើរព្រៃគប្បីមើលទស្សនាវដ្ដីនោះផងចុះ ។

ឥតមានក្ដីក្ដៅក្រហាយ ម្រឹគពាឡ(១)ចាំផ្លាយ មិនហ៊ានបៀតបៀន
ពានរ ។ យក្សអារក្សទឹករាក្ស មិនឲ្យសត្វណា បៀតបៀនពួកស្វា
បានឡើយ ។

រឿងនេះចប់ប៉ុណ្ណោះហើយ ឥតសង្ខេបឡើយ មានតែសឹមសិន
បំពេញ ។ ខ្ញុំបាននាំមកបញ្ចេញ បញ្ជាក់ឲ្យពេញ សេចក្ដីភាសិតបុរាណ ។
នាយល្អកម្រេកបាន រីនាយក្លាហាន បានសម្រេចការសន្ដិសុខ ។

មានរឿងមួយទៀតទៅមុខ ខ្ញុំទាញមកទុក បញ្ជាក់ដូចមានតទៅ ៖

## រឿងពោធិសត្វកើតជាស្ដេចពានរ

(តិណ្ឌុកជាតក)

*បទកាកគតិ*

រឿងមួយទៀតពិត ថាកាលអតីត(២) កន្លងយូរយារ កាល
នោះមែនមាន ពួកពានរ នៅព្រៃហេមពាន្ត ជាសុខសប្បាយ ។
ដោយសារពានរិន្ទ្រ កជាធិបតិន្ទ្រ ប៉ុនមាល្បាយ ដឹងកិច្ចដឹងកល យល់
ការវែងឆ្ងាយ ពានរជានាយ គឺពោធិសត្វ ។ ព្រះអង្គសន្សំ បារមី
ឧត្ដម ពានបរមត្ថ ហ៊ានលះជីវិត ប្ដូរនឹងពួកសត្វ ពានរច្រើនក្កាត់
ដែលជាបរិវារ ។ ព្រះអង្គតែងនាំ ទៅក្នុងព្រៃជាំ ស្វែងរកអាហារ
ហើយតែងតែប្រុង ប្រយ័ត្នការពារ មិនឲ្យបរិវារ ពានរគ្រោះពុំគាប់ ។

(១) ពាឡ ប្រែថា «កាច, សាហាវ» ។ កុំច្រឡំនឹងពាល ដែលប្រែថា «ល្ងង់,ខ្លៅ» នោះឡើយ ។ (២) ត្រង់នេះអានថា អៈតិត កុំអានថា អៈតីតៈ ។

ព្រះអង្គបានតាំង ក្ឍយមួយសម្រាំង មានស្មារតីខ្ជាប់ ឈ្មោះសេនកៈ មាឌមានស្វាហាប់ ប្រាជ្ញាចំណាប់ ឲ្យជានាយរង ។ ជួយចាត់ចែងការ ជួយគ្រងការពារ អស់បរិវារផង ពុំដែលមានខ្វាយ ពុំឲ្យមានហ្មង ពួកពលស្វាផង តែងគ្រងរង់ស្ដាប់ ។

កាលនោះមែនមាន ភូមិចាស់បុរាណ មានដើមទន្ទាប់ មានផ្លែទុំខ្ចី ចំណីចំណាប់ ឲ្យជាសេគាប់ ដូចទិព្វផលា ។ មនុស្សចេញចោលទៅ ជួនកាលគេនៅ ថែទាំរក្សា ដើម្បីយកផល តិណ្ឌុកព្រឹក្សា គេកាប់ចន្ទា ធ្វើជារបង ។

សម័យមួយស្វាត់ ស្វាមួយខិលក្អាត់ លបលោតរំលង បេះបានផ្លែទុំ ឆ្ងាញ់ក្រៃកន្ទង នាំឲ្យស្វាផង ចង់តែទៅបេះ ។ ជ្រួល-ជ្រើមប្របល់ នាំឲ្យរវល់ ក្នុងក្រុមស្វានេះ ខ្លះថាដូច្នោះ ខ្លះថាដូច្នេះ ចង់តែទៅបេះ ឃាត់ពុំព្រមស្ដាប់ ។

ព្រះពោធិសត្វ រង់វៃពេកក្អាត់ ថាទៅត្រូវស្លាប់ តែឃាត់ពុំបាន ក៏ទៅប្រញាប់ ព្រះអង្គតាមជាប់ ដើម្បីការពារ ។ ពួកស្វាទាំងឡាយ ប្រឹងបេះប្រញាយ រពាយខ្សៀវខ្សារ អាងតែពោធិ-សត្វមកការពារ កំពុងខ្សៀវខ្សារ ស្រាប់តែគេព័ទ្ធ ។ មហាជនជុំជិត ចោមដល់ទីត ព្រលប់យប់ស្ងាត់ ស្ភាពនាល័យ(១) ភិតភ័យផ្អួមមាត់ ព្រះពោធិសត្វ

(១) អានថា : ស្វាពន់តាលៃ (ស្វាព្រៃ) ។

ឃាត់មិនឲ្យចុះ ៗ ដោយទ្រង់យល់ថា ធម្មជាតិមនុស្ស មានការចម្រុះ
កិច្ចច្រើនជំពូក ចាប់នេះចាប់នុ៎ះ មុខជាមិនធុះ កើតចាប់ស្វាទេ ៗ

វីសេនកៈ នាយវីរៈ ដែលបានជាមេ កាលពួកស្វាទៅ
ខ្លួនមិនទៅទេ កុំឲ្យឥតមេ រាំងកន្ទ្វង ៗ លុះបាត់ពួកស្វា អស់
កាលវេលា យូរយារអន្លើង ទើបឈ្ងល់យល់ថា ច្បាស់ជាក់ស្ទើង
ទៅដល់កន្ទ្វង មានមនុស្សព័ទ្ធជាប់ ៗ ទើបសេនកៈ ប្រុងសម្បជញ្ញៈ
ឃាតខ្ញីប្រញាប់ ទៅតាមពួកស្វា ដែលគេព័ទ្ធជាប់ សេនកៈប្រញាប់
ចូលទៅក្នុងស្រុក ៗ បានឃើញយាយចាស់ គាត់ដើរណាស់ អង្គុយ
សំកុក ទទូរអាំងភ្លើង ទន្ទកក្រឡុក សេនកៈតក្រុក ឆក់ឧសភ្លើង
បាន ៗ រត់គេចឡើងទៅ កាន់ទីលំនៅ គីគ្រឹហាឋាន ដុតផ្ទះឆេះ
ទ្រុល ហើយក្បាលគេចប្រាណ មនុស្សទាំងប៉ុន្មាន ភ័យច្រួលច្របល់ ៗ

ពួកពានរ ដឹងថាមនុស្ស មានការរវល់ រត់ទៅស្រុកបាត់
ស្វាត់អស់ពីគល់ សម្រុតមកដល់ ដីហើយរត់ទៅ ៗ ពោធិសម្ភារ
ប្រមូលបរិពារ ទៅដល់លំនៅ ក្នុងហេមពាន្ត ជាឋានព្រៃជ្រៅ តំណ
តទៅ បានក្តីសុខសាន្ត ៗ

រឿងនេះចែងចប់ បរិបូណ៌សព្វគ្រប់ តាមដោយលំអាន ខ្ញុំជាក់
បញ្ជាក់ តាសិតបុរាណ ថានាយក្លាហាន បានស្រេចកិច្ចការ ៗ

រឿងនេះពីរោះ ព្រមទាំងឥតមោះ ពាក្យពេចន៍ពោហារ សម្ដែងថែងចប់ សព្វគ្រប់ប្រការ ភាសិតពិស្ដារ ថែងចប់ម្ល៉េះហោង ។

## ដំបូន្មានដល់យុវជន

– កុំធ្វើមេខពាត់ កុំពង្រាត់ពួកសាមគ្គី កុំទ្រព្រើថពី ខុសវេណីពីបុរាណ ។

– នាយធ្វើងដោយសារពល ផ្ទាំងខ្ពស់សល់ ដោយសារគ្រាន

បើងចង់ធំប៉ុន្មាន គ្មានគេកាប់ឥតអំពើ ។

– កិច្ចការលើផែនដី ទោះអ្វីៗគេតពីធ្វើ កុំដេកក្រោកមើលលើ

ចាំទេព្ដាចុះមកជួយ ។

– ការធំគ្នាច្រើនធ្វើ គ្រប់អំពើមិនតែមួយ ត្រូវតែព្រួតគ្នាជួយ

ព្រមទាំងត្រូវស្ដាប់នាយកោយ ។៚

ចប់

នាយល្អក្រៃកបាន នាយក្លាហានបានស្រេចការ

តែប៉ុណ្ណេះ ។

## ៣– អួសទុកកុំឲ្យល្អាន ចាប់ត្រីឲ្យបានកុំឲ្យល្អក់ទឹក

កាព្យពាក្យ ៧

ពាក្យថាអួសទុកកុំឲ្យល្អាន ចាប់ត្រីឲ្យបានកុំឲ្យល្អក់

ជាភាសិតល្អពុំអាក្រក់ សម្រាប់នាយកគ្រប់តំណែង ។

បានជាតំណតដំណាល ពីបុរាណកាលប្រាជ្ញត្រិះថ្លែង
ជាជម្ងឺនានមកច្បាស់ថែង សម្ដែងសំដៅដល់មេបា ។
ភាសិតនេះមានគោលពីរពិត អ្នកប្រាជ្ញប្រថិត(១)ជាមាតិកា
១- គឺអុសទូកឬទាក់ កុំឲ្យល្ហានធាមានះហេតុស្នាម ។
២- គឺចាប់ត្រីឲ្យបានផង កុំឲ្យមានហ្វូងទឹកល្អក់ភ្លាម
ចូល'ក្នុងដល់ផ្ទុកមិនទើមតាម ដៃច្បាមចាប់ត្លាមបានទាំងបីង ។
ភាសិតនេះជាពាក្យឧបមា អ្នកឥតប្រាជ្ញាពិតពុំដឹង
ទាល់តែពិនិត្យគិតរំពឹង ទើបដឹងទើបជ្រាបជ្រះសង្កា ។
រីពាក្យថាទូកក្នុងទីនេះ មិនមែនទូកជិះឆ្លងជលសា
គឺជាករណីយ៍ដែលអស់មហា- ជនផងគ្រប់គ្នាក៏ប៉ងធ្វើ ។
ដូចជាករណីយ៍ក្នុងគ្រួសារ កិច្ចផ្ទៃកផការសព្វសារពើ
ដែលមេគ្រួសារមេក្រុមធ្វើ សុទ្ធតែអំពើធ្ងន់ណាស់ណា ។
ពុំនោះសោតទេដូចកតាដែន ខេត្តដែនរដ្ឋពសីមា
ក៏ជាទូកធំធំហោមហា- ធំឥតឧបមាធ្ងន់ក្រៃលែង ។
ករណីយកិច្ចទាំងអម្បាលមាណ ដូចដែលខ្ញុំបានលើកមកថ្លែង
ចុះចំគោលធំធំនេះឯង អ្នកប្រាជ្ញសម្ដែងថាជាទូក ។
រីឯទូកទាំងអម្បាលណោះ អ្នករៀនអ្នកចេះចូលចិត្តលុក

---

(១) ក្លាយមកអំពីពាក្យថា “ ប្រតិស្ឋ ” ដែលប្រែថា តាំងទុក, តម្កល់ទុក ។

ចាប់អួសចាប់ទាញកុំឲ្យក្អក　　តែទូកនេះតែងតែមានល្អាន ៗ
គឺមានស្នាមប្រេះរបេះឆា　　របកត្រង់ណាខ្វះពុំខាន
កម្រនឹងអួសឲ្យសុខសាន្ត　　ដល់សិរដ្ឋានបានសួស្តី ៗ
ហេតុនេះបានជាប្រាជ្ញបុរាណ　　លោកមានមេត្តាត្រាប្រណី
អាណិតអាសូរជនប្រុសស្រី　　ដែលខំឃ្លាតខ្លីគ្រប់ទីឋាន ៗ
លោកតែងទូន្មានប្រៀនប្រដៅ　　ថាអួសទូកទៅកុំឲ្យល្អាន
កុំឲ្យកើតហេតុហួសប្រមាណ　　កុំឲ្យរទស្ថានក្នុងតំណែង ៗ
　　ការនេះពិតជាករណីយ៍ធ្ងន់　　ដែលឥស្សរជនគ្រប់កន្លែង
ចង់តែកន្លងការជួយខ្វែង　　ទើបខំប្រឹងប្រែងអួសជានិច្ច ៗ
ប៉ុន្តែតែងតែមានឧបសគ្គ　　រនាំងរាំង ស្ទាក់ឲ្យទង្គិច
គឺគល់កល់កៀងកើលឲ្យលិច　　ខ្វះក៏ទង្គិចតាល់តែបែក ៗ
មានជនខ្វះដៃផ្គតពីសូន្យ　　បេះអួសទាំងក្បួនសណ្ឋានបែក
ចាត់តាមទំនួលស្រួលវែកញែក　　ឥតបែកថែមបានពិន្ទុល្អ ៗ
ដំណើរផ្សេងគ្នាទាំងនេះឯង　　អ្នកប្រាជ្ញសម្តែងជាតំណ
តតាមទំនៀមដែលល្អៗ　　ជាក្រមកពីខ្វះបុណ្យភ័ព្វ ៗ
ទោះបីអ្នកបេះដឹងយ៉ាងណា　　តែខ្វះវាសនាសាងរាប់កប្ប
គង់អួសទៅកៀងកល់ត្រឡាប់　　ចង់បានធុតធាប់ផ្កាប់អន្តរាយ ៗ
លុះតែអ្នកមានបុណ្យវាសនា　　កើតគុបប្រាជ្ញាជាក្ខុសុសសាយ

គប់ដោយទ្រឹស្ដីល្អពណ្ណរាយ ទើបក្រជាឆាយធ្ងន់ជាស្រាល ៗ

ឧទាហរណ៍ដូចព្រះកុមិន្ទ នរិន្ទបមពង្សអង្គភូបាល

ជាម្ចាស់យើងដែលប្លែកត្រកាល មនុស្សប៉ាន់កណ្ដាលគ្មានគេដូច ៗ

ទ្រង់បានសោយរាជ្យពីកុមារ គួរឲ្យអស្ចារ្យព្រោះនៅតូច

ទៅតែកាន់ការពុំដែលខូច ពុំដូចប្រទេសគេជិតខាង ៗ

សៀមយួនតែងប្រាសអាយូស ព្រោះអួសពុំរួចខ្វះសំណាង

បានជាសំណើចអ្នកជិតខាង ក្អេងក្អាងដូចក្អាត់បាត់ពីស្រុក ៗ

គឺថាស្ដេចសៀមជំនាន់នោះ នាមឈ្មោះថាប្រជាទីប៉ុក

អួសរដ្ឋពុំរួចរត់ចោលស្រុក ស្ដេចយួនអុកឡុកដូចគ្នាដែរ ៗ

ចៅដាយនៅឆ្ងាយដល់អណ្ណាម មានស្នាមហើយថយមកជិតខ្មែរ

ធ្វើការមិនខ្ចះប្រែះបែកបែរ រត់ទៅនៅក្បែរស្រុកបាំកង ៗ

ស្រុកយួនខាងត្បូងឈ្មោះឌិញយៀម រស់តាមទំនៀមអាមេរិកាំង

ចាត់ការឲ្យកើតតែចម្បាំង ខួបប្រាំងវស្សាឥតបានសុខ ៗ

ដប់ឆ្នាំប្លាយហើយយួនខាងត្បូង នៅក្នុងចម្រូងការអុកឡុក

ព្រោះតែអ្នកដែលជាប្រមុខ ធ្លាក់ថុកជង្ហុកទ្រឹស្ដីខុស ៗ

ថែមទាំងបុណ្យតូចពូជទាបផង ថែមជាប់ចំណងជនទុយ៌ស

ថែមទាំងចចេងចង់តែខ្ពស់ ចង់រស់ចង់រួចតែពូជខ្លួន(១) ៗ

---

(១) ពូជង៉ោឌិញយៀម ស្លាប់វិនាសក្នុងថ្ងៃទី២ វិច្ឆិកា ១៩៦៣ ដោយរដ្ឋប្រហារ ព្រោះគាត់ប្រើការរំលោភលើពួកពុទ្ធសាសនិក ។

ស្រុកណាក៏កើតកលិយុគដែរ　　មិនដូចស្រុកខ្មែរប្រែដូចយួន
យកគេធ្វើគ្រូគ្រប់ចំនួន　　បែកពួកបីបួនបានទទឹង ។
គឺខ្លះថាប្លុក(១)ខាងកើត　　ខ្លះស៊ើតថាប្លុកខាងលិច
ខ្លះអព្យាក្រឹត្យគិតកលកិច្ច　　មិនកើតមិនលិចនៅកណ្ដាល ។
ទើបតែទឹងបានយល់ស្របគ្នា　　ទំរាំជានាពស្រ្ពក៏ស្កាល
វេលាអស់ច្រើនក្រៃគ្រាកាល　　បណ្ដាលពីអ្នកអួសមិនស្រួល(២) ។
មានតែពួកខ្មែរយើងនេះឯង　　លូនលឿនចិញ្ចាងតាមទំនួល
ពោះបីកង់ទឹកប្ដូទទួល　　ពួកយើងលឿនស្រួលឥតស្រាំផា ។
ព្រោះតែសម្ដេចព្រះប្រមុខ-　　រដ្ឋដែលយើងទុកជាបិតា
នៃយើងជាតិខ្មែរទាំងអស់គ្នា　　ហើយជាបិតាសន្តិភាព ។
ទ្រង់កបដោយបុណ្យពីបុព្វ　　មិនមែនតិចទេផុតជម្រាប
ទ្រង់កបដោយប្ញកពាសុភាព　　ទ្រង់ជ្រាបវិជ្ជាក៏ជ្រៅជ្រះ ។
ទ្រង់មានព្រះទ័យទន់ត្រជាក់　　ទ្រង់ចេះរាក់ទាក់មិនម្នាម្នះ
មនុស្សយើងគេឯងតែងប្រទះ　　ឃើញទ្រង់សំពះចាស់ព្រឹទ្ធា ។
ទុនអើយនេះទុនព្រោះមានគ្រាប់　　ទាល់តែគេរាប់ពេញភាព
បានសោយរាជ្យឡើងថ្កើងកាលណា　　ក្សត្រាទ្រង់ប្រោសព្រះរាជទាន ។

---

(១) ភាសាបារាំងគេសរសេរ ( Bloc ) ប្រែថា ក្រុម ។ ក្រុមខាងកើត គឺពួករុស្ស៊ី , ក្រុមខាងលិច គឺពួកអាមេរិកាំង ។ (២) លាវយល់ស្របគ្នាបានទន្ទ្រាំបែកបាក់គ្នាទៀត ដល់ឆ្នាំ១៩៦៦ មិនទាន់បានសុខនៅឡើយ ។

លទ្ធិប្រជាធិបតេយ្យ(១) យើងប្រើសព្វថ្ងៃជាប្រធាន
នេះហៅអ្នកសទូកឥតឡ្យល្អាន ប្រធានចំណុចនេះពេញត្រូវ ។
ត្រូវម្តងនាំធ្វើឲ្យត្រូវទៀត ពុំដែលបង់ម្យៀតទាសខុសផ្លូវ
ត្រូវហើយត្រូវចំចំកៅអ្ហូវ ត្រូវដល់ឥឡូវឥតខុសម្តង ។
ធម្មតាមហាក្សត្រតែងរេបិង នេះមិនដែលរើងដូចក្សត្រផង
ទន់ទៅតែពត់មិនទន់ម្តង អ្នកណាកន្លងអ្នកនោះក្ងាត់ ។

មួយទៀតកាលទ្រង់ព្រះរាជទាន ឲ្យមានសេរីថាពេញមាត់(២)

ថាម៉េចថាចុះកុំតែក្ងាត់ ខុសរដ្ឋធម្មនុញ្ញទើបមានទោស ។
កាលណោះមែនមានគណៈបក្ស យោគគ្នាដូចយក្សធំថ្ងាសៗ
ដើរថ្វែងកំហែងដូចស្វាក្រោស បកកើ្តទ្វេទោសតែគ្នាឯង ។
បង្កបង្កើតអរិចិត្ត មិត្រហើយនិងមិត្រចិត្តបេញស្វែង
ទំស្វរកទោសតែគ្នាឯង ដណ្តើមកន្ទេងធ្វើកុងរ្យយ៍ ។
បណ្តាលជាអសន្តិសុខ រេចពស្រ្តគ្រប់ស្រុកដូចស្មៅខ្ចី
ដែលគោឡើងកប្តក្របី ជល់គ្នាហើយឥតឈក់រករី ។
ទាល់តែសម្តេចព្រះភូមិន្ទ នរិន្ទបមពង្សអគ្គភូមី
ទាញលែងបណ្តោយឲ្យរករី ភូមីទ្រង់ជាក់រាជសម្បត្តិ ។
ថ្វាយផ្ទាល់ព្រះមាតាបិតា អភិសេកលើកជាព្រះមហាក្សត្រ

(១) ពីឆ្នាំ ១៩៤៧ ។ (២) មាត្រា ៩ នៃរដ្ឋធម្មនុញ្ញ ។

សក្ការៈនេះជាបរមត្ថ ឥតមានមហាក្សត្រណាធ្វើបាន ៗ
ទ្រង់ជាក់ពង្សហើយទ្រង់ធ្វើក្សត្រ ដូចជនតែពាសក្នុងភូមិឋាន
យានដោយព្រះបាទកំសត់មាន គង់នៅចក្រយានគ្មានធ្វើនៃ្ន ៗ
ស្ដេចធ្លាក់ចូលក្នុងភូមិលំនៅ នៃអ្នកក្នុងក្រោលល់ៗថ្ងៃ
ដើម្បីស្ទង់ស្ទាបអធ្យាស្រ័យ ស្រេចហើយក្សត្រឲ្យបន្ទូលថា ៗ
នៃហអស់លោកអ្នកទាំងឡាយអើយ លោកអើយខ្ញុំសុំលោកមេត្តា
បើកឲ្យខ្ញុំអូសម្ដងវិញណា ខ្ញុំហ៊ានសន្យាត្រឹមបីឆ្នាំ ៗ
ឲ្យបានឯកពង្សពេញបរិបូណ៌ ឲ្យក្សត្របានធូរលែងវេទកម្ម
បើដល់កំណត់ត្រឹមបីឆ្នាំ ខ្ញុំនាំពុំរួចខ្ញុំសុំឈប់ ៗ
តមកសម្ដេចព្រះក្សត្រនាថ ទុកគោសុជាតិជាបមកត
ការនាមេត្តាពល់ថ្ងៃយប់ ទ្រង់ជប់បង្កើតជាអគ្គការ ៗ
នាមឈ្មោះសង្គមរាស្ត្រនិយម(១) មានជនតូចធំចូលខៀវខ្មារ
បោលគណៈបក្សបង់អសារ ព្រួតគ្នាខំស្ដារប្រទេសជាតិ ៗ
មិនយូរប៉ុន្មានបានឯកពង្ស ដោយការអង់អាចព្រះនរនាថ
ទ្រង់ណែនាំប្រទេសជាតិ ឲ្យឃ្លាតពីខ្មៅទៅជាប្រាជ្ញ ៗ
ឲ្យក្រោកពីក្រទៅជាមាន ឲ្យខ្លាចជាហ៊ានមានអំណាច
ឲ្យទាបជាខ្ពស់យសត្រដាច ត្រដឹមគួរខ្លាចគួរស្ញប់ស្ញែង ៗ

(១) ពីឆ្នាំ ១៩៥៥ ។

នេះហៅអូសទូកឥតឡ្បណ្ណាន អូសបានទាំងបាត់ស្នាមប្រេះខ្វែង
ស្នាមឆារេចគ្រប់កន្លែង ស្អាតទែងដូចទូកឥតខ្ទង់មិត្ត ៗ

ចប់គោលទី ១ ( អូសទូកកុំឡ្បណ្ណាន ) ត្រឹមប៉ុណ្ណេះ
គោលទី ២ ( ចាប់ត្រីឲ្យបានកុំឲ្យល្អក់ទឹក ) តទៅ

ពាក្យថាអូសទូកខ្ញុំសុំស្មេះ បញ្ចប់ត្រឹមនេះហើយពិនិត្យ
គោលការណ៍ទី២តាមសុភាសិត តាមប្រាជ្ញប្រឌិតប្រដៅថា ៗ
ចាប់ត្រីឲ្យបានកុំឲ្យល្អក់ ទឹកពាល់កខ្វក់ខូចខានថ្លា
មិនថ្លែងចំត្រីពួកមច្ឆា ជាពាក្យឧបមាឧបមេយ្យទុក ៗ
គឺពាក្យថាត្រីមិនមែនជា- អស់ទាំងមច្ឆានៅនាថ្លុក
ស្ទឹងបឹងបួរបៀរបត់គ្រលុក គ្រលៀតជង្ហុកអូរត្រពាំង ៗ
ត្រីនេះគឺជាទ្រព្យរបស់ អម្រស់អម្រល្អសម្រាំង
ជាគ្រឿងសម្រើបចិត្តអស់ទាំង- មហាជនប្រណាំងប្រជែងគ្នា ៗ
ទំរុកទំពានទន្ទ្រានគ្រាច់ ប្តូរឈាមប្តូរសាច់សព្វទិស
ទោះទាំងកត្រីឥតបើក រុលរកគ្រប់គ្នាគ្រប់ទីឋាន ៗ
ទីគោកទីទឹកទីទាបទួល ទំនាបទំនួលទំនងបាន
មានផ្លូវត្រង់ណាត្រង់ណាមាន ទំទិតចូលក្តាន់ឋានត្រង់ណោះ ៗ
រកទៅរកទៅទៅជាវិស ទាស់ទែងខ្វែងឃ្លើសឃ្លាន់ជាន់គ្រោះ
ជួនគ្រាន់បានក្រែលះទៅខាងណោះ ស្រោចគ្រោះខាងណោះរបេះបង់ ៗ
នេះហៅចាប់ត្រីកុំបានផង ថែមទាំងមានហ្វូងទឹកថ្លាធ្ងន់

ធ្វើឲ្យល្អក់ខ្ចប់អសារបង់ ព្រោះមិនកាន់ត្រង់ភាសិតនេះ ៗ
ខ្វះខ្វាររកទាល់តែបាន តែរទេះស្ពានមានស្ពាមប្រែះ
រកបានបានមកតែខាងណេះ របះប្រយោជន៍កេចខាងណោះ ៗ
នេះក៏មិនមែនជាករណីយ៍ នៃជនប្រុសស្រីដែលល្អសោះ
សៅហ្មងមែនមែនព្រោះមានមោះ មានឈ្មោះថាចាប់ត្រីឲ្យល្អក់ ៗ
ជនល្អកម្រមានក្នុងលោក មានច្រើនគគោកតែអាក្រក់
ព្រោះច្រើនតែចាប់ត្រីឲ្យល្អក់ កខ្វក់ខ្ចប់ទឹកគ្រប់ទីឋាន ៗ
ជនល្អក្នុងគ្រាស្វែងប្រយោជន៍ មិនបេះបោចកេចតាមចង់បាន
ដូចឃ្មុំត្រឹបផ្កាព្រឹក្សាសាន្ត ឥតមានឲ្យខូចខកខានផ្លែ ៗ
អ្នកណារកទ្រព្យរបស់បាន មិនឲ្យរទេះស្ពានសត្វថ្ងៃ
បានផ្កាឥតឲ្យខូចដល់ផ្លែ នេះនែហៅថាមនុស្សល្អ ៗ
ចាប់បានត្រីមកមិនមានល្អក់ ទឹកមិនកខ្វក់កក់កករ
ទឹកថ្លានៅថ្លាបរិសុទ្ធល្អ នេះពេញកម្រមានសព្វទី ៗ
មួយទៀតអ្វីៗដែលគេប្រឹង គេគិតរំពឹងប្រឹងសំភី
ភាវរកចាប់យកមកដល់ទី នោះក៏ជាត្រីមួយយ៉ាងដែរ ៗ
ដូចពុតអាក្រក់នៃមនុស្សខូច គេស្ទាបគេស្ទូចគេថ្នមថៃ
ស្ទង់យូរៗទៅទាល់តែក្អួ គេប្រិតឲ្យប្រែទៅតាមការណ៍ ៗ
នេះហៅចាប់ត្រីត្រីក៏បាន ទាំងទឹកមិនមានល្អក់អសារ

ហៅធ្វើការកើតមិនខូចការ ព្រោះបុណ្យសម្ភារមានគ្រប់គ្រាន់ ។
មួយទៀតពលរដ្ឋក្នុងភាព គឺពស្ត្រប្រជាទាំងរយពាន់
ហ្មឺនសែនលានកោដិកើតកពភ័ក្ត ភ័យស្ងួនភ័ក្ត្រស្មោះបោះបេះជ្រួល ។
នេះក៏ជាត្រីមួយបែបដែរ ត្រីបេះត្រីបែរត្រីផ្កាយប្រួល
ប្រាជ្ញព្រើលប្រឹងប្រិតរឹតមិនស្រួល ចាប់តាស់ទំនួលបានទំនាស់ ។
ទំនៀមអូសទូកកុំឲ្យល្អាន ចាប់ត្រីឲ្យបានកុំឲ្យទាស់
ទាល់តែអ្នកប្រាជ្ញជាសប្បុរស បុណ្យកប់មិនអស់ទើបធ្វើបាន ។
ដូចជាចមពង្សអង្គនរោត្តម សីហនុបរមកដថ្កើងថ្កាន
ហាក់ដូចទេវបុត្រស្រុតពីឋាន ទេវលោកមកឋានកម្ពុជា ។
ឬហាក់ដូចព្រះឥន្ទ្រឲ្យស្រង់ ខ្មែរពីអន្ទង់ទុក្ខវេទនា
ដូចអស់លោកអ្នកជ្រាបគ្រប់គ្នា ខ្ញុំសូមពណ៌នាបន្តិចទៀត ។
ស្រុកខ្មែរពីដើមកម្ពុជា បារាំងគ្រួតត្រាតឹងចង្អៀត(១)

---

១ បារាំងត្រួតត្រាប្រទេសខ្មែរ ដោយអាងទៅលើសន្ធិសញ្ញាដែលលោក Amiral de la grandiere ធ្វើជាមួយនឹងព្រះបាទសម្ដេចព្រះនរោត្តម នៅក្រុងឧដុង្គ ក្នុងខែកក្កដា គ.ស. ១៨៦៣ ហើយនិងសន្ធិសញ្ញាមួយទៀត ដែលព្រះបាទសម្ដេចព្រះនរោត្តម បានឡាយព្រះហស្តលេខា ពីថ្ងៃ ៨ រោច ខែជេស្ឋ ឆ្នាំវក ឆស័ក គ.ស. ១៨៨៤ ជាមួយនឹងមន្ត្រីធំជាតិបារាំង ៣ នាក់ គឺលោក សារល់-ថោមសុន (Charl-Thomson) ចៅហ្វាយស្រុកនៅព្រៃនគរ ជាតំណាងរដ្ឋាភិបាលបារាំងសេស ១, លោក ក្លូប៊ុកូវស្គី (Klobukowsky) នាយខុទ្ទកាល័យរបស់លោកថោមសុន ១, លោក ហ្វូរេស (Foures) ជាតំណាងប្រទេសបារាំង នៅប្រទេសខ្មែរ ១, គឺក្នុងពេលដែលបារាំងឡោមព្រះបរមរាជវាំង ចតុមុខ ក្រុងភ្នំពេញ ។ (បេះតាមលោកអ៊ឹម-ធុំ) ។

ដូចត្រីក្នុងបៀរជាប់ដុចទៀត	បង្អៀតបង្អល់ទល់ប្រដា ។
បារាំងហើយ ចាប់ផ្សឹកព្រះសង្ឃ(១)	កាន់សីលសឹងទ្រង់ព្រះធម្មោ
ព្រោះតែព្រះសង្ឃប្រើសីហាលោ	សំដៅទៅប៉ះបារាំង ។
រីឯព្រះសង្ឃអគ្គិឯទៀត	ហ៊ានទៀតព្រួតគ្នាចូលគាំង
ស្នូរគុសត្រូវទឹងបារាំង	ពាល់តែភ័យខ្លាំងពេញទាំងស្រុក ។
កម្ពុជាជាន់នោះខ្ញ័រផែនដី	មនុស្សទាំងប្រុសស្រីកើតអុកឡុក
រត់ពួនពាសព្រៃបោះបង់ស្រុក	ព្រះសង្ឃផ្លាប់សុខក៏សៅហ្មង ។
មានតែសម្តេចព្រះភូមិន្ទ	នរិន្ទចមជាតិជាចម្បង
ទ្រង់ចាត់បំបាត់ការសៅហ្មង	ធ្វើយុទ្ធតវ៉ាទឹងបារាំង ។
បានផុតពីប្រតិកតូរ៉ក់	សឹងមានសញ្ញាព្រមគ្នាតាំង
កម្ពុជាទៅជាប់ទឹងបារាំង	តែតាំងជារដ្ឋសហភាព(២) ។
តាំងពីនោះមកបារាំងសែស	តោះបុកក្រអែសតែស្លុបៗ
ពុំសូវទន្ទ្រានធ្វើឡូជាប	សភាពជាអ្នកញាញើតច្រើន ។

(១) បារាំងចាប់ផ្សឹកលោកគ្រូអាចារ្យ ហែម-ចៀវ សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ពីខែកក្កដា ឆ្នាំ ១៩៤២ ។ លោកគ្រូអាចារ្យនេះ ជាមិត្តស្និទ្ធស្នាលនឹងខ្ញុំ បានប្រឡងយកទីសាស្ត្រាចារ្យជាមួយគ្នា ពីថ្ងៃទី ២៤-៤-៣១, បានប្តូរយោបល់គ្នាជានិច្ច ក្នុងការបម្រើជាតិសាសនា ព្រះមហាក្សត្រ ។ កាលដែលលោកមានអាសន្ននោះ ខ្ញុំក៏មានក្នុងរឿងនោះដែរ, តែខ្ញុំជាប់ជម្រះតែ ២ ថ្ងៃ រួចពីថ្ងៃព្រហស្បតិ៍ ១១ កើត ទុតិយាសាឍ ឆ្នាំមមីចត្វាស័ក (២៣-៧-៤២)។ ខ្ញុំស្អុតចិត្តអាណិតម្តាយខ្ញុំដល់សព្វថ្ងៃដែលលោកតឹងទ្រូងស្លាប់ព្រោះតែខ្ញុំមានរឿងនោះ ។

(២) Le cambodge était un état autonome faisant partie de l'union française à titre d'état associé en 6 Mai 1947. ។

( នៅមានត )

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

## ដែលមាននៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក-ថែម រៀបរៀង

( តពីលេខ ២ ឆ្នាំ ១៩៦៦ )

**បំណងជើង** "សាស្ត្រា ព្រះនិព្វាន(១)"

**អ្នកនិពន្ធ** *រកពុំទាន់ឃើញ ។*

**កាលបរិច្ឆេទ** *គ្មានបញ្ជាក់ក្នុងអត្ថបទ ។*

**របៀបនិពន្ធ** *ពាក្យរាយ : លំនាំទេសនា ។*

**ប្រភពរឿង** *មហាបរិនិព្វានសូត្រ ។*

**លក្ខណៈឯកសារ** *សាស្ត្រាស្លឹករឹតមាន ៥ ខ្សែចប់ ។ ខ្សែទី ១ មាន ១១ សន្លឹក ខ្សែទី ២ មាន ១០ សន្លឹកកន្លះ ខ្សែទី៣ មាន ១០ សន្លឹក ខ្សែទី ៤ មាន ១៤ សន្លឹក ខ្សែទី ៥ មាន ១៣ សន្លឹក ។*

---

(១) បំណងជើងខាងលើនេះ មិនស្រវឹងអត្ថបទរបស់ប្រភពរឿងទេ ព្រោះអត្ថបទបញ្ចប់បានបញ្ជាក់ថា "មហាបរិនិព្វានសុត្តវណ្ណនា និដ្ឋិតា" ប្រែថា សេចក្ដីពណ៌នាអំពីមហាបរិនិព្វានសូត្រចប់ហើយ ។ ដូច្នេះអ្នកនិពន្ធគួរដាក់បំណងជើងថា "សាស្ត្រាមហាបរិនិព្វានសូត្រ" ដូច្នេះវិញទើបសម ។ ឯអត្ថបទផ្ទៃរឿង ថ្លែងពណ៌នាអំពីព្រះជីវប្រវត្តិរបស់ព្រះពុទ្ធជាម្ចាស់ តាំងអំពីព្រះអង្គប្រសូត្ររហូតដល់ចូលព្រះនិព្វាន ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមក អំពីវត្តសណ្ដែក ខេត្តកំពង់ចាម ចុះលេខ ១០៣៧ ។

**អត្ថបទផ្ដើម** នមោ តស្ស ។ ជាតិកោដិសហស្សេហិ បមាណរ-ហិតំ លោកស្ស លោកនាថេន កតំ យេន មហេសិនា យេន ភគវា ។ ព្រះមានបុណ្យអង្គឯណា មហេសិនា គឺព្រះអង្គស្វែងរកសីលាទិគុណដ៏ប្រសើរ ហិតំ គឺប្រយោជន៍ បមាណរហិតំ ដ៏ប្រាសលែងប្រមាណ កតំ ស្ដេចបានធ្វើហើយ លោកនាថេន ដ៏ជាពំនាក់នៃលោកផងទាំងឡាយ លោកស្ស ពួកលោកនេះ កោដិសហស្សេហិ ដោយនូវកំណើតមួយពាន់កោដិ ។ . . . . . . .

. . . . .. . , . ។ល។ . .

**អត្ថបទបញ្ចប់** បពិត្រអើយ ព្រះមហាកស្សបថេរ អ្នកឋិតនៅដរាបតែអស់អាយុហើយ អ្នកចូលនិព្វានហោង ។ ព្រះអជាតសត្រូវ ក៏សុគតដោយអណ្ដាប់នោះហោង ។ មហាជនផងទាំងឡាយ បានមកជួយប្រដាប់ព្រះសារីរិកធាតុនោះ ដល់រំលាងបញ្ចក្ខន្ធ អំពីមនុស្សលោកនេះទៅ បានទៅកើតនាសួគ៌ទេពលោកនាយហោង ។

មហាបរិនិព្វានសុត្តវណ្ណនា បពិត្រអើយ នេះទីងស្រងីសរសើរ ជំនើរដំណាល កាលព្រះជិនាទបុណ្យ ព្រះអង្គចូលនិព្វាន និដ្ឋិតា សម្រេចនូវប្រការអម្បាលណេះហោង ។

បំណងជើង « សាស្ត្រា ព្រះសុទ្ធិមគ្គ(១) »

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង គោលការណ៍ប្រតិបត្តិផ្នែកខ្លះ ក្នុងលទ្ធិពុទ្ធនិយម

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ១៨ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមក អំពីវត្តព្រៃកុយ ខេត្តកំពង់ចាម ចុះលេខ ១០៣៣ ។

អត្ថបទផ្ដើម នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សត្ថា ជេតវនេ វិហរន្តោ (ធម្មំ) អារព្ភ កថេសិ ។

សត្ថា រីសម្ដេចព្រះសពេជ្ញតាញាណ វិហរន្តោ ព្រះអង្គ

---

១) ឯកសារនេះ មានវិបត្តិច្រើន ទាំងខាងអក្ខរាវិរុទ្ធ ទាំងខាងអត្ថន័យ ទាំងបាលី ទាំងសម្រាយ ទាំងពាក្យពេចន៍ ក៏មានតក់និងភ្លាំងភ្លាត់ច្រើនណាស់ ។

ស្ដេចគង់នៅ ជេតវន ក្នុងព្រះស្រីជ័យជេតពន

សុគន្ធកុដិមហាវិហារ (ធម្មំ) កថេសិ ព្រះអង្គសំដែង

ថ្លែងព្រះធម៌វិសេសទេសនា យោ បុគ្គលោ បើ

បុគ្គលប្រុស-ស្រីផងទាំងឡាយឯណា ចិត្តប្បសាទេន បើ

មានចិត្តកាត់ជំឡាសទ្ធា . . ! . . .

. . . . . . ។ល។ . . .

អត្ថបទបញ្ចប់ វិជ្ជាគឺប្រាជ្ញានោះឯង ឈ្មោះយល់ដឹងរក្សាសីលឲ្យ

បានបរិសុទ្ធនោះឯង តែងទឹងនាំអាត្មា មាតាបិតា ញាតិកា

បុត្រភរិយានោះ ឲ្យបានជាសុខប្រកបផងគ្នា នោះនឿងកបដកប

រួចដល់នគរមហានិព្វាន គឺតដ៏ជាឋានបរមសុខក្សេមក្សាន្តប្រ-

សើរនោះទៀតប្រាកដហោង ។

បពិត្រសប្បុរសផងទាំងឡាយអើយ អាត្មាភាព ទីងសំដែង

ថ្លែងព្រះធម៌វិសេសទេសនា ក្នុងម្ពីព្រះសុទ្ធមគ្គ សង្គ្រោះរូប-

ភូតទាំង ៤ នេះឯង មាននូវប្រការអម្បាលនេះណោះឯងហោង ។

( នៅមានត )

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ-ភាគ ៦

ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកភាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

ចាំង-គេក លើកពែងស្រាឡើងហើយថា ព្រះចៅវុយ-អង មានព្រះគុណលើយើងច្រើនណាស់ ឥឡូវយើងនឹងអាសាទៅធ្វើការសង្គ្រាមនឹង គួន-អ៊ូ គ្រានេះគឺជាទីបំផុតពេលហើយ បើ គួន-អ៊ូ មិនស្លាប់ យើងក៏ត្រូវតែស្លាប់វិញជាប្រាកដ មនុស្សទាំងពួងនោះក៏សរសើរថា លោកមានប្រសាសន៍នេះប្រសើរណាស់ ហើយចាំង-គេក ក៏ហៅនាង លិ-ស៊ី ជាភរិយាចូលមកហើយផ្តាំថា បើយើងអស់ព្រេងសំណាងទៅចាំង-ហូយ ជាបុត្រប្រុសរបស់យើងនេះ មានលក្ខណៈល្អណាស់ ចៅត្រូវឲ្យស្រាប់ ចិញ្ចឹមពាំទុក ដើម្បីនឹងបានទៅច្បាំងសងសឹក នឹង គួន-អ៊ូ ជំនួសយើងតទៅ ។

ខណៈកាលនឹងលើកទ័ពចេញទៅនោះ ប៉ាំង-តេក បង្គាប់ទាហានព្រមគ្នាថា បើយើងស្លាប់ អស់អ្នកទាំងឡាយត្រូវយកមឈូសនេះដាក់ខ្មោចយើងនាំទៅថ្វាយព្រះចៅ វុយ-អង ផងចុះ បើយើងសម្លាប់ គួន-អ៊ូ ស្លាប់វិញ នឹងកាត់យកក្បាល គួន-អ៊ូ ដាក់ក្នុងមឈូសនេះនាំទៅថ្វាយដូចគ្នា ពួកទាហានទាំង ៥០០ ក៏សោមនស្សត្រេកអរថា បើលោកតាំងទៅសេចក្ដីសត្យកតញ្ញូដូច្នេះហើយ យើងខ្ញុំទាំងឡាយក៏ពេញចិត្តខិតខំធ្វើពលការជាមួយនឹងលោកឲ្យអស់តម្រិះប្រាជ្ញា លុះថាដូច្នោះហើយក៏លើកទ័ពទៅ ក្រោយនោះមានមនុស្សនាំយកសំដី ដែលប៉ាំង-តេក និយាយនោះទៅទូលព្រះចៅ វុយ-អង ៗ ក៏ទ្រង់សោមនស្សត្រេកអរណាស់ថា បើ ប៉ាំង-តេក ទៀងត្រង់នឹងយើងដូច្នេះពិត យើងក៏មិនត្រូវគិតព្រួយចិត្តនឹងសត្រូវប៉ុណ្ណោះឡើយ ។

កៃ-អ៊ូ បានឮដូច្នោះក៏ទូលថា ប៉ាំង-តេក នេះ ល្អតែពាក្យអ្នកខ្លាំងពូកែម្យ៉ាង ខ្ញុំគិតព្រួយណាស់ ព្រោះឃើញថា ទោះយ៉ាងម្ដេចក៏មិនឈ្នះ គួន-អ៊ូ ទេ ព្រះចៅវុយ-អង ក៏យល់ឃើញផង ទើបឲ្យបំរើកាន់សំបុត្រតាមទៅនិយាយនឹង ប៉ាំង-តេកថា គួន-អ៊ូ នោះ មានកម្លាំងខ្លាំងពូកែណាស់ ទាំងតម្រិះប្រាជ្ញាវិះគិតគំនិតមារយាទក៏ឆ្លាតទាំងព្រម បើបានទៅច្បាំងគ្នាហើយកុំបីប្រមាថ បើឃើញបានចំណាប់វេលាណាសឹមធ្វើការ បើមិនបានការទេ ក៏ត្រូវតែរាំងរក្សាការពារខ្លួន កុំឲ្យមានសេចក្ដីអន្តរាយ ។

ឯ ប៉ាំង-តេក នោះ លុះដឹងក្នុងសេចក្តីព្រះតម្រាស់ព្រះចៅ វុយ-អង ហើយ ក៏និយាយទឹងទាហានទាំងពួងថា គួន-អ៊ី នោះជាមនុស្សទាហាន ហានក្លាប្រាកដមក ៣០ ឆ្នាំហើយ ឥឡូវយើងទៅកំចាត់ចេញឲ្យបាន ហេតុម្តេចម្ចាស់យើង មកលើកតម្កើងសរសើរ គួន-អ៊ី នោះដូច្នេះ អ៊ុ-គិម ដែលជាមេកងទ័ពធំបានឮ ប៉ាំង-តេក និយាយដូច្នោះក៏ថា ដែលមានព្រះតម្រាស់បង្គាប់មកដូច្នេះ ក៏គួរតែយើងទឹងទទួលធ្វើតាមទើបត្រូវ លុះ អ៊ុ-គិម និង ប៉ាំង-តេក ប្រឹក្សាគ្នាដូច្នេះហើយ ក៏លើកទ័ពធំចូលទៅជិតស្រុក អ៊ួន សៀ ទើបឲ្យទាហានហោស្រែកវាយឃ្មោះ គង ផ្គរស្គរ ព្រមគ្នា ។

ឯ គួន អ៊ី ដែលតាំងបន្ទាយភ្ជាប់គ្នាទឹងស្រុក អ៊ួន-សៀ នោះ លុះដឹងថា អ៊ុ-គិម និង ប៉ាំង-តេក លើកទ័ពមកហើយ ធ្វើអាស្រូវកាសយកមឈូសមកប្រមាទ ទឹងដាក់ក្បាលដូច្នោះ គួន-អ៊ី ក៏មានសេចក្តីខឹងក្តៅខ្លាំងណាស់ថា ខ្លួនយើងក៏មានឫទ្ធីដែលល្បីល្បាញទូទៅក្នុងផែនដី ហេតុអ្វីអាប៉ាំង-តេក ដែលជាមនុស្សទាបថោក វាមកប្រមាថមើលងាយយើងដូច្នេះ គួន-អ៊ី ក៏ប្រើ គួន-បេង ជាកូនចិញ្ចឹមនោះ លើកទ័ពទៅវាយស្រុក អ៊ួន-សៀ ឯគួន-អ៊ី ក៏លើកទៅច្បាំងនឹង ប៉ាំង-តេក គួន-បេង ក៏ជំរាបបិតាថា លោកឪពុកប្រៀបបីដូចជាភ្នំដ៏ធំខ្ពស់ ឯ ប៉ាំង-តេក នោះប្រៀបបីដូចជាដំបូកតូច ១ គួរប្ដូរអញ្ចើញទៅតទឹងវាមិនសមគួរសោះ

ខ្ញុំបាទនឹងសុំទៅតស៊ូនឹង ប៉ាំង-តេក ជាជំនួសបិតាវិញ គួន-អ៊ូថា បើទៅ នឹងទៅក៏ទៅចុះ បិតានឹងលើកពលទៅតាមជាក្រោយ គួន-បេង ក៏ លើកទាហានចេញទៅ ។

ឯ ប៉ាំង-តេកនោះ លុះឃើញគួនបេងលើកទាហានមក ក៏ឲ្យ ទាហានយកទង់ធំ ដែលសរសេរជាអក្សរ ៤ តួ ឈ្មោះថាពួកឡាំហាន់ ប៉ាំង-តេកកាន់ដឹកមុខ ប៉ាំង-តេកនោះពាក់អាវក្រោះកាន់លំពែងជិះសេះ ចេញទៅឃរមុខទាហានទាំងពួង ៥០០ នាក់ ហើយឲ្យលើកយកមល្ហូស ទៅតាំងទុកពីមុខ គួន-បេង លុះឃើញ ប៉ាំង-តេក ជិះសេះទៅបញ្ឈរ នៅដូច្នោះ ក៏ស្រែកជេរថា អាចោរទុយិសទ្រុស្តក្បត់នាយចៅហ្វាយ ។

ប៉ាំង-តេក ឮដូច្នោះ ក៏សួរទាហានទាំងពួងថា ដែលចេញខ្លួនមក នេះគឺឈ្មោះអ្វី ? ទាហានឆ្លើយថា ឈ្មោះគួន-បេងជាបុត្រចិញ្ចឹម គួន-អ៊ូ ប៉ាំង-តេកក៏ស្រែកថា ព្រះចៅរ៉ុយ-អង់ប្រើឲ្យយើងលើកទ័ពមកកាត់យក ក្បាលគួន-អ៊ូជាបិតាឯង ។ គ្រាន់តែជាកូនតូច មិនគួរនឹងមកជាគូសង្គ្រាម នឹងគ្នាទេ ឯងចូរវិលទៅប្រាប់បិតាឯង ឲ្យចេញមកតដៃនឹងយើងវិញ ទើប ត្រូវ គួន-បេងឮដូច្នោះខឹងណាស់ បំបោលសេះចូលទៅប្រយុទ្ធគ្នានឹង ប៉ាំង-តេកដោយក្បួនសេះបាន ៣០ ក្បួន ក៏មិនទាន់ចាញ់ឈ្នះគ្នា ហើយ ទាំងសងខាងក៏ថយកទៅក្រោយវិញ ។

( នៅមានត )

# ឯកសារ កម្ពុជសុរិយា

## (គ)

លោក ឱក-គាម ប្រមូលរៀបរៀង

គចបញ្ចកកម្មដ្ឋាន (កាព្យ) : លោក ស៊ុន-ហ៊ិន, ទ.ក ១, ទំព័រ ១៥, ឆ្នាំ ១៩៥៨ (ម.៥២/៣០)

គបជមិ : ភិក្ខុ ថាច់-សើយសារ៍, ទ.ក ៣, ទំព័រ ២៣៦, ឆ្នាំ ១៩៦៣ (ម ៥២/៣៥) ។

គម្រាជាជសភាស្ត្រ : ព្រះមហាពិទូរក្រសេម, ទ.ក ៧-៨-៩, ទំព័រ ៥៧, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

គម្រាព្រៃធិជប្រជ្ជូលដេវ្សជៗ ជាធំឆាយធីការក្បៀជ : អ្នកស្រី ពេជ្រ-សល់, ទ.ក ៧, ទំព័រ ៨០៣, ឆ្នាំ ១៩៦៤ (ម.៥២/១៦) ។

គម្ពៃព្រះពុទ្ធសាសនា : លោក ស្តើង-ឡូ, ទ.ក ១១, ទំព័រ ១២២០, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

គាថាដំរលៀក : យុនអក្កា ឯក, ទ.ក ៤-៥-៦, ទំព័រ ៥៣, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

គិលមុដ្ឋិជាគក : ព្រះញាណកោសល ញាណ-ឈើន, ទ ក.៧, ទំព័រ ៧៣៤, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

តើព្រះពុទ្ធសាសនាវិវត្តមកដល់ត្រឹមណា : លោកក៉យ-ប៊ុក ទ.ក.៩, ទំព័រ ៨០១, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

តេមិយជាតក : ទ.ក. ៧-៨-៩, ទំព័រ ៤៣, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

ត្រពាំងលាក់ឆក្ក័ល (រឿង) : ទំនៀមទម្លាប់ខ្មែរ ទ.ក. ១១, ទំព័រ ១៣០៣, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

ត្រីមាស (រឿង) : លោកសក់-ខាត់, ទ.ក. ១, ទំព័រ ៤១ ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ត្រៃក្សជជមិ : ព្រះបាឡាត់ សុង-ស៊ីវ, ទ.ក. ៥, ទំព័រ ៣៦៣, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

ត្រៃរតនគាថា : លោកឯន-ប៉ង់, ទ.ក. ១១, ទំព័រ . . . , ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

ថេរប្បវត្តិ : ព្រះគ្រូធម្មបរិយាវង្ស ទឹម; ទ.ក. ១២, ទំព័រ ១១៣, ឆ្នាំ ១៩២៦ (ម.៥២/១) ។

ទង់ពុទ្ធសាសនា : លោកជង-វង់, ទ.ក. ១, ទំព័រ ៣៨, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

ទសជាតកនិងបឋមសម្ពោធិ : អ្នកឧកញ៉ាវរវៀងជ័យ ជួន, ទ.ក. ១, ទំព័រ ១៣, ឆ្នាំ ១៩២៦-២៧ (ម.៥២/១) ។

ឧស្សាហការឌីសាណាជិ (អំពី) : ទ.ក ៤ ៥-៦, ទំព័រ ១១, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ធាក់ជ្រូកព្រៃ (រឿង) : ម- រឿងទាក់ជ្រូកព្រៃ ។

ធាក់ដំរី (រឿង) : ម- រឿងទាក់ដំរី ។

ធាធ ៤ យ៉ាងផង ពរ ៨ ប្រការ : ព្រះញាណ ឈឹន, ទ.ក ១០, ទំព័រ ៨៨៣, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

ធិដ្ឋធម្មិកកថា : ព្រះអរិយកស្សប កែវ-អ៊ួប, ទ.ក១១, ទំព័រ ៨១២, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

ធិដ្ឋធម្មិកត្ថកថា : ព្រះទេពសត្ថា សុ-ហាយ, ទ.ក.២, ទំព័រ ១២៦, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

ធិដ្ឋានុគតិ : លោក ផែន-ន, ទ.ក.៧, ទំព័រ ៥៥១, ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

ធីបធម្មកថា : ព្រះមហា ជា-សន, ទ.ក.៨, ទំព័រ ៨៤៥, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

ធីកាត្រជាក់ត្រីកុំ . សាស្ត្រាចារ្យ ឈឹម-ស៊ុម, ទ.ក.១, ទំព័រ ៣៦, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ធីកានដ្ឋេសាប : គិម-ហាក់, ទ.ក.១-២-៣, ទំព័រ ៥, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

ធុមេធជាតកៈ ម-ឯកវិបាតជាតក ។

ធុល្លភបុគ្គល ២ ពួក : ព្រះមហា ប៉ាន់-ផុន, ទ.ក. ៥, ទំព័រ ៣២៣, ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

ទេវតា : លោក ផេង-គ្រីវ ទ.ក. ២, ទំព័រ ១០៩, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ទេវតាមានមែនឬ? : លោក ប៊ូ ប៉ូ, ទ.ក ១៤, ទំព័រ ៩០០, ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

ទេវទត្តគឺអ្នកណា? : ទ.ក. ២៣, ទំព័រ ១៣, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ទេវធម្ម : លោក អម្រឹតក្សត្រី ម៉ុក (លោក ញ៉ុក-ថែម ពិនិត្យ, ទ.ក.២, ទំព័រ ១៤៤, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ទេសភាពនៃរដ្ឋនេប៉ាល់និងរដ្ឋបិដ្ឋល័ : លោក ព៉យ-ប៊ុក, ទ.ក. ៤, ទំព័រ ៣៧៧, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

ទោសនៃសុរា : ព្រឹទ្ធបាលទោ ជា-ប៉ូ, ទ.ក. ៨, ទំព័រ ៧២៩, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

ទៅលេងឋានសួគ៌មួយដប់ថ្ងៃ : លោក ញូង-សឿង ទ.ក. ៩, ទំព័រ១០៤៥, ឆ្នាំ ១៩៥៩ (ម.៥២/៣១)។

ទំពែក ៤ ជាក់ : ទ.ក. ១០-១១-១២, ទំព័រ ២៦១, ឆ្នាំ ១៩៣៨ (ម.៥២/១០) ។

ទំនុកសរសើរព្រះបារមី បនក្រុងឆតភេជ : សម្តេចហៅ-ហ្វាក់ង៍ ទ.ក. ១-២-៣, ទំព័រ ៥, ឆ្នាំ ១៩៣៣ (ម.៥២/៦)។

ទំនៀមកាន់ទុក្ខសពនៃសាមញ្ញជនជាតិខ្មែរ : លោក ប៊ូ-ប៊ូ, ទ.ក. ៨, ទំព័រ ៨១៩, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

ទំនៀមទម្លាប់កុលសម្ពន្ធ : លោក ឌីក-គាម, ទ.ក.១០, ទំព័រ ១១៩០, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

ទំនៀមទម្លាប់ខ្លះនៅសហរដ្ឋអាមេរិក : លោក គួច-គីឡេង ទ.ក. ៧, ទំព័រ ៧៤៤, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ទំនៀមទម្លាប់ និងឧត្តមប្រយោជន៍ក្រុមជំនុំ ទំនៀមទម្លាប់ខ្មែរ : ទ.ក ១២, ទំព័រ ៩៤៨, ឆ្នាំ១៩៥២ (ម.៥២/២៤) ។

ទំនៀមធ្វើស្រែនៅកម្ពុជាក្រោម : លោកអាចារ្យ ឌិញ-ប្រាជ្ញ ទ.ក ១, ទំព័រ ១៨, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

ទំនៀមទម្លាប់ស្ត្រីនៅស្រុកទីបេត៍ : អ្នកស្រីសារ៉ះយាន, ទ.ក ២, ទំព័រ ១៤១, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

និទានបង្ហិលពពិល : អ្នកស្រី ពេជ្រ-សល់, ទ.ក ៨, ទំព័រ ៧៣៦, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

និទានបេះក្រវាញ : អ្នកស្រី ពេជ្រ-សល់, ទ.ក ១, ទំព័រ៦២, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

និទានត្រពាំងទូកនៅស្រុកថាសាក់ ខេត្តឃុំង ក្បាសាំងស៊ុន : លោកថាច់-ប៉ែន, ទ.ក ៦, ទំព័រ ៦៧៣, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

និទានស៊ុំអឹកាក្មៀង : អ្នកស្រី ពេជ្រ-សល់, ទ.ក ៩, ទំព័រ ៩៨២, ឆ្នាំ ១៩៦៤ (ម.៤២/៣៦) ។

និទានហុចស្លាម៉ាត់ : អ្នកស្រី សារ៉ះយ៉ាន, ទ.ក១១, ទំព័រ៨៣៥, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

និទានអ្នកស្រុកប៉ៃលិន : លោក លី-ធាមតេង, ទ.ក. ៦, ទំព័រ ៣៦, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ទ្វារនៃប្រយោជន៍៦ យ៉ាង : លោកស្រី អ៊ូ, ទ.ក. ៩, ទំព័រ ៧៩១, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ទ្វាន សមាស តាមនិទានព្រាហ្មណ៍ក្នុងនគរពារាណសី (ពិធី) : ទ.ក. ១៣-១៤, ទំព័រ ៣២, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ធ្វានសក្កម្មកថា : ព្រះមុនីកោសល សុ-ហាយ, ទ.ក. ១, ទំព័រ ១០, ឆ្នាំ១៩៦៤ (ម.៥២|៣៦) ។

ធនញ្ជយបណ្ឌិត : ទ.ក. ១២-៣, ទំព័រ៦៧, ឆ្នាំ ១៩៣៨ (ម.៥២/១០) ។ ទ.ក ១-២-៣, ទំព័រ ៤១, ឆ្នាំ ១៩៣៧ (ម ៥២|៩) ។

ធម្មគោរព : ព្រះឧត្តមមុនី ម៉ឺន-សែស, ទ.ក. ៦, ទំព័រ ៣៤០, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ធម្មចក្កប្បវត្តសុត្ត : ព្រះមហានន្ទ, ទ.ក.៤, ទំព័រ៧, ឆ្នាំ១៩២៧ (ម.៥២/២) ។

ធម្មចរិយា : ព្រះគ្រូបញ្ញាលិខិត កៅ-ស៊ុម, ទ.ក. ៣, ទំព័រ ១៧៧, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

ធម្មទេសនា : ព្រះមហា ហួត, ទ.ក. ៧-៨-៩, ទំព័រ ១៥១, ឆ្នាំ ១៩៣៩ (ម.៥២/១០) ។

ធម្មធ្វជបណ្ឌិត (រឿង) : លោក សាំ-ឌុំ, ទ.ក.៩, ទំព័រ ៦៥៧, ឆ្នាំ១៩៥៥ (ម.៥២/២៧) ។

ធម្មានុធម្មប្បដិបត្តិកថា : ព្រះមហា ថោង-យូ, ទ.ក. ៧, ទំព័រ ៤៨៣, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

ធម្មបទកាសិត : លោកគ្រូបៅអធិការ ឯក-ញឹម, ទ.ក ១១, ទំព័រ, ៥៩៤, ឆ្នាំ ១៩៤៤ (ម. ៥២/១៦) ។

ធម្មកាសិត : គ្រូបង្រៀន ប៉ាន គេង, ទ.ក.១-២-៣, ទំព័រ ១០២, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

ធម្មវិចារណកថា : ព្រះសាសនមុនី កឹម-គូ ទ.ក.៩, ទំព័រ ៩៦៣, ឆ្នាំ ១៩៦២ (ម ៥២/៣៤) ។

ធម្មវិភាវិធី : ព្រះគ្រូសុវិឡុញ្ញាណ សូ-ហាយ, ទ.ក.៨, ទំព័រ៤៣៣, ឆ្នាំ១៩៤៦ (ម.៥២/១៨) ។

ធម៌គ្រប់គ្រងលោក : លោក ប៊ូ-ប៊ូ, ទ.ក. ៣, ទំព័រ ២៤៦, ឆ្នាំ១៩៦៥ (ម. ៥២/៣៧) ។

ធម៌ទេសនាអំពីពុទ្ធសាសនានៅទីបេត៍ កំមង់ដង់រូប៊ែរ ទ.ក ៩, ទំព័រ ៧៩, ឆ្នាំ១៩២៦-២៧ (ម. ៥២/១) ។

ធម៌ទេសនាអំពីព្រះនិញ្វាន : លោកកំម៉ង់ដង់រូប៊ែរ ទ ក.១, ទំព័រ ៦៩, ឆ្នាំ១៩២៧ (ម. ៥២/២) ។

ធម៌សង្គ្រោះ : ព្រះមហា ឡុច, ទ.ក ៨, ទំព័រ ៥៧៣, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។

ធម្មាធាសកថា : ព្រះបាឡាត់ឧត្តមលិខិត សុង-ស៊ុវ, ទ.ក. ១០, ទំព័រ ៧២៣, ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

ជម្មាដិប្បាយ : ព្រះបាឡាត់ធម្មប្បញ្ញាញាណ ស៊ុន-ហ៊ាន, ទ.ក. ៩, ទំព័រ ៩៣៣, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ជម្មាដិប្បាយ «សោវចស្សតា» : លោក ស៊ុន-ហ៊ាន, ទ.ក. ៩, ទំព័រ ៤៩៨, ឆ្នាំ ១៩៤៦ (ម.៥២/១៨) ។

ជម្មិតកាភាគ (កាព្យ) : លោកចៅអធិការ ឯក-ញឹម, ទ.ក. ៨-៩, ទំព័រ ៣៩៣, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

ធុរៈ ២ យ៉ាងក្នុងព្រះពុទ្ធសាសនា : ព្រះទេពសត្ថា គឹម-តូ, ទ.ក. ៣, ទំព័រ ១៩៩, ឆ្នាំ១៩៥៨ (ម.៥២/៣០) ។

ធ្មេញដៃបណ្ឌិត : ទ.ក. ៤-៥-៦, ទំព័រ ១៨១, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

ឆក្ខត្តជាតក : ម— ឯកនិបាតជាតក ។

ឆគវត្ត (រូបនាងអប្សរនៅទ្វារចូលខាងលិច : ទ.ក. ៣, ទំព័រ ១, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ជាងនាយដើងក្រាន : ម— រឿងនាងនាយដើងក្រាន ។

ជាងសក់ក្រអូប : លោក ញ៉ែម-ខឹម, ទ.ក ១១, ទំព័រ ១២៧០, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

ជាតករណធម៌ : ព្រះមហា យ៉ក-ទ្រលន់, ទ.ក ១១, ទំព័រ៨០៣, ឆ្នាំ ១៩៥៣ (ម ៥២/២៥) ។

នារទកស្សប (កាព្យ) : លោក យូរ-អ៊ុន, ទ.ក ២, ទំព័រ ១៧១,

ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

នានាភាសិត : ព្រះគ្រូមុនីសោភ័ណ សោម ឡុប, ទ.ក ១, ទំព័រ

៣៣, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

នានាសារធម៌ : លោក ស៊ុន-ហ៊ិន, ទ.ក ១២, ទំព័រ ៨៩៥,

ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

នាយកធម៌ : ព្រះមហា ធូរ-សុទ្ធ, ទ.ក ៩, ទំព័រ ៦៥១, ឆ្នាំ

១៩៥២ (ម.៥២/២៤) ។

នាយឆ្មា (រឿង) : លោក លាង-ហ័ចអាន, ទ.ក ១, ទំព័រ ៨៨,

ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

នាលៈនិងទមយន្តី : អ្នកស្រី ស្រ៊ិន-សារីយ៉ាន, ទ.ក១, ទំព័រ ៤៦,

ឆ្នាំ១៩៥៤ (ម.៥២/២៦) ។

និតិសាស្ត្រ (កាព្យ) : អាចារ្យហ៊ុម, ទ.ក ២.៣, ទំព័រ ២៣,

ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

និទានសុភាសិត : ព្រះមហា ម៉ៅ-ខាន់, ទ.ក ៧, ទំព័រ ៥០១,

ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។ ទ.ក ៧, ទំព័រ ៦១៩, ឆ្នាំ

១៩៥៧ (ម.៥២/២៩) ។

និទានមាន់ផ្គាត់ : ទ.ក ៨, ទំព័រ ៤៨៩, ឆ្នាំ ១៩៤៣ (ម.៥២/១៥)

និទានសុភាសិតទី ១ : លោកគ្រូអាចារ្យ ពាន់-សុខ, ទ.ក ១០, ទំព័រ ៥៥១, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

និព្វានកថា : ក្រមការ ញ៉ែម-យ៉ន៍, ទ.ក ៤-៥-៦, ទំព័រ ១០៦, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

និព្វានសុត្ត : ឧកញ៉ាកត្តិពជា យ៉ុង, ទ.ក ៤-៥-៦, ទំព័រ ៩៣, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

និរយកថា : មហា ឧម-ណាគ្រី, ទ.ក ១០, ទំព័រ ៧៧៨, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។ ព្រះមហា អ-សុវណ្ណណាគ្រី សុវិឡ្យនោ, ទ.ក ៩, ទំព័រ ៦៨០, ឆ្នាំ ១៩៤៨ (ម.៥២/២០) ។

និរាសនគរវត្ត : ឧកញ៉ាសុត្តន្តប្រីជា-ឥន្ទ, ទ.ក ៧-៨-៩, ទំព័រ . . . . ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

បក្សាចចាតទ្វទ្វនិងកាំព្យលបក្សា (រឿង ព្រង់ចិន) : លោក ក៉យ ប៊ុក, ទ.ក ១៦, ទំព័រ ១១៦៨, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

បញ្ញាសជាតកភាគទី ៤ : បណ្ឌិតមហា ឈឹម-ស៊ុមន៍ ទ.ក៩, ទំព័រ ៦៦៨, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

បក្សីចិត្ត (រឿងព្រេង) : សាស្ត្រាចារ្យ ផេង-ជ្រើវ, ទ.ក៧, ទំព័រ ៥២៧, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

បងប្អូនពីរនាក់ចែកមត៌កគ្នា : លោក ផេង-ជ្រើវ, ទ.ក. ៥, ទំព័រ ២២, ឆ្នាំ ១៩៦៤ ( ម.៥២/៣៦ ) ។

បងប្អូនពីរនាក់និងមាន់ផ្ទាក់ : លោក ទៀង-តៃណុន. ទ.ក. ៩, ទំព័រ ៨៤៥, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

បង្សុកូលឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធនៃឯ.ឧ រាជេន្ទ្រប្រាសាទប្រធានាធិបតីនៃប្រទេសឥណ្ឌា: ទ.ក. ៣, ទំព័រ ៣៣២, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

បញ្ញាគាថា : ព្រះមហា ឈឹម-សាមី, ទ.ក. ៦, ទំព័រ ៥១៣, ឆ្នាំ ១៩៥៦ ( ម.៥២/២៨ ) ។

បញ្ញាបរិយាយ : ព្រះឧបាលិវង្ស សូ-ហាយ, ទ.ក.៦, ទំព័រ៥៣៦, ឆ្នាំ១៩៥៦ (ម.៥២/១៦) ។

បញ្ញាវុឌ្ឍិគាថា : ព្រះមហាសុខ-វន, ទ.ក.៧, ទំព័រ ៤៨៨, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។

ប្រវត្តិលោកគ្រូចៅអធិការវត្តក្បាលកោះ : ព្រះអាចារ្យ ជាម-លាន់ហា, ទ.ក ៣, ទំព័រ ២២៧, ឆ្នាំ ១៩៤៩, (ម.៥២/២១) ។

បដាចារ (ធាជ់) : សាមណេរគួច-គីឡេង, ទ.ក ៩, ទំព័រ ៧០៧, ឆ្នាំ ១៩៥០ (ម.៥២/២) ។

បណ្ដាំមាតា : ឃុនសិរីមេធីស្រី អ៊ូ, ទ.ក. ១១, ទំព័រ ៨០១, ឆ្នាំ ១៩៤៩ (ម ៥២/២១) ។

បណ្ឌិតគាថា : ព្រះមហាអ៊ុក-អ៊ុន, ទ.ក.១, ទំព័រ ១, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

បទអុំទូក : លោកឱ-គាម, ទ.ក ៩, ទំព័រ ៩៩៤, ឆ្នាំ ១៩៦៤ (ម ៥២/៣៦) ។

បដានគាថា : ព្រះទេពមុនីយូរ-ប៉ុណ្ណ, ទ.ក ៩, ទំព័រ ៦៩៦, ឆ្នាំ ១៩៤៩ (ម. ៥២/២១) ។

បញ្ហាមុតយកបញ្ហាដោះ : លោក ប៊ូ-ប៉ូ, ទ.ក. ៩, ទំព័រ ១០៣៧, ឆ្នាំ ១៩៥៩ (ម. ៥២/៣១) ។

បមាណាប្បមាណគាថា : អាចារ្យសេខ-ឈុន, ទ.ក. ១០-១១-១២; ទំព័រ ២០៩, ឆ្នាំ ១៩៣៧ (ម. ៥២/៩) ។

បរិយាយសិប្បកថា : ព្រះគ្រូសុវណ្ណញាណសូរ-ហាយ, ទ.ក ៤ ទំព័រ ២០៩, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

បរិវត្តកម្មជាតកម្មក្នុងឆ្នាំ ១៩៣៣ : របស់ព្រះសាសនសោភណ ជ.ណាត, ទ.ក.៤-៥-៦, ទំព័រ ១១៩, ឆ្នាំ១៩៣៦ (ម.៥២/៨) ។

បាឋកថាអំពីវិន័យនិងច្បាប់គ្រហស្ថ : អ្នកឧកញ៉ាទេពពិទូរ ក្រសេម, ទ.ក.៣, ទំព័រ ១៥២, ឆ្នាំ១៩៤៤ (ម ៥២/១៦) ។

បាឋកថា រឿងពុទ្ធរូបបូរាណ : ឃុនអត្ថកោវិទជា យូ, ទ.ក.៣, ទំព័រ ២២០, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

បារឡាអាមនិងយូសាហ្វាត (ឬរឿងព្រះពុទ្ធក្នុងគម្ពីររបស់សាសនាគ្រាបៀង) : ក្រុមការជុំ-ម៉ៅ, ទ.ក.១, ទំព័រ ៩, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុណ្យឆ្លងព្រះវិហារ និង សាលាបឋមសិក្សានៅវត្តសិរី-បទុម (វត្តអន្លង់ស) ស្រុកកងមាស កំពង់-ចាម : លោកតាប-ពិន, ទ.ក ៥, ទំព័រ ៣៩១, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

បុណ្យឈាបនកិច្ចសពអ្នកអាចារ្យហ៊ុន-សុជ : កិត្តិ សួន-សុរិន្ទ, ទ.ក.៤, ទំព័រ៣១២, ឆ្នាំ១៩៤៩ (ម.៥២/២១) ។

បុណ្យដង្ហែព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ និងអរហន្តធាតុទៅដំកល់ក្នុងទីវត្តប្រាង្គណ៍ (ឧដុង្គ): ទ.ក ១, ទំព័រ១, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុណ្យទក្ខិណានុប្បទានជូនលោកស៊ីហ៊ីស្យាត់ (នៅវត្តប្រាង្គ) : ទ.ក. ១-២-៣, ទំព័រ ១, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

បុណ្យបញ្ចុះសីមានិងឆ្លងព្រះវិហារវត្តប្រាង្គ : ទ.ក៣, ទំព័រ ៣៤៣, ឆ្នាំ ១៩៦៤ (ម. ៥២/៣៦) ។

បុណ្យបញ្ចុះធាតុលោកគ្រូព្រះសពសុភា-ឆួន : ចៅអធិការឯក-ញឹម, ទ,ក.១, ទំព័រ ៥២, ឆ្នាំ១៩៤៩ (ម.៥២/២១) ។

បុណ្យបញ្ចុះសីមាវត្តលង្កា : ទ.ក.៥, ទំព័រ៥៦៧,ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

បុណ្យប្រគេនកញ្ចប់ថាយ (ពិធី) នៅស្រុកលាវ : ភិក្ខុសុមនសិស្សស៊ុំអួន, ទ.ក. ៧-៨-៩, ទំព័រ៣៧, ឆ្នាំ ១៩៣៦ (ម. ៥២/៨) ។

បុណ្យព្រះរាជទានព្រះភ្លើងព្រះសពព្រះអង្គម្ចាស់ក្សត្រីហារិរក្ខមណ្ឌានិត្យម៉ាលេ (មន្ទា) : ទ.ក២៣, ទំព័រ ៥៣, ឆ្នាំ ១៩៣៦ (ម. ៥២/៨) ។

បុណ្យសម្ពោធឆ្លងព្រះពុទ្ធរូបសិលានៅទីក្រុងឯករាជ : ព្រះមហាពិទូរក្រសេម, ទ.ក. ៧-៨-៩, ទំព័រ ៩, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុប្ផានារី : លោកញ៉ុង-សៀង, ទ.ក ៦, ទំព័រ ២៨៥, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

បុរសចេះថ្នាំពិសពស : ទ.ក១០-១១-១២, ទំព័រ ២០១, ឆ្នាំ ១៩៣៧ (ម.៥២/៩) ។

បុរសបររទេះពីរនាក់ទាស់ទែងគ្នា (រឿងព្រេង) : ទ.ក. ១៨, ទំព័រ ២៧, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

បុរសពីរនាក់តាមខ្ញុំរត់ (រឿងព្រេង) : ទ.ក ១៧, ទំព័រ២៨ ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

បុរសពីរនាក់ទៅបរបាញ់ (រឿងព្រេង) : ទ.ក ២៤, ទំព័រ ២៥, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

បុរសពីរនាក់ទាស់ទែងគ្នាអំពីរឿងជីកអណ្តូង (រឿងព្រេង) : ទ.ក.១៩៩ ទំព័រ ២៦ ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

បុរសពីរនាក់រែកស្រូវ (រឿងព្រេង) : ទ.ក ១៥, ទំព័រ ២៧, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

(នៅមានត)

# ផ្នែកកំណាត់និងប្រវត្តិការណ៍

## សេចក្តីកត់ហេតុនៃការប្រជុំការងារ

### នៅពុទ្ធសាសនបណ្ឌិត្យ

ថ្ងៃទី ១១-៣-៦៦

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំមួយ ថ្ងៃទីដប់មួយ ខែ មិនា ពេលម៉ោងប្រាំបីព្រឹក មានការបើកសម័យប្រជុំការងារមួយ ក្រោមអធិបតីភាពនៃសហជីវិនលាង-ហ័បអាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ ដោយមានសហការីរបស់លោកជាច្រើនរូប បានចូលរួមផង :

១– សហជីវិន លឹម លាងជិន អគ្គលេខាធិការ

២– – ញូង · សឿង អគ្គលេខាធិការរង

៣ - – ឈឹម · ណាក នាយការិយាល័យគណនេយ្យ

៤ – – ឌឹម . គាម នាយការិយាល័យបណ្ណាល័យ

៥ សហជីវិនី ពេជ្រ . សល់ នាយការិយាល័យទំនៀមទំលាប់

៦– សហជីវិន សូ , ប៉ូ លេខាធិការកត់ហេតុ ។

បន្ទាប់ពីការថ្លែងអំណរគុណចំពោះអង្គប្រជុំរួចហើយ សហជីវិន នាយកក៏បានបើកពេលប្រជុំ ដោយយកបញ្ហាការបោះពុម្ពសៀវភៅដាក់ឲ្យអង្គប្រជុំដោះស្រាយ ។ ទីប្រជុំ បន្ទាប់ពីបានប្តូរយោបល់គ្នាយ៉ាងយូរមក ក៏បានសម្រេចដូចតទៅ :

# ទី១បញ្ហាបោះពុម្ពសៀវភៅនៃក្រសួង :

ការបោះពុម្ពសៀវភៅនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

ទី១- សៀវភៅបន្ទុក cahier de charge ចុះថ្ងៃទី ២៨ មេសា ១៩៦៥ ប្រការ ១១ ថែងថា :

សៀវភៅបោះពុម្ពផ្សេងៗ របស់ពុទ្ធសាសនបណ្ឌិត្យ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដែលមានតម្លៃលើសពី ១១ ម៉ឺនរៀលសម្រាប់លក់ជាកម្រៃសម្រាប់ថវិការជាតិ ត្រូវមានគណៈកម្មការមួយសម្រាប់ទទួលខុសត្រូវ មានសមាសភាពដូចតទៅ :

១.- នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ប្រធាន

២ – តំណាងអនុរដ្ឋលេខាធិការក្រសួងធម្មការ សមាជិក

៣ នាយការិយាល័យដំរះបញ្ជីក្រសួងធម្មការ -ដ-

៤ – នាយឃ្លាំងពុទ្ធសាសនបណ្ឌិត្យ -ដ-

៥ – លេខាធិការមួយរូប -ដ-

គណៈកម្មការនេះមានភារៈពិនិត្យ និងកប់ទូវចំនួនសៀវភៅទាំងអស់ដែលអ្នកផ្គត់ផ្គង់បានដឹកនាំយកមកប្រគល់ជូន តាមរយៈវេលាដែលមានកំណត់ក្នុងសៀវភៅបន្ទុកនេះស្រាប់ ។

ទី២- សៀវភៅបោះពុម្ពផ្សាយផ្សេងៗ ដែលមានចំនួនត្រឹម ១០ ម៉ឺនរៀលចុះមក ត្រូវអនុវត្តទៅតាមព្រះរាជក្រឹត្យលេខ ៥៨១ នស ចុះ

ថ្ងៃទី ១៩-៩-៥៨ ។ មាត្រា ១ កថាខណ្ឌទី ២ ថែងថា:

បណ្ណបញ្ជាត្រូវមានចុះហត្ថលេខាទៅក្រសួង ដោយមានហត្ថលេខាយល់ព្រមរបស់អ្នកបញ្ជាចំណាយថវិកា " ordonnateur du budget " រដ្ឋមន្ត្រីក្រសួងធម្មការ ហើយចុះហត្ថលេខាទិដ្ឋាការនៃក្រុមអភិបាលវិលញ្ញូនទៀតផង ។

ចំណាយទាំងនេះធ្វើឡើង ដោយការពិគ្រោះតម្លៃក្នុងលំទិតលាយលក្ខណ៍អក្សរចំពោះអ្នកផ្គត់ផ្គង់ ។

ទី ៣ - គណៈកម្មការទទួលខុសត្រូវក្នុងមុខចំណាយនៃវគ្គទី ២ ខាងលើរបស់ក្រសួងដែលបានអនុវត្តជាហូរហែរួចមកហើយ ហើយទឹងបន្តទៅទៀតគឺមាន :

១ - នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ គឺសហជីវិន

លាង-ហ័បអាន ប្រធាន

២ - សហជីវិន ញ៉ុង-សៀង អគ្គលេខាធិការរង សមាជិក

៣ - - ឈឹម-ណាក នាយការិយាល័យគណនេយ្យ -ដ-

៤ - - កៀង-ស្សេង នាយឃ្លាំង -ដ-

បញ្ជាក់: សហជីវិន ញ៉ុង-សៀង ត្រូវអស់គាណត្តិជាសមាជិកនៅពេលចូលនិវត្ត ហើយសហ-លឹម-លាងជ៉ូន អគ្គលេខាធិការ នឹងជំនួស

វិញ នៅពេលព្រះរាជក្រឹត្យតាំងពេញច្បាប់ ។

ទី ៤. តាមសេចក្តីកត់ហេតុថ្ងៃទី ៨-១០-៦៥ ស្តីពីការបោះពុម្ពសៀវភៅ ដោយការកែប្រែរបៀបខាងក្នុង និងទំហំសៀវភៅ ក្រុមជំនុំយល់ឃើញថា ទំព័រសៀវភៅកើនចំនួនច្រើន ដូច្នេះតម្លៃបោះពុម្ពត្រូវឡើងជាងមុនបន្តិច ហើយតម្លៃលក់ក៏ឡើងជាងមុន ដើម្បីឲ្យបានចំណេញ ៣០ ភាគរយដល់ថវិកាជាតិ ។

## ទី ២ បញ្ហាការតាំងនាយផ្នែកសំរាប់ការិយាល័យ បោះពុម្ពផ្សាយ :

ការតាំងនាយផ្នែកសំរាប់ការិយាល័យបោះពុម្ពផ្សាយសៀវភៅផ្សេងៗរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ លើកលែងតែទស្សនាវដ្តីកម្ពុជសុរិយាចេញ ក្រុមជំនុំបានមូលមាត់តាំងសហជីវិន ប៉ិ-សុវណ្ណ ជានាយផ្នែក « chef de section » ជំនួសសហជីវិន ឌិក-គាម ដែលតាំងជានាយការិយាល័យបណ្តោះអាសន្ននៃបណ្ណាល័យ ។

បន្ទាប់ពីការថ្លែងអំណរសាទរជាថ្មីចំពោះអង្គប្រជុំមក សហជីវិននាយកក៏ប្រកាសបិទពេលប្រជុំនៅពេលម៉ោង ១០ និង ៥ នាទីព្រឹក នៅថ្ងៃខែ ឆ្នាំ ដដែល ។

ភ្នំពេញ ថ្ងៃទី ១៩ មីនា ឆ្នាំ ១៩៦៦

លេខាធិការទីប្រជុំ

បានឃើញ និង យល់ព្រម

ប្រធាននៃអង្គប្រជុំ

សមាជិកនៃអង្គប្រជុំ :

១ សហ-លីម លាងជិន

២- ញូង-សឿង

៣- ឈឹម-ណាក

៤ - ឌឹក-តាម

៥- សហជីវិន ពេជ្រ-សល់